## ក្រសួងអប់រំ យុវជន និងកីឡា

Ministry of Education, Youth and Sport

## វិទ្យាស្ថានជាតិអប់រំ

National Institute of Education

# និក្ខេបបទ

# ការប្រើប្រាស់សៀវភៅសិក្សាភាសាអង់គ្លេសនៅកម្រិតអនុវិទ្យាល័យ ខេត្តស្វាយរៀង

# The using of English TextBook in Junior High School Svay Rieng Province


ដោយ/by

**ថៃ ណាគ្រី**

THAI NAKRY


**ដើម្បីបំពេញលក្ខខណ្ឌបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៧**

**ឯកទេសៈ គ្រប់គ្រងអប់រំ**

**ឆ្នាំសិក្សា ២០១៨-២០២០**

# ក្រសួងអប់រំ យុវជន និងកីឡា

Ministry of Education, Youth and Sport

## វិទ្យាស្ថានជាតិអប់រំ

National Institute of Education

# និក្ខេបបទ

# ការប្រើប្រាស់សៀវភៅសិក្សាភាសាអង់គ្លេសនៅ
# កម្រិតអនុវិទ្យាល័យ ខេត្តស្វាយរៀង

# The using of English TextBook in Junior High School

# Svay Rieng Province


ដោយ/by

**ថៃ ណាគ្រី**

THAI NAKRY


ដើម្បីបំពេញលក្ខខណ្ឌបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៧

ឯកទេស៖ គ្រប់គ្រងអប់រំ

ឆ្នាំសិក្សា ២០១៨-២០២០


គ្រូដឹកនាំបន្ទោល៖ បណ្ឌិត អាន វ៉ប្រាថ

គ្រូដឹកនាំរង ៖ លោក ឡុច ចាន់ថន

# សេចក្តីអះអាងរបស់បេក្ខជន

ខ្ញុំបាទសូមបញ្ជាក់ថា និក្ខេបបទស្រាវជ្រាវដែលមានចំណងជើងថា «**ការប្រើប្រាស់សៀវភៅភាសាអង់គ្លេសនៅកម្រិតអនុវិទ្យាល័យ ខេត្តស្វាយរៀង**»សម្រាប់បំពេញលក្ខខណ្ឌបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំនៅវិទ្យាស្ថានជាតិអប់រំ គឺជាស្នាដៃស្រាវជ្រាវរបស់ខ្ញុំបាទទាំងស្រុង។ ស្នាដៃនេះមិនដែលបានប្រើប្រាស់ ដើម្បីបំពេញលក្ខខណ្ឌសម្រាប់ទទួលសញ្ញាបត្រនៅវិទ្យាស្ថាន និងសាកលវិទ្យាល័យណាមួយឡើយ។ សេចក្តីដកស្រង់ និងខ្លឹមសារផ្សេងៗ ដែលបានយកមកប្រើប្រាស់នៅក្នុងអត្ថបទស្រាវជ្រាវនេះសុទ្ធតែបានចុះបញ្ជីក្នុងឯកសារយោងទាំងអស់។

និក្ខេបបទស្រាវជ្រាវនេះ ពិតជាចងក្រងដោយខ្ញុំបាទផ្ទាល់ពិតប្រាកដមែន។

ថ្ងៃ ..................ខែ............. ឆ្នាំ.................ព.ស. ២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី....... ខែ...... ឆ្នាំ ២០២០

**ហត្ថលេខាបេក្ខជន**

**ថៃ ណារុត្រី**

# លិខិតបញ្ជាក់

បណ្ឌិត **អាន វ៉ុប្រាជ** ជាគ្រូដឹកនាំបង្គោល និងលោក **ឡុច ចាន់ថន** ជាគ្រូដឹកនាំរង

## សូមបញ្ជាក់ និងទទួលស្គាល់ថា

លោក **ថៃ ណារ្រត្តី** ជានិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៧ ពិតជាបានសរសេរនិក្ខេបបទស្រាវជ្រាវ «**ការប្រើប្រាស់សៀវភៅសិក្សាភាសាអង់គ្លេសនៅកម្រិតអនុវិទ្យាល័យ ខេត្តស្វាយរៀង**» ពិតប្រាកដមែន។

ថ្ងៃ................. ខែ................. ឆ្នាំ............. ព.ស.២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី...... ខែ....... ឆ្នាំ២០២០

................................ ..............................

**អាន វ៉ុប្រាជ** **ឡុច ចាន់ថន**

គ្រូឧទ្ទេស គ្រូឧទ្ទេស

វិទ្យាស្ថានជាតិអប់រំ វិទ្យាស្ថានជាតិអប់រំ

# លិខិតឧទ្ទេសនាមគណៈកម្មការវាយតម្លៃការការពារនិក្ខេបបទ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា
លេខ: ៥៣៧៧ អយក.ខទក
(ការសម្ងាត់)

**លិខិតឧទ្ទេសនាម**

យោង ៖ -លិខិតលេខ២៩៥៥ អយក.វជអ ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២០។
-បទប្បញ្ញត្តិស្តីពីការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ នៅវិទ្យាស្ថានជាតិអប់រំ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥។
-ផែនការអនុវត្តកម្មវិធីបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៧ និងទី៨ ឆ្នាំសិក្សា២០១៩-២០២០ ចុះថ្ងៃទី០៨ ខែតុលា ឆ្នាំ២០១៩។

បុគ្គលិកអប់រំ នៃក្រសួងអប់រំ យុវជន និងកីឡា ដូចមានរាយនាមខាងក្រោម ត្រូវបានចាត់តាំងជា **គណៈកម្មការការពារសារណា** ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៧ ដែលនឹងប្រព្រឹត្តទៅពីថ្ងៃទី២៤-២៥ ខែតុលា ឆ្នាំ២០២០ នៅវិទ្យាស្ថានជាតិអប់រំ៖

| | | | |
|---|---|---|---|
| ១-ឯ.ឧបណ្ឌិត | សៀង សុវណ្ណា | វិទ្យាស្ថានជាតិអប់រំ | ប្រធាន |
| ២-ឯកឧត្តមបណ្ឌិត | ម៉ុក សារ៉ុម | អគ្គ.អប់រំ | អនុប្រធាន |
| ៣- ឯកឧត្តម | នៀ សុផន | នាយកដ្ឋានបុគ្គលិក | សមាជិក |
| ៤-លោក | ឌី បុណ្ណា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៥-លោកបណ្ឌិត | នូវ វ៉ា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៦-លោកស្រី | ប៊ុន សុផានី | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៧-លោក | ថៃ ហេង | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៨-លោកបណ្ឌិត | នី រដ្ឋា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៩-លោក | ម៉ន មុនិន្ទ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១០-លោក | ចាប រតនា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១១-លោកបណ្ឌិត | ឈាង សង្វាត | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១២-លោកបណ្ឌិត | អាន វ៉ូប្រាវ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៣-លោកស្រី | នូ ចន្ទី | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៤-លោក | សៀង វាសនា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |

ឯកឧត្តម លោក លោកស្រី ដូចមានរាយនាមខាងលើ ត្រូវអញ្ជើញមកវាយតម្លៃការការពារសារណា របស់និស្សិតពីថ្ងៃទី២៤-២៥ ខែតុលា ឆ្នាំ២០២០ ចាប់ពីម៉ោង៧:៣០នាទីព្រឹកតទៅ នៅវិទ្យាស្ថានជាតិអប់រំ។

ថ្ងៃ ចន្ទ ១៣ កើត ខែ កត្តិក ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ តុលា ឆ្នាំ២០២០
**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន**

**កន្លែងទទួល៖**
-អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ
-ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី
"ដើម្បីជ្រាបជាព័ត៌មាន"
-គ្រប់អង្គភាពក្រោមឱវាទក្រសួងអយក ដែលមានការពាក់ព័ន្ធ
"ដើម្បីជ្រាបជាព័ត៌មាន"
-សាមីខ្លួន "ដើម្បីអនុវត្ត"
-កាលប្បវត្តិ -ឯកសារ វជអ

អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ : www.moeys.gov.kh

# លិខិតថ្លែងអំណរគុណ

ការសិក្សាស្រាវជ្រាវមួយនេះ អាចសម្រេចដល់គោលដៅប្រកបដោយភាពជោគជ័យ គឺ ដោយសារមានការចូលរួមយ៉ាងសកម្មពីគ្រប់មជ្ឈដ្ឋានពាក់ព័ន្ធនានា ដែលបានចូលរួមផ្តល់ឱកាស ជួយសម្របសម្រួល និងជ្រោមជ្រែងតាំងពីដើមរហូតដល់ចប់។ ហេតុនេះខ្ញុំបាទដែលជាអ្នកសិក្សាស្រាវជ្រាវ សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ៖

លោកឪពុក អ្នកម្តាយ ដែលបានផ្តល់កំណើត និងចិញ្ចឹមបីបាច់ថែរក្សា ផ្តល់ដំបូន្មាន ឧបត្ថម្ភ គាំទ្រ និងផ្តល់ឱកាសឱ្យខ្ញុំបានរៀនសូត្រ ទទួលបានផ្លែផ្កាដូចសព្វថ្ងៃនេះ។

លោកឪពុកម្តាយក្មេក និងភរិយាជាទីស្រលាញ់ ដែលតែងតែលើកទឹកចិត្ត និងគាំទ្រដល់ការបន្តការសិក្សារបស់ខ្ញុំ ដោយមិនគិតពីការនឿយហត់។

ក្រសួងអប់រំ យុវជន និងកីឡា និងវិទ្យាស្ថានជាតិអប់រំ ដែលបានរៀបចំថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់សម្រាប់ឱ្យខ្ញុំបាទមានឱកាសបន្តការសិក្សានៅទីនេះ។

គណៈគ្រប់គ្រងការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំនៅវិទ្យស្ថានជាតិអប់រំ ព្រមទាំងលោកសាស្ត្រាចារ្យទាំងអស់ដែលបានចំណាយពេលវេលា បង្ហាត់បង្រៀនដល់ខ្ញុំបាទដោយមិនគិតពីការនឿយហត់។

បណ្ឌិត **អាន វុទ្ធារ៉ាច** ជាសាស្ត្រាចារ្យដឹកនាំបង្គោល ដែលលោកតែងតែឆ្លៀតពេលដ៏មានតម្លៃក្នុងការផ្តល់គំនិតណែនាំជាទ្រឹស្តីល្អៗ កែលម្អចំណុចខ្វះខាត ឃ្លាប្រយោគ អក្ខរាវិរុទ្ធ និងផ្តល់កម្លាំងចិត្តបច្ចេកទេស វិធីសាស្ត្រនានា មិនតែប៉ុណ្ណោះ លោកបណ្ឌិតបានផ្តល់ ជាឯកសារដែលទាក់ទងនឹងប្រធានបទ ព្រមទាំងជួយបង្ហាញទិសដៅដល់រូបខ្ញុំរហូតការសិក្សាស្រាវជ្រាវនេះ ទទួលបានជោគជ័យជាស្ថាពរ។

លោក **ឡុច ចាន់ថន** ជាសាស្ត្រាចារ្យដឹកនាំរង ដែលលោកតែងតែឆ្លៀតពេលដ៏មានតម្លៃក្នុងការកែសម្រួល រចនាបទ ឃ្លាប្រយោគ និងរបៀបសរសេរនិក្ខេបបទ ព្រមទាំងជួយកែសម្រួល កម្រងសំណួរផ្សេងៗដែលទាក់ទងនឹងប្រធានបទ និងការវិភាគទិន្នន័យផងដែរ។

មិត្តរួមថ្នាក់ជំនាន់ ទី៧ ទាំងអស់ដែលតែងតែផ្តល់កម្លាំងចិត្តដល់រូបខ្ញុំបាទ តាមរយៈការចែករំលែក

ចំណេះដឹង បទពិសោធន៍ និងព័ត៌មានទាំងឡាយ ធ្វើឱ្យខ្ញុំបាទមានទឹកចិត្តតស៊ូ និងពុះពាររាល់ការលំបាក និងឧបសគ្គទាំងឡាយដើម្បីសម្រេចគោលដៅនៃការស្រាវជ្រាវសរសេរនិក្ខេបបទនេះ។

គណៈគ្រប់គ្រងសាលា លោកគ្រូ អ្នកគ្រូ និងបុគ្គលិកពាក់ព័ន្ធ ភាគសំណាកទាំងអស់ដែលបានចូលរួមឆ្លើយនូវកម្រងសំណួរ និងសហការក្នុងការផ្តល់ទិន្នន័យធ្វើឱ្យការសិក្សាស្រាវជ្រាវនេះទទួលបានជោគជ័យ។

ជាទីបញ្ចប់នេះខ្ញុំបាទសូមគោរពជូនពរ ដល់អ្នកមានគុណទាំងទ្វេ ព្រមទាំងឯកឧត្តម លោកជំទាវ លោក លោកស្រី ថ្នាក់ដឹកនាំក្រសួងអប់រំ យុវជន និងកីឡា និងឯកឧត្តម លោកជំទាវ លោក លោកស្រី តំណាងអង្គការដៃគូអភិវឌ្ឍ ឯកឧត្តមបណ្ឌិត សាស្ត្រាចារ្យទាំងអស់នៃវិទ្យាស្ថានជាតិអប់រំ សូមជួបប្រទះតែសេចក្តីសុខ សេចក្តីចម្រើនគ្រប់ប្រការ មានសុខភាពល្អបរិបូណ៍ សម្រេចជោគជ័យគ្រប់ភារកិច្ច និងទទួលបាននូវពុទ្ធពរទាំងឡាយ ៤ប្រការគឺៈ អាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

**សូមអរគុណ**!

# មូលន័យសង្ខេប

ការស្រាវជ្រាវមួយនេះមានបំណងស្វែងរក និងបង្ហាញអោយឃើញពីស្ថានភាពជាក់ស្តែងនៃការប្រើប្រាស់សៀវភៅសិក្សាភាសាអង់គ្លេសរបស់គ្រូភាសាអង់គ្លេសនៅកម្រិតអនុវិទ្យាល័យ និងបញ្ហាប្រឈមនានា ពាក់ព័ន្ធទៅនិងការប្រើប្រាស់សៀវភៅសិក្សាភាសាអង់គ្លេសនៅសាលារដ្ឋសព្វថ្ងៃ ជាពិសេសនៅក្នុងខេត្តស្វាយរៀងតែម្តង។

វិធីសាស្ត្រដែលអ្នកសិក្សាស្រាវជ្រាវយកមក ប្រើដើម្បីប្រមូលទិន្នន័យគឺវិធីសាស្ត្របែបបរិមាណវិស័យ(Quantitative Method) និង វិធីសាស្ត្របែបគុណវិស័យ(Qualitative Method)។ក្នុងការសិក្សាស្រាវជ្រាវបែបបរិមាណវិស័យ អ្នកសិក្សាស្រាវជ្រាវបានប្រើប្រាស់នូវកម្រងសំណួរបែបពហុជ្រើសរើសសម្រាប់សួរគ្រូ និងសិស្ស រីឯវិធីបែបគុណវិស័យវិញ អ្នកសិក្សាស្រាវជ្រាវបានចងក្រងជាកម្រងសំណួរបែបសំណួរបើក សម្រាប់សម្ភាសនាយកសាលាដើម្បីងាយទទួលបានព័ត៌មានបន្ថែមសម្រាប់គាំទ្រដល់ចម្លើយមួយចំនួននៅក្នុងកម្រងសំណួរបែបបរិមាណវិស័យ។ ភាគសំណាកដែលបានចូលរួមនៅក្នុងការស្រាវជ្រាវត្រូវបានជ្រើសរើសយកចេញពីវិទ្យាល័យចំនួន ៤ និងអនុវិទ្យាល័យចំនួន ៤ នៅក្នុងស្រុក៥ផ្សេងគ្នា ក្នុងខេត្តស្វាយរៀង(១ នៅក្នុងក្រុងនិង ៤ ទៀតនៅតាមស្រុកនីមួយៗ)។ជាតុសំណាកទាំងអស់មានចំនួន៣២៨នាក់ ដោយក្នុងនោះមាននាយកសាលាចំនួន ៨ នាក់ គ្រូបង្រៀនភាសាអង់គ្លេសចំនួន២០នាក់ និងសិស្សចំនួន ៣០០នាក់។

លទ្ធផលនៃការសិក្សាស្រាវជ្រាវនេះបានបង្ហាញថា ស្ថានភាពជាក់ស្តែងទាក់ទងទៅនឹងការប្រើប្រាស់សៀវភៅភាសាអង់គ្លេស នៅកម្រិតអនុវិទ្យាល័យមានភាពល្អប្រសើរ។ ក្នុងនោះគ្រូរហូតដល់ទៅ ៨០%ដែលមានកំរិតសញ្ញាបត្រគរុកោសល្យត្រឹមត្រូវទៅតាមកម្រិតថ្នាក់ដែលគាត់បង្រៀននិង មាន២០% ទៀតមានសញ្ញាបត្រគ្រូកម្រិតឧត្តម។

ជាងនេះទៅទៀតពួកគាត់សុទ្ធតែជាគ្រូដែលមានបទពិសោធន៍បង្រៀនយូរឆ្នាំ។ ពាក់ព័ន្ធនិងវិធី

សាស្ត្រនៃការបង្រៀនវិញ គឺគ្រូតែងតែឆ្លាស់វិធីសាស្ត្រគ្រប់ពេលដែលគាត់បង្រៀន ដោយម្តងគាត់ប្រើវិធីសាស្ត្រនេះ និងម្តងគាត់ប្រើវិធីសាស្ត្រនោះ។ លើសពីនេះទៅទៀតគ្រូបង្រៀនរហូតដល់ទៅ ៩៥%ដែលតែងតែធ្វើកិច្ចតែងការបង្រៀនទើបគ្រប់មេរៀនដែលគាត់បានបង្រៀន។

ទន្ទឹមនឹងចំណុចវិជ្ជមានខាងលើក្នុងនោះក៏មានចំនុចខ្វះខាតមួយចំនួនដែលជាបញ្ហាប្រឈមទាមទារឱ្យមានដំណោះស្រាយផងដែរ។ បញ្ហាទាំងនោះក៏ដូចជាកង្វះសម្ភារៈទ្រទ្រង់ចាំបាច់សម្រាប់ការប្រើប្រាស់សៀវភៅភាសាអង់គ្លេសមួយចំនួនរួមមានៈម៉ាញ៉េចាក់ស៊ីឌី ប្រដាប់បំពងសម្លេង និងបន្ទប់សម្រាប់ការអនុវត្តន៍ស្តាប់និងមើលវីដេអូ និងបណ្ណាល័យដែលខ្វះសៀវភៅជាភាសាអង់គ្លេសជាដើម។គ្រូបង្រៀនរហូតដល់ទៅ៩០%ដែលពុំទទួលបានការបណ្តុះបណ្តាលវគ្គដែលទាក់ទងទៅនឹងវិធីសាស្ត្រនៃការប្រើប្រាស់សៀវភៅសិក្សាគោល ឬវិធីសាស្ត្របង្រៀនភាសាអង់គ្លេសបន្ថែមដើម្បីបំប៉នសមត្ថភាពក្នុងរយៈពេល ៥ឆ្នាំចុងក្រោយនេះទេ។

ក្រៅពីនេះចំនួនម៉ោងក្នុងការប្រើប្រាស់សៀវភៅភាសាអង់គ្លេស ក៏នៅតែជាបញ្ហាដោយសារសៀវភៅមានមេរៀនច្រើន ហើយម៉ោងបង្រៀនភាសាអង់គ្លេសដែលកំណត់ដោយក្រសួងគឺពុំទាន់សមស្របបាន ១០០%។

ម្យ៉ាងវិញទៀតបញ្ហាខ្វះសៀវភៅសិក្សាសម្រាប់សិស្ស នៅតាមសាលានីមួយៗក៏នៅតែជាបញ្ហាដោយសារតាមសាលាគោលដៅនីមួយៗ សៀវភៅសិក្សាភាសាអង់គ្លេសមិនទាន់គ្រប់គ្រាន់នៅឡើយ។ រីឯសកម្មភាពនៅក្នុងសៀវភៅពុម្ពរបស់សិស្សមានច្រើនជាងលំហាត់អនុវត្ត។

# Abstract

This is a study to investigate and identify the real situation of the using English TextBook in Secondary School and some challenges related to using English TextBook at state school especially in Svay Rieng province. A method employed in collecting data was both quantitative and qualitative. In quantitative method, the researcher organized a multiple-choice questionnaire for both teachers and students and in the qualitative method opened questions were prepared to interview the school principals. The sample comprised 328 people covering 8 school principals, 20 English teachers, and 300 students from 8 different secondary schools (1 in the urban and 4 in the rural areas) located in five different districts in Svay Rieng province.

The result of the study indicates that 80% of English teachers have the right qualifications to teach that class level, and 90% of them have at least bachelor degrees and 10% of them have master degrees. Moreover, those teachers have long experience in teaching English and are well-prepared because 95% of them have prepared the lesson plans almost every time they teach. Besides, the English teachers in those target schools have often changed their teaching methodologies in their teaching to interest the students′ learning and cooperation in the class.

However, there are still some challenges. One of those challenges is that most schools still lack some necessary teaching materials such as CD players, MP3 players, Audio Lab, and English documents( in school libraries). Furthermore, roughly 90%of the

teachers have admitted that have never joined any trainings or workshops related to English textbook using, and teaching methodologies for last 5 years. Based on 10% of Teachers selected for answering the questionnaires, in addition, teaching hours set for English subject at state school are still unsatisfactory. At the same time, lack of English Textbooks in each school is still the problem. Also, the students do not try hard enough In their learning English subject.

# មាតិកា


សេចក្តីអះអាងរបស់បេក្ខជន ..................................................... i

លិខិតបញ្ជាក់..................................................... ii

លិខិតឧទ្ទេសនាមគណៈកម្មការវាយតម្លៃការការពារនិក្ខេបបទ ..................................................... iii

លិខិតថ្លែងអំណរគុណ ..................................................... iii

មូលន័យសង្ខេប..................................................... vi

Abstract .....................................................viii

ជំពូកទី១៖ សេចក្តីផ្តើម.....................................................2

១.១. លំនាំបញ្ហា .....................................................2

១.២. ចំណោទបញ្ហា.....................................................5

១.៣ គោលបំណងនៃការស្រាវជ្រាវ.....................................................5

១.៤. សំណួរស្រាវជ្រាវ.....................................................6

១.៥. សារៈសំខាន់នៃការស្រាវជ្រាវ.....................................................6

១.៦. ដែនកំណត់ និងវិសាលភាពនៃការសិក្សាស្រាវជ្រាវ.....................................................6

១.៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ .....................................................7

ជំពូកទី២៖ រំលឹកទ្រឹស្តី .....................................................9

២.១. និយមន័យពាក្យគន្លឹះ.....................................................9

២.២. គុណសម្បត្តិគ្រូភាសាអង់គ្លេស .....................................................12

២.២.១. ចំណេះដឹងរបស់គ្រូបង្រៀន.....................................................13

២.២.២. វិធីសាស្រ្តបង្រៀនភាសាអង់គ្លេស.....................................................14

២.៣. សម្ភារឧបទេសបង្រៀនភាសាអង់គ្លេស .....................................................15

២.៤. កម្មវិធីសិក្សាភាសាអង់គ្លេស .....................................................16

២.៥. ការលើកទឹកចិត្ត.....................................................19

២.៦. ការរៀបចំមេរៀនឬកិច្ចតែងការបង្រៀន.....................................................20

២.៧. បរិមាណសិស្សក្នុងថ្នាក់ ..... 21
ជំពូកទី៣៖ វិធីសាស្ត្រស្រាវជ្រាវ ..... 23
៣.១. ការប្រមូលទិន្នន័យ ..... 23
៣.២. ទីតាំងនៃការស្រាវជ្រាវ ..... 23
៣.៣. ការជ្រើសរើសសំណាក ..... 24
៣.៤. ឧបករណ៍ស្រាវជ្រាវ ..... 25
៣.៥. ដំណាក់កាលនៃការប្រមូលទិន្នន័យ ..... 27
៣.៦. ការវិភាគទិន្នន័យ ..... 27
៣.៧. ក្រមសីលធម៌នៃការស្រាវជ្រាវ ..... 28
ជំពូកទី៤៖ លទ្ធផល និងការពិភាក្សា ..... 30
៤.១. អ្នកចូលរួម និងព័ត៌មានទូទៅ ..... 30
៤.២. គុណវុឌ្ឍិគ្រូបង្រៀនភាសាអង់គ្លេស ..... 30
៤.២.១. កម្រិតជំនាញគរុកោសល្យរបស់គ្រូភាសាអង់គ្លេស ..... 30
៤.២.២. កម្រិតសញ្ញាបត្ររបស់គ្រូភាសាអង់គ្លេស ..... 31
៤.២.៣. បទពិសោធន៍បង្រៀនរបស់គ្រូភាសាអង់គ្លេស ..... 32
៤.២.៤. ការទទួលបានការបណ្ដុះបណ្ដាលបន្ថែម៥ឆ្នាំចុងក្រោយរបស់គ្រូ ..... 33
៤.២.៥. អត្ថប្រយោជន៍នៃការបណ្ដុះបណ្ដាលបន្ថែម ..... 34
៤.២.៦. ចំណាប់អារម្មណ៍គ្រូលើវគ្គបណ្ដុះបណ្ដាលបន្ថែម ..... 34
៤.៣. កម្មវិធីសិក្សាភាសាអង់គ្លេស ..... 36
៤.៣.១. បំណែងចែកកម្មវិធីសិក្សាភាសាអង់គ្លេស ..... 36
៤.៣.២. ខ្លឹមសារក្នុងសៀវភៅសិក្សាគោល ..... 37
៤.៣.៣.ចំណាប់អារម្មណ៍របស់សិស្សទាក់ទងនិងខ្លឹមសារមេរៀនក្នុងសៀវភៅ ..... 38
៤.៣.៤. ចំនួនម៉ោងសិក្សាធៀបនិងចំនួនមេរៀន ..... 39
៤.៣.៥. ចំនួនម៉ោងសិក្សាភាសាអង់គ្លេសក្នុង១សប្ដាហ៍ ..... 39

៤.៤. សម្ភារឧបទេសសម្រាប់ទ្រទ្រង់ការប្រើប្រាស់សៀវភៅសិក្សា 40
៤.៥. សារៈប្រយោជន៍នៃការប្រើប្រាស់សម្ភារបង្រៀនរបស់គ្រូ 42
៤.៦. វិធីសាស្ត្របង្រៀនភាសាអង់គ្លេស 42
៤.៦.១. សកម្មភាពប្រើប្រាស់សៀវភៅសិក្សាក្នុងថ្នាក់ 42
៤.៦.២. ការផ្តល់កិច្ចការផ្ទះ 43
៤.៦.៣. ការលើកទឹកចិត្ត 44
៤.៧. ការរៀបចំកិច្ចតែងការបង្រៀន 45
៤.៨. បរិមាណសិស្សក្នុងថ្នាក់រៀន 46
៤.៨.១. ចំនួនសិស្សក្នុង១ថ្នាក់ 46
៤.៨.២. ឥទ្ធិពលអវិជ្ជមាននៃឥទ្ធិពលអវិជ្ជមាននៃចំនួនសិស្សច្រើនក្នុងមួយថ្នាក់ 47
៤.៩. ស្ថានភាពសិក្សារបស់សិស្ស 48
ជំពូកទី៥៖ សេចក្តីសន្និដ្ឋាន និង សំណូមពរ 51
៥.១. សេចក្តីសន្និដ្ឋាន 51
៥.២. សំណូមពរ 53
ក. ក្រសួងអប់រំ យុវជន និងកីឡា 53
ខ. មន្ទីរអប់រំ យុវជន និងកីឡា 54
គ. គណៈគ្រប់គ្រងសាលារៀន 54
ឃ. ចំពោះលោកគ្រូ អ្នកគ្រូ 54
ង. ចំពោះសិស្សានុសិស្ស 55
៥.៣. ការស្រាវជ្រាវបន្ត 55
ឯកសារយោង 57
ឧបសម្ព័ន្ធទី១ 62
កម្រងសំណួរសម្រាប់នាយក 62

កម្រងសំណួរសម្រាប់គ្រូ......65
កម្រងសំណួរសម្រាប់សិស្ស......69
ឧបសម្ព័ន្ធទី២៖ លិខិតឧទ្ទេសនាម និងឯកសារពាក់ព័ន្ធ......72

# ជំពូកទី១

# សេចក្តីផ្តើម

# ជំពូកទី១

# សេចក្តីផ្តើម

## ១.១. លំនាំបញ្ហា

ភាសាអង់គ្លេសគឺជាភាសាយានដែលពិភពលោកបានប្រើអស់រយៈពេលជាងមួយសតវត្សរ៍ ហើយត្រូវបានគេទទួលស្គាល់នៅក្នុងប្រទេសជាច្រើនជុំវិញពិភពលោកផងដែរ។ ដូចគ្នានេះភាសាអង់គ្លេស នឹងបន្តដើរតួនាទីនាំមុខគេនាពេលអនាគត (Crystalឆ្នាំ ២០០៣) ។ វាមិនអាចទៅរួចទេដែលមិនអើពើនឹងឥទ្ធិពលរបស់វានៅក្នុងផ្នែកណាមួយនៃពិភពលោកហើយភាសាអង់គ្លេសតំណាងឱ្យការវិវត្តនៃសាកលភាវូបនីយកម្ម។ លើសពីនេះទៀតការបង្រៀនភាសាអង់គ្លេសគឺជាមធ្យោបាយនៃការឃោសនាមិនត្រឹមតែភាសាអង់គ្លេសប៉ុណ្ណោះទេ ប៉ុន្តែក៏ជាសាកលភាវូបនីយកម្មដែលភាសានេះជានិមិត្តរូបផងដែរ (Igawa ឆ្នាំ ២០១០) ។អ្វីដែលសំខាន់ជាងនេះទៀតចំពោះការអភិវឌ្ឍន៍យ៉ាងឆាប់រហ័សនៃរបៀបរស់នៅពិភពលោកតែមួយគឺការរីកសាយនៃភាសាអង់គ្លេស។ ភាសាគឺជាភ្នាក់ងារដ៏អស្ចារ្យនៃភាពដូចគ្នា។ ប្រសិនបើភាសាអង់គ្លេសកំពុងតែទទួលជោគជ័យលើភាសាសកលផលប៉ះពាល់គឺច្បាស់ណាស់៖ វប្បធម៌និងវិស័យផ្សេងទៀតនៃប្រទេសនិយាយភាសាអង់គ្លេសនឹងគ្របដណ្តប់លើវិស័យដូចជារចនាបថ អគារ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ មធ្យោបាយទំនាក់ទំនង និងមធ្យោបាយដឹកជញ្ជូនសូម្បីតែរចនាសម្ព័ន្ធរដ្ឋាភិបាលនិងវិធីនៃកាអនុវត្តនិង សូម្បីតែមនោគមវិជ្ជា (, ១៩៩០) ។GraddoNaisbitt & Aburdenel(២០០០)ថែងថា" គ្មានភាសាណាមួយនិងកាន់កាប់ជំហរផ្តាច់មុខក្នុងសតវត្សរ៍ទី ២១ដែលស្ទើរតែសម្រេចបាននៅចុងសតវត្សរ៍ទី ២០ ទេ" (ទំព័រ ៥៩) ។Crystal (ឆ្នាំ ១៩៩៧) បានលើកឡើងថា" ភាសាមួយក្លាយជាភាសាអន្តរជាតិសម្រាប់គ្រូបង្រៀនភាសាអង់គ្លេសគឺជាមនុស្សសំខាន់នៃដំណើរការសាកលភាវូបនីយកម្មនេះ និងជាអ្នកផ្តល់ផលប៉ះពាល់ដែលសាកលភាវូបនីយកម្មលើសេដ្ឋកិច្ច ឱកាសការងារការវិនិយោគវិទ្យាសាស្ត្របច្ចេកវិទ្យាព័ត៌មាននិងទំនាក់ទំនងអន្តរជាតិ។ ជាពិសេសអ្នកដែលបង្រៀនភាសាអង់គ្លេសជាភាសាបរទេសនៅក្នុងប្រទេសដែលមិននិយាយភាសាអង់គ្លេសគឺជាអ្នកទទួលនូវសាកលភាវូបនីយកម្មនិងផលប៉ះពាល់របស់

វាផងដែរ (Capella, ២០០០ ហេតុផលចំបងមួយគឺអំណាចនយោបាយរបស់ប្រជាជនរបស់ខ្លួនជាពិសេសយោធារបស់ពួកគេ" (ទំព័រ ៧)។ ដោយមើលឃើញពីសក្តានុពលពីភាសាអង់គ្លេសរាជរដ្ឋាភិបាលកម្ពុជា បាននិងកំពុងកែប្រែធ្វើទំនើបកម្មរចនាសម្ព័ន្ធឧស្សាហកម្មកម្ពុជា ពីអតិពលកម្មឈានទៅឧស្សាហកម្មជំនាញឆ្នាំ២០២៥ តាមរយៈការតភ្ជាប់ខ្សែសង្វាក់តម្លៃសកល សមាហរណកម្មទៅក្នុងបណ្តាញផលិតកម្មតំបន់ និងការអភិវឌ្ឍកន្សោមផលិតកម្មប្រទាក់ក្រឡា ទន្ទឹមនិងការពង្រឹងការប្រកួតប្រជែងនិងការលើកកម្ពស់ផលិតផលក្នុងស្រុក ហើយឈានបន្តអភិវឌ្ឍទៅជាឧស្សាហកម្មទំនើបដោយផ្អែកលើមូលដ្ឋានបច្ចេកវិទ្យាព័ត៌មានវិទ្យា និងចំណេះដឹងភាសាអង់គ្លេស(CIDP,២០១៥)។មកដល់សម័យកាលភាវូបនីយកម្ម ភាសាអង់គ្លេសក៏បានដើរតួនាទីសំខាន់ក្នុងការចូលរួមចំណែកក្នុងការអប់រំ និងការអភិវឌ្ឍសេដ្ឋកិច្ចផងដែរ ពីព្រោះវាត្រូវបានចាត់ទុកថាជាភាសារដ្ឋចំណេះដឹងទេសចរណ៍ ឱកាសការងារ និងទំនាក់ទំនងជាអន្តរជាតិ (Crystal,១៩៩៧&Hywei Coleman,២០១០)។ ភាសាអង់គ្លេស គឺត្រូវបានគេប្រើសម្រាប់ទំនាក់ទំនងជាសកលជាពិសេសនៅក្នុងការធ្វើការជំនួញជាមួយបរទេស ហើយ"ការសិក្សាភាសាអង់គ្លេសជាការសិក្សាបំណិនជីវិតដែលមានសារៈប្រយោជន៍សម្រាប់ការរីកចម្រើន នៅក្នុងប្រទេសនាពេលអនាគត"(Igawa,២០០៨)។ ដើម្បីឆ្លើយតបទៅនឹងនិន្នាការពិភពលោកដែលកំពុងផ្តោតការយកចិត្តទុកដាក់លើការលើកកម្ពស់វិស័យអប់រំនោះ សមាគមន៍អាស៊ាននិងប្រទេសកម្ពុជាផងដែរក៏បានកំណត់ចក្ខុវិស័យរបស់ខ្លួនដោយជំរុញប្រទេសនីមួយៗនៅក្នុងតំបន់ដែលជាសមជិក អោយខិតខំធ្វើការកំណែទម្រង់លើគ្រប់វិស័យ ដើម្បីអោយមានកម្រិតស្តង់ដា ប្រហាក់ប្រហែលគ្នារវាងប្រទេសទាំងអស់ តាមរយៈការធ្វើសមាហរណកម្មអាស៊ាននៅឆ្នាំ២០១៥។ ក្នុងនោះដែរវិស័យអប់រំ ជាវិស័យអទិភាពមួយដែលប្រទេសទាំងអស់ក្នុងតំបន់ជាសមជិកត្រូវជានាលើកកម្ពស់គុណភាពអប់រំរបស់ខ្លួនធ្វើយ៉ាងណារៀបចំ ប្រជាពលរដ្ឋរបស់ខ្លួនអោយក្លាយទៅជាធនធានមនុស្សដែលប្រកបដោយចំណេះដឹង ជំនាញឯកទេស និងក្លាយជាកម្មករជំនាញ។ ទន្ទឹមនិងនេះដែរ ចំណេះដឹងភាសាអង់គ្លេស ក៏ត្រូវបានគេចាត់ទុកជាចំណេះដឹងដ៏សំខាន់នៅក្នុងការអភិវឌ្ឍវិស័យអប់រំ សេដ្ឋកិច្ចនយោបាយ និងការអភិវឌ្ឍនានាផងដែរ។ នៅក្នុងឆ្នាំ២០០៧ សមាគមន៍អាស៊ានក៏បានសម្រេចជ្រើសរើសយកភាសាអង់គ្លេសជាភាសាសម្រាប់ប្រើប្រាស់ជាផ្លូវការក្នុង

ការទំនាក់ទំនងនៅក្នុងសមាគមន៏ និងជំរុញអោយប្រទេសទាំងអស់ដែលជាសមាជិកត្រូវបញ្ចូលភាសាអង់គ្លេសជាមុខវិជ្ជាចម្បងទៅក្នុងកម្មវិធីសិក្សារបស់ប្រទេសនីមួយៗ(Clayton, 2007)(Minh, 2013)។ ប្រទេសមួយចំនួនដែលប្រើប្រាស់ភាសាអង់គ្លេស ជាភាសាអន្តរជាតិមានដូចជា កម្ពុជា វៀតណាម ឡាវ ថៃ និងភូមា បានបង្ហាញក្តីព្រួយបារម្មណ៏ ពីការឃ្លាតឆ្ងាយនៃចំណេះដឹងភាសាអង់គ្លេស បើប្រៀបធៀបជាមួយប្រទេសក្នុងតំបន់។ ហេតុនេះហើយបានជាប្រទេសទាំងនោះបានផ្តួចផ្តើមគំនិតដើម្បីជំរុញប្រជាពលរដ្ឋរបស់ខ្លួនអោយពង្រឹងសមត្ថភាពចំណេះដឹងភាសាអង់គ្លេស ក្នុងនោះប្រទេសថៃ និង កម្ពុជា បានចាប់ផ្តើមអោយនិស្សិតនៅសាកលវិទ្យាល័យដែលចាប់យកជំនាញបដិសណ្ឋារកិច្ច និងទេសចរណ៏រៀនជាភាសាអង់គ្លេស(Nuangpolmak, 2017)។ដោយផ្អែកលើបរិបទពិភពលោក និងប្រទេសក្នុងតំបន់ដែលផ្តោតការយកចិត្តទុកដាក់ចំពោះវិស័យអប់រំ រាជរដ្ឋាភិបាលកម្ពុជានៅអាណត្តិទី៥ បានផ្តល់អទិភាពទៅលើការអភិវឌ្ឍធនធានមនុស្សទៅក្នុងយុទ្ធសាស្រ្តចតុកោណរបស់ខ្លួន ក៏ព្រោះតែកម្ពុជាមានមហិច្ឆតាចង់ប្រែក្លាយខ្លួនអោយទៅជាប្រទេសមានចំណូលកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងឈានទៅជាប្រទេសដែលមានកម្រិតខ្ពស់នៅឆ្នាំ២០៥០ (យុទ្ធសាស្រ្តចតុកោណដើម្បីកំណើនការងារសមធម៌ និងប្រសិទ្ធភាពនៅកម្ពុជាដំណាក់កាលទី៣ ឆ្នាំ២០១៣)។ដើម្បីសម្រេចចក្ខុវិស័យរបស់រាជរដ្ឋាភិបាលក្រសួងអប់រំ យុវជននិងកីឡា បានចាប់ផ្តើមធ្វើកំណែទម្រង់វិស័យអប់រំ ដោយដាក់ចេញនូវផែនការយុទ្ធសាស្រ្តវិស័យអប់រំ រយៈពេល៥ឆ្នាំ និងផ្តោតសំខាន់លើការអភិវឌ្ឍធនធានមនុស្ស ដើម្បីធ្វើការប្រកួតប្រជែងទីផ្សារពលកម្មការងារក្នុងតំបន់ ដោយពង្រឹងគុណភាពអប់រំ លើកកម្ពស់ការស្រាវជ្រាវវិទ្យាសាស្រ្ត បច្ចេកទេស និងនវានុវត្តន៏(ណារុន,២០១៤)។ ស្របពេលជាមួយគ្នានេះដែរក្រសួងបានដាក់ចេញនូវផែនការសកម្មភាពគោលនយោបាយស្តីពីគ្រូបង្រៀន កម្មវិសិក្សា និងសៀវភៅសិក្សាគោលដែលជាកំណែទម្រង់យ៉ាងម៉ត់ចត់ និងមានលក្ខណៈជាប្រព័ន្ធដោយបានបង្កើតឡើងដើម្បីបង្កើនគុណភាពអប់រំទូទាំងប្រទេស ។ដើម្បីអោយគុណភាពអប់រំកាន់តែប្រសើរ យើងត្រូវផ្តោតការយកចិត្តទុកដាក់លើការសិក្សាភាសាបរទេស ជាពិសេសភាសាអង់គ្លេសដែលជាហេតុធ្វើអោយក្រសួងអប់រំ យុវជននិងកីឡាបានអោយសិស្សានុសិស្សសិក្សាភាសាអង់គ្លេសចាប់ពីថ្នាក់ទី៤ នៅបឋមសិក្សា(ណារុន,២០១៤)។

## ១.២. ចំណោទបញ្ហា

បន្ទាប់ពីការធ្វើកំណែទម្រង់របស់ក្រសួងអប់រំ យុវជននិងកីឡា ទៅលើចំណុចអាទិភាពទាំង១៥ចំណុច និងសរសេរស្តម្ភទាំង៥ ជាពិសេសកម្មវិធីសិក្សា សៀវភៅសិក្សាគោល និងការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ដើម្បីធ្វើអោយគុណភាពអប់រំ បានប្រសើរឡើងរួចមក យើងឃើញថាថាសិស្សភាគច្រើន បានយកចិត្តទុកដាក់រៀនសូត្រគួរអោយកត់សម្គាល់។ការលើកឡើងនេះគឺផ្អែកលើលទ្ធផលការប្រឡងមធ្យមសិក្សាទុតិយភូមិដែលមានអត្រាសិស្សជាប់ពី៤៤% នៅឆ្នាំ២០១៤ ទៅ៥៥,៨៨%នៅឆ្នាំ២០១៥ និង ៦២,២%នៅឆ្នាំ២០១៦ទៅ៦៥%នៅឆ្នាំ២០១៧ និង២០១៨ និង៦៨,៦២%នៅឆ្នាំ២០១៩។ទោះជាលទ្ធផលប្រឡងសញ្ញាបត្រមានការកើនឡើងជាលំដាប់ ក៏មុខវិជ្ជាភាសាអង់គ្លេសនៅមានកម្រិតនៅឡើយ ពោលគឺមិនឆ្លើយតបតាមការចង់បានរបស់លោកគ្រូ អ្នកគ្រូ ក៏ដូចជាក្រសួងអប់រំយុវជននិងកីឡានៅឡើយ។ លទ្ធផលនេះបង្ហាញថា កម្មវិធីសិក្សានិងការប្រើប្រាស់សៀវភៅសិក្សាគោលរបស់សិស្សនៅមធ្យមសិក្សា នៅមានចំណុចខ្វះខាតនៅឡើយ។ កត្តាមួយចំនួនគឺអាចចាប់ផ្តើមតាំងពីមធ្យមសិក្សាបឋមភូមិក៏មានដែរ ដែលជាហេតុបន្តរហូតទៅដល់មធ្យមសិក្សាទុតិយភូមិ។ ក្រៅពីនេះទៀតតាមការសង្កេតពិភាក្សា និងសម្ភាសន៍របស់អ្នកស្រាវជ្រាវជាមួយគណៈគ្រប់គ្រងសាលាលោកគ្រូ អ្នកគ្រូបង្រៀនភាសាអង់គ្លេសនៅកម្រិតអនុវិទ្យាល័យផ្ទាល់ ឃើញថាសិស្សនៅកម្រិតថ្នាក់នេះ មិនសូវខិតខំរៀនសូត្រ និងប្រើប្រាស់សៀវភៅសិក្សាគោលអោយបានក្លាំងក្លានៅឡើយទេនៅតាមសាលារដ្ឋ។

## ១៣. គោលបំណងនៃការស្រាវជ្រាវ

ដោយសារមានចម្ងល់ពាក់ព័ន្ធនឹងគុណភាពនៃការប្រើប្រាស់សៀវភៅសិក្សាភាសាអង់គ្លេសនៅសាលារដ្ឋនាពេលបច្ចុប្បន្ននេះហើយ ទើបធ្វើអោយអ្នកសិក្សាស្រាវជ្រាវសម្រេចចិត្តជ្រើសរើសយកបញ្ហានេះមកធ្វើជាប្រធានបទស្រាវជ្រាវ ដើម្បីបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់របស់ខ្លួន។ការសិក្សាស្រាវជ្រាវនេះមានគោលបំណងសំខាន់ៗពីរគឺៈ

១.រកឱ្យឃើញនូវស្ថានភាពជាក់ស្តែង នៃការប្រើប្រាស់សៀវភៅសិក្សាភាសាអង់គ្លេស នៅតាមសាលារដ្ឋ។

២.រកឱ្យឃើញកត្តាជះឥទ្ធិពលដល់ គុណភាពនៃការសៀវភៅសិក្សាភាសាអង់គ្លេសនៅអនុវិទ្យាល័យនាពេលបច្ចុប្បន្ន។

## ១.៤. សំណួរស្រាវជ្រាវ

ដើម្បីឆ្លើយតបទៅនិងគោលបំណងខាងលើ អ្នកសិក្សាស្រាវជ្រាវបានលើកយកនូវសំណួរស្រាវជ្រាវចំនួនពីរគឺៈ

១. តើស្ថានភាពនៃការប្រើប្រាស់សៀវភៅសិក្សាភាសាអង់គ្លេស នៅកម្រិតអនុវិទ្យាល័យប្រព្រឹត្តទៅយ៉ាងដូចម្តេច?

២. តើកត្តាអ្វីខ្លះ ដែលជះឥទ្ធិពលដល់គុណភាព នៃការប្រើប្រាស់ក្នុងសៀវភៅសិក្សាភាសាអង់គ្លេសនៅអនុវិទ្យាល័យនាពេលបច្ចុប្បន្ន?

## ១.៥. សារៈសំខាន់នៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះមានសារៈសំខាន់ណាស់ពីព្រោះវានឹងបង្ហាញអោយឃើញនូវបញ្ហាប្រឈមមួយចំនួនសម្រាប់ជួយដល់គ្រូក្នុងការដោះស្រាយអោយទាន់ពេលវេលា និងកែលម្អគុណភាព ប្រសិទ្ធភាពនៃការប្រើប្រាស់សៀវភៅសិក្សាភាសាអង់គ្លេស ដើម្បីចូលរួមចំណែកជាមួយរាជរដ្ឋាភិបាលក្នុងការដោះស្រាយ និងបន្តពង្រឹងវិស័យអប់រំរបស់រដ្ឋអោយរឹតតែមានប្រសិទ្ធភាពខ្ពស់ជាងបច្ចុប្បន្ននេះទៀត។ ការស្រាវជ្រាវនេះនឹងផ្តល់ជារបកគំហើញថ្មីមួយសម្រាប់ចូលរួមវិភាគទានដល់អ្នកសិក្សាជំនាន់ក្រោយៗធ្វើការស្រាវជ្រាវបន្តទៅទៀតទៅលើប្រធានបទនេះ។

## ១.៦. ដែនកំណត់ និងវិសាលភាពនៃការសិក្សាស្រាវជ្រាវ

អ្នកសិក្សាស្រាវជ្រាវបានសម្រេចជ្រើសរើសយកខេត្តស្វាយរៀង សម្រាប់ធ្វើការស្រាវជ្រាវនេះពីព្រោះខេត្តនេះមិនទាន់មានការរីកចម្រើនខ្លាំងទាំងផ្នែកសេដ្ឋកិច្ច ការអប់រំ និងទីផ្សារការងារក៏នៅកម្រិត ដូច្នេះការប្រើប្រាស់សៀវភៅសិក្សាភាសាអង់គ្លេសនៅក្នុងតំបន់នេះ ពិតមានសារៈសំខាន់ណាស់សម្រាប់ជួយលើកកម្ពស់ជីវភាព និងផលិតកម្លាំងពលកម្មអោយឆ្លើយតបទៅនឹងតម្រូវការទីផ្សារការងារ។ ដើម្បីអោយការសិក្សាស្រាវជ្រាវនេះមានតម្លៃ និងស៊ីជម្រៅគ្រប់ជ្រុងជ្រោយ អ្នកសិក្សាស្រាវជ្រាវជ្រើសរើសយក

នាយក នាយិកា គ្រូបង្រៀនមុខវិជ្ជាភាសាអង់គ្លេស និងសិស្សរៀនថ្នាក់ទី ៧ ៨ ៩ ចេញពីអនុវិទ្យាល័យចំនួន៨ ក្នុងខេត្តស្វាយរៀងតែប៉ុណ្ណោះ((១) អនុវិទ្យាល័យនៅក្នុងក្រុងស្វាយរៀងចំនួន១ (២) អនុវិទ្យាល័យនៅទីប្រជុំជនគឺស្រុកស្វាយជ្រំចំនួន៣ (៣) អនុវិទ្យាល័យ នៅតំបន់ដាច់ស្រយាលគឺនៅស្រុកចន្ទ្រាចំនួន៣)មកធ្វើជាសំណាកក្នុងការស្រាវជ្រាវ។ ក្នុងនោះសិស្សចំនួន៣០០នាក់ និងគ្រូ២០នាក់និងត្រូវជ្រើសរើសអោយបំពេញកម្រងសំណួរដាច់ដោយឡែកពីគ្នា ដែលរៀបចំឡើងដោយអ្នកសិក្សាស្រាវជ្រាវ។ ក្រៅពីនេះលោកនាយក/នាយិកា ចំនួន៨រូបទៀតនៃអនុវិទ្យាល័យនីមួយៗ នឹងត្រូវបានអញ្ជើញអោយបំពេញកម្រងសំណួរ ឆ្លើយជាសំណួរទម្រង់បើក និងឆ្លើយតាមរយៈការសម្ភាសន៍ផ្ទាល់មាត់បន្ថែមទៀត។

## ១.៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះត្រូវបានបែងចែកជា ៥ ជំពូកធំៗ

**ជំពូកទី១៖** សេចក្ដីផ្ដើម ក្នុងជំពូកនេះអ្នកសិក្សាស្រាវជ្រាវ និងលើកឡើងពីលំនាំបញ្ហា ចំណោទបញ្ហា សំណួរស្រាវជ្រាវ គោលបំណង ដែនកំណត់ និងវិសាលភាពនៃការសិក្សាស្រាវជ្រាវ។

**ជំពូក២៖** រំលឹកទ្រឹស្ដី នៅក្នុងជំពូកនេះ អ្នកសិក្សាស្រាវជ្រាវបានប្រមូលទ្រឹស្ដីចាស់ៗពីអ្នកសិក្សាស្រាវជ្រាវមុនដែលពាក់ព័ន្ធទៅនិងប្រធានបទនេះ ដើម្បីធ្វើជាគំនិតសំរាប់ធ្វើការស្រាវជ្រាវ និងបង្កើតស្នាដៃថ្មី។

**ជំពូកទី៣៖** វិធីសាស្ត្រស្រាវជ្រាវ ជំពូកនេះអ្នកសិក្សាស្រាវជ្រាវនិងបង្ហាញនូវឧបករណ៍ស្រាវជ្រាវ វិធីសាស្ត្រប្រមូលទិន្នន័យ ជ្រើសរើសគំរូ និងប្រភេទគំរូ ព្រមទាំងវិធីសាស្ត្រក្នុងការវិភាគទិន្នន័យជាដើម។

**ជំពូកទី៤៖** លទ្ធផលនិងការពិភាក្សា នៅក្នុងជំពូកនេះអ្នកសិក្សាស្រាវជ្រាវនិងយកទិន្នន័យដែលប្រមូលបានមកវិភាគ និងបកស្រាយយ៉ាងក្បោះក្បាយដើម្បីរកឱ្យឃើញនូវចំណុចល្អ និងចំណុចដែលត្រូវធ្វើការកែលម្អនៅក្នុងស្ថានភាពជាក់ស្តែងរបស់សាលានីមួយៗ។

**ជំពូកទី៥៖** សេចក្ដីសន្និដ្ឋាននិងសំណូមពរ ជាផ្នែកមួយទៀតដែលអ្នកសិក្សាស្រាវជ្រាវធ្វើការសន្និដ្ឋានទៅលើចំណុចទាំងអស់ ដែលបានយកមកវិភាគព្រមទាំង ផ្តល់ជាសំណូមពរមួយចំនួន ក្នុងគោលបំណងចូលរួមចំណែកធ្វើឱ្យ ស្ថានភាពនៃការប្រើប្រាស់សៀវភៅសិក្សាភាសាអង់គ្លេសនេះ ឱ្យកាន់តែប្រសើរឡើងថែមទៀត។

# ជំពូកទី២

# រំលឹកទ្រឹស្ដី

# ជំពូកទី២

# រំលឹកទ្រឹស្តី

## ២.១. និយមន័យពាក្យគន្លឹះ

**សៀវភៅសិក្សា** ជាអ្វី?

សៀវភៅសិក្សាដើរតួយ៉ាងសំខាន់នៅក្នុងថ្នាក់រៀន នៅគ្រប់ស្ថាប័នអប់រំទាំងអស់ដូចជាសាលារដ្ឋមហាវិទ្យាល័យនិងសាលាភាសានៅទូទាំងពិភពលោក។ ក្នុងបរិបទខ្លះគ្រូមានសិទ្ធិជ្រើសរើសសៀវភៅសិក្សាដោយខ្លួនឯង។ ទោះយ៉ាងណាគ្រូបង្រៀនភាគច្រើនមានសៀវភៅណែនាំដែលបានណែនាំកំណត់ឬប្រគល់ឱ្យពួកគេ (Garinger, ២០០១) ។ យោងតាម Riazi (២០០៣ ទំព័រ ៥២)" សៀវភៅសិក្សាគឺជាឧបករណ៍មួយនៅក្នុងដៃរបស់គ្រូហើយគ្រូត្រូវតែដឹងមិនត្រឹមតែពីរបៀបប្រើវាប៉ុណ្ណោះទេ ប៉ុន្តែវាក៏មានប្រយោជន៍ផងដែរ។ ទ្រព្យសម្បត្តិនៃសម្ភារៈបោះពុម្ពផ្សាយសម្រាប់បង្រៀនភាសាអង់គ្លេស (ELT) ដែលមានលក់នៅលើទីផ្សារធ្វើឱ្យការជ្រើសរើសសៀវភៅសិក្សាត្រឹមត្រូវគឺជាកិច្ចការដែលពិបាក។ លើសពីនេះទៅទៀតការជ្រើសរើសសៀវភៅសិក្សាគោលជាក់លាក់មួយបង្ហាញពីការសម្រេចចិត្តខាងការអប់រំដែលក្នុងនោះមានវិជ្ជាជីវៈហិរញ្ញវត្ថុ និងការវិនិយោគនយោបាយយ៉ាងច្រើនសន្ធឹកសន្ធាប់(Sheldon,១៩៨៨)។ ក្នុងស្ថានភាពខ្លះសៀវភៅសិក្សាដើរតួជាមូលដ្ឋានសម្រាប់អ្នកសិក្សាបញ្ចូលភាសាភាគច្រើនទទួលនិងការអនុវត្តភាសាដែលកើតឡើងនៅក្នុងថ្នាក់រៀន។ ពួកគេអាចផ្តល់ជាមូលដ្ឋានគ្រឹះសម្រាប់ខ្លឹមសារមេរៀនតុល្យភាពជំនាញដែលត្រូវបានបង្រៀននិងប្រភេទកិច្ចការភាសាដែលសិស្សប្រើយ៉ាងសកម្ម។ ក្នុងកាលៈទេសៈផ្សេងទៀតសៀវភៅសិក្សាអាចប្រើជាចម្បងដើម្បីបន្ថែមការបង្រៀនរបស់គ្រូ។ សម្រាប់អ្នកសិក្សាសៀវភៅសិក្សាអាចផ្តល់នូវប្រភពទំនាក់ទំនងសំខាន់ដែលពួកគេមានជាមួយភាសាគោលដៅដោយមិនរាប់បញ្ចូលការបញ្ចូលដែលផ្តល់ដោយគ្រូ។ នៅក្នុងករណីនៃគ្រូថ្មី, សៀវភៅសិក្សាក៏អាចត្រូវបានប្រើជាទម្រង់នៃការបណ្តុះបណ្តាលគ្រូ; នោះគឺពួកគេផ្តល់គំនិតអំពីវិធីរៀបចំផែនការ និងបង្រៀនមេរៀនក៏ដូចជាទ្រង់ទ្រាយដែលគ្រូអាចប្រើបាន។ ភាគច្រើននៃការបង្រៀនភាសាដែលកើតឡើងនៅពាសពេញពិភព

លោកសព្វថ្ងៃនេះមិនអាចកើតឡើងដោយគ្មានការប្រើប្រាស់សៀវភៅពាណិជ្ជកម្មច្រើនទេ។ ការរៀនប្រើសៀវភៅសិក្សាដូច្នេះជាផ្នែកសំខាន់មួយនៃចំណេះដឹងវិជ្ជាជីវៈរបស់គ្រូ (Rechard ២០០៥) ។ Hutchinson និង Torres (ឆ្នាំ ១៩៩៤ ទំព័រ ២៣២) កំណត់វិធី ៤ យ៉ាងដែលសៀវភៅសិក្សាអាចជួយក្នុងការផ្លាស់ប្តូរការអប់រំ៖ ទី១ ជាយានសម្រាប់គ្រូនិងអ្នកបណ្តុះបណ្តាលសិស្ស ទី ២ ពីព្រោះពួកគេផ្តល់ការគាំទ្រនិងការជួយសម្រួលបន្ទុកក្នុងការស្វែងរកវត្ថុធាតុដើម។ ទី៣ដោយការផ្តល់នូវរូបភាពពេញលេញតាមដែលអាចធ្វើទៅបាននៃការផ្លាស់ប្តូរ; និងទី៤តាមរយៈការគាំទ្រផ្នែកចិត្តសាស្ត្រដែលពួកគេផ្តល់អោយគ្រូ។ ទោះជាយ៉ាងណាក៏ដោយការបំពេញគោលដៅទាំងនេះជាពិសេសទីមួយ និងទីបី គឺអាស្រ័យលើវិធីសាស្ត្រនិងគុណភាពនៃសៀវភៅសិក្សា។ សម្ភារអាចមិនត្រូវនិងការបង្រៀនប្រភេទថ្មីដែលត្រូវបានលើកទឹកចិត្តដោយជំនួសមកវិញនូវវិធីសាស្ត្រដែលត្រូវបានអនុវត្តជាទូទៅ។ ម៉្យាងទៀតសម្ភារអាចនិងពិបាកប្រើណាស់ដែលគ្រូមិនអាចអនុវត្តតាមដែលបានគ្រោងទុកធ្វើឱ្យពួកគេងាកទៅរកការអនុវត្តពីមុនរបស់ពួកគេ។ ក្នុងករណីណាក៏ដោយការផ្លាស់ប្តូរសៀវភៅ និងក្លាយជាការកាត់បន្ថយលទ្ធភាពរបស់គ្រូដែលកំពុងសាកល្បងវិធីសាស្ត្រ និងវិធីសាស្ត្រជំនួសថ្មី (Garinger, ២០០១)។សៀវភៅសិក្សាមួយត្រូវបានគេមើលឃើញថាជាយានដែលមិនអាចខ្វះបានសម្រាប់ការទទួលបានភាសាបរទេសដែលសុពលភាពនិងសារៈសំខាន់គឺកម្រនិងត្រូវបានគេលួច។ និស្សិតជាច្រើនដែលធ្វើការជាមួយសៀវភៅវគ្គសិក្សាមានអារម្មណ៍ថាមានសុវត្ថិភាពនិងមានវឌ្ឍនភាពនិងសមិទ្ធិផល។ ហេតុដូច្នេះពួកគេកាន់តែមានទំនុកចិត្តនិងពេញចិត្តព្រោះពួកគេចេះភាសាគោលដៅក្នុងក្របខ័ណ្ឌជាក់លាក់។ លើសពីនេះទៀតសៀវភៅសិក្សាផ្តល់ឱ្យពួកគេនូវឱកាសដើម្បីត្រឡប់មកវិញនិងកែសម្រួលឡើងវិញ។ ពួកគេក៏អាចប្រើសៀវភៅសិក្សាសម្រាប់ការសិក្សាដោយខ្លួនឯងនិងជាឯកសារយោង។ ក្រៅពីនេះសៀវភៅមានរូបភាពល្អដែលបំពាក់ដោយឃ្លាដែលទាក់ទាញភ្នែកនិងរូបភាពឬចំណងជើងដែលគួរឱ្យចាប់អារម្មណ៍គឺល្អសម្រាប់សម្ភារៈថតចម្លងរាប់រយក្បាលដែលគ្រូនិងសិស្សឧស្សាហ៍មើល។យើងអាចធ្វើការវាយតម្លៃសៀវភៅសិក្សាជាដំណាក់កាលដូចខាងក្រោមក្នុងដំណើរការនៃការបង្រៀន និងរៀនភាសាបរទេសដូចខាងក្រោម៖

១. ការជ្រើសរើសសៀវភៅសិក្សា

២. ការវាយតម្លៃសៀវភៅដែលបានប្រើប្រាស់រួចហើយនៅក្នុងកម្មវិធីដើម្បីកំណត់ពីចំណុចខ្លាំងនិងចំណុចខ្សោយរបស់ពួកគេ។

៣. ការវាយតម្លៃសៀវភៅបន្ទាប់ពីវគ្គបណ្តុះបណ្តាលមួយដែលមានគោលបំណងរក្សាទុកធ្វើបច្ចុប្បន្នភាព (Riazi, 2003)។

**ការបង្រៀន** ជាសកម្មភាពសម្របសម្រួលការរៀនរបស់សិស្ស លើកទឹកចិត្តឱ្យចេះរៀនដោយខ្លួនឯង ពង្រឹង និងពង្រីកចំណេះដឹង បទពិសោធន៍ដល់សិស្សគ្រប់រូប។ សកម្មភាពនៃការបង្រៀន រួមមានការពន្យល់ការដាក់ចំណោទ ការសួររកហេតុផល ការសួរសំណួរ ការលើកទឹកចិត្តការតាមដានសាវតារបស់សិស្ស ការប្រឡង ឬការវាយតម្លៃអំពីការរីកចម្រើនរបស់សិស្ស។ល។ ក្រៅពីនេះមាន ចិត្ត គរុកោសល្យ គ្រូបង្រៀនក៏ដូចជាអ្នកដទៃទៀតដែរ ចាំបាច់ត្រូវតែបន្តស្រាវជ្រាវរកអ្វីដែលថ្មីអភិវឌ្ឍន៍សមត្ថភាពវិជ្ជាជីវៈរបស់ខ្លួន និងបង្កើតអ្វីដែលថ្មីពេញមួយជីវិតការងារ(នាយកដ្ឋានអភិវឌ្ឍន៍កម្មវិធីសិក្សា ក្របខណ្ឌកម្មវិធីសិក្សាអប់រំចំណេះទូទៅនិងអប់រំបច្ចេកទេស ២០១៥)។Modern Conceptបានលើកឡើងថា ការបង្រៀនគឺជាបុព្វហេតុដែលជំរុញឱ្យសិស្សខិតខំរៀនសូត្រនិងទទួលបានចំណេះដឹង បទពិសោធន៍និងមធ្យោបាយសម្រាប់ការរស់នៅរបស់ខ្លួនគេជាមួយសង្គមឱ្យសមស្របទៅតាមបំណងប្រាថ្នា ដែលពួកគេចង់បានផងដែរ។ ទិដ្ឋភាពដ៏សំខាន់បំផុតនៃដំណើរការ បង្រៀនគ្រួសារ និងអ្វីដែលពួកគេរៀន (Dr.A.H.Sequeira,2002)។ ការបង្រៀន គឺជាកិច្ចការរបស់គ្រូ ក្នុងការប្រើប្រាស់ចំណេះដឹងរបស់ខ្លួនសម្រាប់អភិវឌ្ឍសមត្ថភាពរបស់សិស្សឱ្យមានភាពល្អប្រសើរ(Thomas F. Green)។ការបង្រៀនគឺជាសកម្មភាពនៃការចែករំលែកការអប់រំដល់អ្នកសិក្សានៅក្នុងថ្នាក់រៀនមួយ(Traditional teaching)។

ការបង្រៀន គឺជាការយកចិត្តទុកដាក់ទៅលើសកម្មភាពរបស់សិស្ស រួមមានសកម្មភាពលេង និងការបង្កើតថ្មីឬបេកគំហើញថ្មី(Paul H.Hirst)។

**ការរៀន** គឺជាទង្វើនៃការទទួលបាននូវអ្វីដែលថ្មី ឬការកែប្រែ និងពង្រឹងចំណេះដឹង អាកប្បកិរិយា បំណិនគុណតម្លៃ ឬចំណង់ចំណូលចិត្តដែលមានស្រាប់ ហើយអាចពាក់ព័ន្ធនិងការសំយោគ ព័ត៌មានប្រទេសផ្សេងៗគ្នាសម្រាប់ការប្រើប្រាស់(នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា ក្របខណ្ឌកម្មវិធីសិក្សាអប់រំ

ចំណេះទូទៅនិងអប់រំបច្ចេកទេស២០១៥)។ការរៀន គឺជាសកម្មភាពរបស់មនុស្សម្នាក់ៗដែលចង់បានចំណេះសម្រាប់យកទៅប្រើប្រាស់ក្នុងជីវភាពរស់នៅរបស់ខ្លួន និងធ្វើយ៉ាងណាឱ្យកាន់តែប្រសើរឡើងពោលគឺធ្វើឱ្យមានការផ្លាស់ប្តូរជីវិតរស់នៅទាំងឥរិយាបថ និងស្មារតី។ ការរៀន គឺជាដំណើរការនៃការទទួលយកនូវអ្វីដែលថ្មី និងអភិវឌ្ឍន៍ទៅលើអ្វីដែលមានស្រាប់ឱ្យកាន់តែមានប្រសិទ្ធភាព ដើម្បីទទួលបានការផ្លាស់ប្តូរទាំងស្រុងដែលឆ្ពោះទៅរកពលរដ្ឋពេញលេញ។ ការរៀន អាចកើតឡើងបានអាស្រ័យទៅលើគម្រោង ឬការវិភាគ នៃការសិក្សាដែលជាគ្រឿងជំរុញឱ្យត្រូវតែមករៀន។ ឥរិយាបទនៃការរៀនរបស់សិស្សក៏អាចឈានទៅដល់ចំណុចទីបញ្ចប់នៃគម្រោងការងារនេះផងដែរ(Three types of Learning, ២០១៥)។

## ២.២. គុណសម្បត្តិគ្រូភាសាអង់គ្លេស

ដើម្បីឱ្យលទ្ធផលនៃការប្រើប្រាស់សៀវភៅសិក្សាគោលទទួលបានគុណភាពល្អ គ្រូបង្រៀនគ្រប់ៗរូបចាំបាច់ត្រូវមានលក្ខណៈសម្បត្តិដូចជា៖ ចិត្តគរុកោសល្យ កម្រិតយល់ដឹងភាសាអង់គ្លេស និងសម្ភារឧបទេស និងវិធីសាស្ត្របង្រៀនជាដើម។ ភារកិច្ចចម្បងរបស់វិធីសាស្ត្របង្រៀន គឺជាការបង្កើនដំណើរការនៃការប្រើប្រាស់សៀវភៅសិក្សា និងបង្រៀនធ្វើយ៉ាងណាឱ្យក្លាយជាអ្នកសម្របសម្រួលស្ទាត់ជំនាញ។ការបង្រៀននេះផ្សារភ្ជាប់ទៅ និងការវិភាគជាបន្តបន្ទាប់អំពីខ្លួនឯង ទទួលយកបទពិសោធន៍របស់គ្រូដទៃ និងស្វែងរកមធ្យោបាយថ្មីៗដើម្បីលើកកម្ពស់ការបង្រៀន។ នៅពេលបង្រៀនគ្រូត្រូវគិតពីគុណសម្បត្តិជាក់លាក់មួយដែលត្រូវផ្តល់ឱ្យសិស្ស។ នោះមានន័យថា វិធីសាស្ត្រនៃការបង្រៀនភាសាអង់គ្លេសដោយប្រើប្រាស់សៀវភៅសិក្សា ត្រូវពិចារណាលើបញ្ហាដែលកើតឡើងដោយភាសាអង់គ្លេសសម្រាប់ដែលត្រូវរៀន (Elena Taralunga TAMURA, vol.48 2006)។ គ្រូបង្រៀនល្អត្រូវមានចំណេះដឹង និងជំនាញវិជ្ជាជីវៈច្បាស់លាស់(Burton,2000)។គ្រូបង្រៀនម្នាក់ដេលទទួលបានជោគជ័យក៏ត្រូវមានចំណេះដឹង យ៉ាងជ្រៅជ្រះ ជំនាញលើឯកទេស និងមានបុគ្គលិកលក្ខណៈល្អ(Cheng-Lying& Andy Curtis,2008)។បើយោងតាមគំនិតខាងលើទាំងអស់នេះ គេអាចនិយាយបានថាគុណសម្បត្តិរបស់គ្រូបង្រៀនល្អ គួរត្រូវបានចែកជា៣ប្រភេទធំៗគឺ៖ ចំណេះដឹង ជំនាញវិជ្ជាជីវៈ និងវិធីសាស្ត្របង្រៀន។

### ២.២.១. ចំណេះដឹងរបស់គ្រូបង្រៀន

ចំណេះដឹងរបស់គ្រូបង្រៀនភាសាអង់គ្លេសនៅប្រទេសកម្ពុជាភាគច្រើននៅមានកម្រិតមធ្យម និង មិនមានសមត្ថភាពខ្ពស់ក្នុងការផ្ទេរចំណេះដឹងឱ្យសិស្សនៅឡើយ។ ដូច្នេះពួកគាត់ចាំបាច់ត្រូវទទួលការ បណ្តុះបណ្តាលបន្ថែម ដើម្បីពង្រឹងសមត្ថភាព ពីព្រោះប្រសិនបើពួកគាត់មានសមត្ថភាព ពួកគាត់និង បង្រៀន និងប្រើប្រាស់សៀវភៅសិក្សា ប្រកបដោយភាពជឿជាក់ និងមានប្រសិទ្ធភាព( Mao, 2013 )។ ដើម្បីឱ្យលទ្ធផលសិក្សារបស់សិស្សប្រសើរឡើង ការអភិវឌ្ឍវិជ្ជាជីវៈគ្រូបង្រៀនជាកត្តាសំខាន់បំផុត ពោលគឺ ធ្វើយ៉ាងណាត្រូវលើកកម្ពស់ចំណេះដឹង និងជំនាញ ព្រមទាំងវិធីសាស្ត្ររបស់គ្រូ។ ការអភិវឌ្ឍវិជ្ជាជីវៈអាច បម្រើឱ្យគោលបំណងជាច្រើនដូចជា ការជួយកែលម្អនូវចំណុចខ្វះខាតទាំងជំនាញ និងចំណេះដឹងរបស់ គ្រូថ្មី ព្រមទាំងធ្វើបច្ចុប្បន្នភាពចំណេះដឹងរបស់គ្រូកំពុងបង្រៀន( Yoon,K,S,Duncan,T.,Lee,S,W,-Y.,Scarloss ,B,& Shapley,K, 2007 )។

ការសិក្សាមួយនៅប្រទេសហូឡង់ក៏បានឱ្យនិយមន័យថា គ្រូបង្រៀនដែលល្អ គឺជាអ្នកបង្ហាត់ បង្ហាញដ៏មានសមត្ថភាព( Beishuizen,2001 )។នៅក្នុងការសិក្សាមួយផ្សេងទៀតធ្វើឡើងដោយGi-Piyo Park &Hyo-Woong Lee,( 2006 )នៅប្រទេសកូរ៉េទៅលើសិស្ស និងគ្រូមុខវិជ្ជាភាសាអង់គ្លេសនៅក្នុង វិទ្យាល័យមួយតាមរយៈការឱ្យពួកគេបំពេញនូវ កម្រងសំណួរដោយបានបញ្ចូលពចំណុចចំពោះការប្រើ ប្រាស់សៀវភៅសិក្សាភាសាអង់គ្លេសឱ្យមានប្រសិទ្ធភាពដូចជា៖ ចំណេះដឹងភាសាអង់គ្លេស គរុកោសល្យ និងជំនាញពាក់ព័ន្ធនឹងសង្គម។ ជាលទ្ធផលរវាងសិស្ស និងគ្រូបានឱ្យតម្លៃទៅលើការប្រើប្រាស់សៀវភៅ សិក្សាផ្សេងគ្នា ដោយគ្រូគិតថាមានចំណេះដឹងភាសាអង់គ្លេសសំខាន់ ចំណែកឯសិស្សវិញគិតថាជំនាញ គរុកោសល្យរបស់គ្រូសំខាន់ជាងក្នុងការផ្ទេរចំណេះដឹង។ យោងតាមEthel &McMeniman គ្រូបង្រៀន ដែលទទួលបានជោគជ័យត្រូវមានចំណេះដឹងមូលដ្ឋានទូលំទូលាយដើម្បីប្រើប្រាស់សៀវភៅសិក្សានៅក្នុង ការបង្រៀនឱ្យទទួលបានលទ្ធផលល្អ។ ជាងនេះទៅទៀត គ្រូបង្រៀនចាំបាច់ត្រូវមានចំណេះដឹងឯកទេស ចំណេះដឹងគរុកោសល្យខ្ពង់ខ្ពស់ផងដែរ( Ethel & McMeniman,M,M., 2000 )។

## ២.២.២. វិធីសាស្រ្តបង្រៀនភាសាអង់គ្លេស

គោលដៅធំបំផុតនៃការបង្រៀន គឺធ្វើឱ្យអ្នកសិក្សាទទួលបានលទ្ធផលល្អ ហើយដើម្បីសម្រេចតាមគោលបំណងនៃការបង្រៀន ត្រូវពឹងផ្អែកជាចម្បងទៅលើវិធីសាស្រ្តបង្រៀន។បើគ្រូប្រើវិធីសាស្រ្តបានសមស្របនោះការបង្រៀនទទួលបានលទ្ធផលល្អ។ យើងដឹងហើយថាពុំមានវិធីសាស្រ្តណាល្អជាងគេនោះទេពោលគឺ វិធីសាស្រ្តណា ក៏វាមានចំណុចល្អរបស់វាដែរ។ អ្វីដែលសំខាន់នៅត្រង់ថា អ្នកប្រើប្រាស់ចេះឆ្នៃប្រឌិតយកមកប្រើប្រាស់ឱ្យបានសមស្របតាមពេលវេលា និងកាលៈទេសៈរបស់ខ្លួន ជាពិសេសគម្បីយកចិត្តទុកដាក់ទៅលើវិធីសាស្រ្តដែលទំនើបមានលក្ខណៈបច្ចុប្បន្នភាព និងប្រសិទ្ធភាព(ថៅ លិន, ២០១១) (Richards, J,Rodgers,2001)បានលើកឡើងថាវិធីសាស្រ្តមួយចំនួនដូចជា៖ ១-វិធីសាស្រ្តបែបទំនាក់ទំនង ជាវិធីសាស្រ្តដែលបង្រៀនឱ្យសិស្សអភិវឌ្ឍសមត្ថភាពទំនាក់ទំនងដោយប្រើភាសាទី២។ ២- វិធីសាស្រ្តរៀនតាមបែបសហការណ៍ ជាវិធីសាស្រ្តដែលសិស្សធ្វើការប្រាស្រ័យទាក់ទងគ្នា និងសហការតាមរយៈការសន្ទនា។ ៣- វិធីសាស្រ្តការបង្រៀនដោយផ្អែកលើខ្លឹមសារក្នុងសៀវភៅសិក្សា សិស្សមានឱកាសរៀនតាមមេរៀននិងប្រធានបទ រាល់សកម្មភាពផ្សេងៗជាច្រើន។ លើសពីនេះទៅទៀត(Celce-Murcia, 2001)ក៏បានបន្ថែមវិធីសាស្រ្តមួយទៀតគឺវិធីសាស្រ្តបែបយល់ដឹងដែលដូចនឹងវិធីសាស្រ្តមួយចំនួនដែរដែលវេយ្យាករណ៍ត្រូវបានបង្រៀនតាមបែបអនុមានរួម។ ជាទូទៅសិស្សជាអ្នកទទួលខុសត្រូវលើការរៀនរបស់ខ្លួន ហើយគ្រូជាមនុស្សមានចំណេះដឹងភាសាអង់គ្លេសគ្រប់គ្រាន់សម្រាប់បង្រៀន។រីឯលោក (Mao, 2013)បានលើកឡើងស្រដៀងគ្នានេះដែរថា គ្រូបង្រៀនភាសាអង់គ្លេសភាគច្រើននៅកម្ពុជាមិនទាន់ច្បាស់ពីនិន្នាការនៃការប្រើប្រាស់វិធីសាស្រ្តបង្រៀនថ្មីៗមួយចំនួនមានដូចជាវិធីសាស្រ្តបង្រៀន និងរៀនតាមបែបទំនាក់ទំនង វិធីសាស្រ្តរៀនដោយឈរលើមូលដ្ឋានការងារ វិធីសាស្រ្តរៀនដោយឈរលើមូលដ្ឋានជាគម្រោង វិធីសាស្រ្តតាមបែបសហការណ៍ជាដើម។ គ្រូបង្រៀនភាសាអង់គ្លេសភាគច្រើនមិនបានអនុវត្តតាមវិធីសាស្រ្តទាំងនេះបានជោគជ័យនៅឡើយ ដូច្នេះពួកគាត់ភាគច្រើនជ្រើសរើសយកវិធីសាស្រ្តនៃការបកប្រែអត្ថបទ និងវេយ្យាករណ៍ដើម្បីបង្រៀនសិស្ស ដែលជាហេតុនាំឱ្យលទ្ធផលនៃការសិក្សារបស់សិស្សមិនគួរជាទីពេញចិត្ត។ ការប្រើប្រាស់វិធីសាស្រ្តនេះបានធ្វើអោយសកម្មភាពរបស់សិស្សមិនសកម្មក្នុងការ

សិក្សានិងពឹងផ្អែកការរៀនរបស់ពួកគាត់ទៅលើគ្រូ និងមិនព្យាយាមសិក្សាស្រាវជ្រាវពង្រីកចំណេះដឹងបន្ថែមដោយខ្លួនឯង។សរុបមក មិនថាវិធីសាស្ត្រមួយណាដែលគ្រូគួរជ្រើសរើសយកមកដើម្បីបង្រៀននោះទេ ប៉ុន្តែត្រូវធានាថាបានជួយឱ្យការបង្រៀនមានគុណភាពពីព្រោះពុំមានវិធីសាស្ត្រមួយណាល្អជាងមួយណានោះទេ អ្វីៗដែលសំខាន់ អ្វីដែលសំខាន់គ្រូត្រូវចេះប្រើវាប្រកបទៅដោយភាពច្នៃប្រឌិត។

## ២.៣. សម្ភារឧបទេសបង្រៀនភាសាអង់គ្លេស

គ្រូបង្រៀនគួរតែជ្រើសរើសសម្ភារឧបទេសសមស្រមតាមវត្ថុបំណងមេរៀន និងរៀបចំផែនការសម្រាប់ដំណើរការសកម្មភាពក្នុងថ្នាក់ដែលអាចឱ្យសិស្សចូលរួមបានគ្រប់គ្នាសម្ភារៈឧបទេសសម្រាប់ការបង្រៀនដើរតួនាទីសំខាន់ណាស់ក្នុងការលើកកម្ពស់ដល់ការប្រើភាសាទំនាក់ទំនងរបស់សិស្ស។ សម្ភារៈឧបទេសទាំងអស់នោះអាចជាសៀវភៅពុម្ពការលេងល្បែងការដើរតួនិងសកម្មភាពផ្សេងៗទៀតដែលគាំទ្រដល់ការបង្រៀន( Richards,2001 )។ ការប្រើសម្ភារៈបង្រៀនមានឥទ្ធិពលលើសកម្មភាពបង្រៀនភាសាបរទេស។ នៅក្នុងការបង្រៀនភាសាអង់គ្លេសគ្រូបង្រៀនអាចប្រើប្រាស់សម្ភារៈឧបទេសសម្រាប់ជាជំនួយដល់ការបង្រៀនដូចជា ម៉ាស៊ីនចាក់ស៊ីឌី ម៉ាស៊ីនចាក់វីដេអូ រូបភាពនិងវត្ថុពិតជាដើម។ គ្រូគួរតែជ្រើសរើសនិងប្រើប្រាស់សម្ភារៈទាំងអស់នោះដោយផ្អែកលើវត្ថុបំណងនៃមេរៀននីមួយៗ( Spatt,M,Pulvemess,A .& Williams,M.,2005 )។ ក្រៅពីនេះពួកគេក៏បានលើកឡើងដែរថាសៀវភៅសិក្សា និងសៀវភៅផ្សេងទៀត ក៏ជាសម្ភារៈឧបទេសយ៉ាងសំខាន់សម្រាប់ដំណើរការបង្រៀនផងដែរ( Grower,2005 )។ ក្ដាខៀនក៏ជាឧបករណ៍ដ៏សំខាន់មួយដែលមិនអាចប្រើបាននៅក្នុងថ្នាក់រៀន។កុំព្យូទ័រក៏ជាសម្ភារៈសំខាន់ក្នុងថ្នាក់ដែរដោយសារសព្វថ្ងៃនេះ ជាមួយបច្ចេកវិទ្យាដែលគេតែងតែប្រើប្រាស់បណ្ដាញអ៊ីនធឺណិតសម្រាប់ធ្វើការទំនាក់ទំនងតាមរយៈអ៊ីមែលនិងប្រព័ន្ធបណ្ដាញសង្គមផ្សេងទៀត។ ថ្មីៗនេះបណ្ដាញទាំងនេះអាចប្រើប្រាស់នៅក្នុងការបង្រៀនភាសាអង់គ្លេសដូចជាការប្រើដើម្បីផលិតសម្ភារៈឧបទេសជាដើម( Celce-Murcia,2001 )។ លោកAbebe និង Davidson ( 2011 )បានលើកឡើងថាសិស្សអាចរៀនពាក្យថ្មីមួយលឿនដោយសារគ្រូបាន ដោយប្រើប្រាស់សម្ភារៈដែលមើលឃើញជំរុញឱ្យសិស្សមានសមត្ថភាព និង

ឱកាសក្នុងការបង្ហាញពីគំនិតនិងអារម្មណ៍របស់ពួកគេ។ ចំណែកMathew,N.G .&Alidmat,A.O.H., 2013)បានទទួលស្គាល់ថា ការប្រើប្រាស់សម្ភារៈសោតទស្សន៍ក្នុងការបង្រៀនភាសាអង់គ្លេស ជួយឱ្យសិស្សមានការរីកចម្រើនទៅលើជំនាញបញ្ចេញសម្លេង និងជំនួយសន្ទនាតាមរយៈការស្តាប់ជនជាតិដើម ការប្រើប្រាស់សម្ភារៈទាំងនេះថែមទាំងជួយឱ្យសកម្មភាពសិស្សនៅក្នុងថ្នាក់កាន់តែគួរឱ្យចាប់អារម្មណ៍និងធ្វើឱ្យសិស្សចាំមេរៀនបានយូរជាងមុន។

## ២.៤. កម្មវិធីសិក្សាភាសាអង់គ្លេស

នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា(2005) បានលើកឡើងថាគុណភាពនៃការអប់រំរងឥទ្ធិពលពីកត្តាជាច្រើនជាពិសេសកម្មវិធីសិក្សាដែលរួមបញ្ចូលទាំងឯកសារពាក់ព័ន្ធក្របខណ្ឌកម្មវិធីសិក្សា កម្មវិធីសិក្សាលំអិត សៀវភៅគ្រូ សៀវភៅសិស្ស សៀវភៅអនុវត្ត សម្ភារៈឧទេស និងសៀវភៅណែនាំស្តីពីការវាយតម្លៃសមត្ថភាពសិស្ស។ ការរៀបចំកម្មវិធីសិក្សាមួយត្រូវគិតឱ្យបានល្អិតល្អន់ទៅលើមុខវិជ្ជា និងកម្រិតថ្នាក់ពីមួយកម្រិតទៅមួយកម្រិតទៀតដើម្បីធានាប្រសិទ្ធភាពការរៀន និងបង្រៀននិងពាក់ព័ន្ធគ្នានៃចំណេះដឹងសម្រាប់ការរស់នៅប្រចាំថ្ងៃ។ ខ្លឹមសារមេរៀននីមួយៗត្រូវតែមានភាពប្រទាក់ក្រឡាគ្នាព្រមទាំងមានភាពរលូនទៅតាមការបែងចែកនៃការអភិវឌ្ឍកម្មវិធីសិក្សាតាមលក្ខណៈវិទ្យាសាស្ត្រដែលកំណត់ច្បាស់លាស់ពីវិជ្ជាសម្បទា បំណិនសម្បទា ចរិយាសម្បទា និងកាយសម្បទាដែលសិស្សត្រូវទទួលបានក្រោយពេលរៀនចប់មេរៀនកម្រិតថ្នាក់ និងកម្រិតសិក្សានីមួយៗ។ ឯកសារដដែលក៏បានបន្តទៀតថា អភិវឌ្ឍកម្មវិធីសិក្សាភាសាអង់គ្លេសត្រូវតែឆ្លើយតបនឹងការផ្លាស់ប្តូរសង្គមនិងការជឿនលឿនផ្នែកវិទ្យាសាស្ត្រ បច្ចេកវិទ្យាក្នុងតំបន់និងលើសកលលោក ពីព្រោះភាសាបរទេសមានសារៈប្រយោជន៍យ៉ាងទូលំទូលាយក្នុងការសិក្សាការទទួលបានការងារ និងការរស់នៅប្រចាំថ្ងៃ។ក្នុងនោះការកំណត់វត្ថុបំណងត្រូវបានធានាឱ្យសិស្សមានសមត្ថភាពទំនាក់ទំនងនៅក្នុងដំណឹងទាំងបួន(ការស្តាប់ ការនិយាយ ការអាននិងការសរសេរ)ព្រមទាំងឱ្យសិស្សក្លាយជាអ្នករៀនពេញមួយជីវិតប្រកបដោយការច្នៃប្រឌិតនិងការជឿជាក់(នាយកដ្ឋានអភិវឌ្ឍន៍កម្មវិធីសិក្សា, 2015)។ ខ្លឹមសារកម្មវិធីសិក្សាដែលល្អ សំខាន់គឺត្រូវធ្វើយ៉ាងណាជួយឱ្យលទ្ធផលការសិក្សារបស់សិស្សបានល្អ ប៉ុន្តែខ្លឹមសារនេះត្រូវបានបំពេញបន្ថែម និងគាំទ្រដោយការអនុវត្តប្រកបដោយ

ប្រសិទ្ធភាព។ កម្មវិធីសិក្សាដែលល្អ មិនត្រឹមតែបង្ហាញពីអ្វីដែលគ្រូគួរបង្រៀនតាមមុខវិជ្ជា និងកម្រិតថ្នាក់ប៉ុណ្ណោះទេ ប៉ុន្តែត្រូវប្រាប់អំពីការបង្រៀន និងវាយតម្លៃ(Stabback,2016)។ កម្មវិធីសិក្សាក្នុងពេលបច្ចុប្បន្នគួរធ្វើយ៉ាងណាឱ្យមានភាពស៊ីជម្រៅប្រសើរជាងការធ្វើឱ្យមានភាពទូលំទូលាយពេកពោលគឺក្នុងកម្មវិធីសិក្សាត្រូវផ្តោតទៅលើចំណុចសំខាន់ៗ និងធ្វើយ៉ាងណាឱ្យមានភាពត្រឹមត្រូវស្របតាមក្បួនកំណត់ និងស្របតាមបរិបទសង្គមបច្ចុប្បន្ន ព្រោះវាជាបញ្ហាចម្បងនៃការអប់រំ។ ម្យ៉ាងវិញទៀតកម្មវិធីសិក្សាត្រូវបញ្ចូលនូវបំណិនសម្រាប់ដោះស្រាយបញ្ហានានាឬបញ្ចូលនូវចំណេះដឹងផ្សេងៗទៀតដែលពាក់ព័ន្ធទៅនិងសង្គមនោះ។ កម្មវិធីសិក្សាគួរដាក់ឱ្យសិស្សរៀនពីលក្ខណៈដោយឡែករបស់មនុស្ស និងធ្វើយ៉ាងណាឱ្យគេចេះឬធ្វើការទំនាក់ទំនងគ្នាដោយភាពតរភាព(Glathor,A,&Jailall,J,2000) សៀវភៅសិក្សាគោលជាតិជាតុដ៏សំខាន់នៃកម្មវិធីសិក្សា ហើយត្រូវបានចាត់ទុកជាឧបករណ៍ដ៏សំខាន់បំផុតនៅក្នុងការបង្រៀន និងរៀន។ ដូចនេះខ្លឹមសារនៅក្នុងសៀវភៅសិក្សាគួរតែមានលក្ខណៈសមស្របទៅតាមកម្រិតសមត្ថភាព និងចំណេះដឹងរបស់សិស្ស។ ការសិក្សារបស់លោក Igawa(2008)បានរកឃើញថា ខ្លឹមសារនៅក្នុងសៀវភៅសិក្សាគោលគួរតែធ្វើអោយមានការចាប់អារម្មណ៍ និងសមស្របសម្រាប់សិស្សគ្រប់កម្រិតសិក្សារបស់សិស្សហើយត្រូវផ្សារភ្ជាប់ជីវិតប្រចាំថ្ងៃក្នុងបរិបទប្រទេសកម្ពុជាផងដែរ។ លើសពីនេះទៅទៀតសៀវភៅសិក្សាគោលរបស់ក្រសួងអប់រំ យុវជន និងកីឡា ហាក់មានអត្ថបទអានច្រើនជាងសកម្មភាពផ្សេង។

កម្មវិធីសិក្សាភាសាអង់គ្លេសនៅប្រទេសកម្ពុជាត្រូវបានឆ្លងកាត់ការកែលំអជាច្រើនដំណាក់កាលដោយចាប់ផ្តើមដាក់ឱ្យសិស្សរៀនជាផ្លូវការនៅឆ្នាំ 1989 ប៉ុន្តែការអប់រំភាសាអង់គ្លេសនាពេលនោះមានភាពខ្វះខាតច្រើន។ យោងតាមការសិក្សារបស់លោកMao(2005)ការអប់រំភាសាអង់គ្លេសនៅពេលនោះមិនទាន់មានកម្មវិធីសិក្សា សៀវភៅសិក្សាគោល និងការបណ្តុះបណ្តាលគ្រូឱ្យបានច្បាស់លាស់ទេ។ ប៉ុន្តែដោយមានការខិតខំប្រឹងប្រែងជាបន្តបន្ទាប់ពីអ្នកទាំងពាក់ព័ន្ធជាពិសេសក្រសួងអប់រំ យុវជន និងកីឡា ការអប់រំភាសាអង់គ្លេសសម្រេចបានអភិវឌ្ឍជាបន្តបន្ទាប់។ ជាក់ស្តែងនៅឆ្នាំ 2016 សៀវភៅសិក្សាគោលភាសាអង់គ្លេសមួយមានចំណងជើងថា"The Cambodia English Course"ត្រូវបានចងក្រងនិងបោះពុម្ពឱ្យប្រើប្រាស់សម្រាប់ថ្នាក់ទី៧ នៅក្នុងកម្រិតមធ្យមសិក្សាបឋមភូមិ។ កម្មវិធីសិក្សាភាសាអង់គ្លេសលម្អិត

សម្រាប់មធ្យមសិក្សាត្រូវបានរៀបចំឡើងក្នុងគោលបំណងដើម្បីសម្រួលបន្ថែមលើវិធីសាស្ត្រ និងការរៀបចំកិច្ចតែងការបង្រៀនរបស់គ្រូ(ក្រសួងអប់រំ យុវជន និងកីឡា១៩៩៦ និង ឯ.ឌ ហាង់ ជួនណារ៉ុន ២០១៦) ផ្អែកលើឯកសារខាងលើភាសាអង់គ្លេសត្រូវបានដាក់ឱ្យបង្រៀនចំនួន ៣៦ សប្តាហ៍ក្នុងមួយឆ្នាំសិក្សា ដែលក្នុងមួយសប្តាហ៍ត្រូវបង្រៀន ៥ ម៉ោងសម្រាប់មធ្យមសិក្សាបឋមភូមិ។ ក្រោយមកទៀតកម្មវិធីសិក្សាលម្អិតមុខវិជ្ជាភាសាអង់គ្លេសស្រដៀងគ្នាត្រូវបានរៀបចំសម្រាប់ថ្នាក់ទី ១០ ទី១១ និងទី ១២ ប៉ុន្តែម៉ោងសិក្សាសម្រាប់ភាសាអង់គ្លេសបានយកមកត្រឹមតែ៤ម៉ោងវិញ(យោងតាមសេចក្តីណែនាំស្តីពីការបង្រៀនភាសាអង់គ្លេសនៅមធ្យមសិក្សា លេខ២៩៨៨ អយក.សណន ចុះថ្ងៃទី០៧ខែតុលាឆ្នាំ ១៩៩៩)។ ក្រោយមកទៀត ដោយមានជំនួយពីដៃគូអភិវឌ្ឍន៍នានា ក្រសួងអប់រំ យុវជននិងកីឡា បានបន្តរៀបចំកម្មវិធីសិក្សាភាសាអង់គ្លេស និងសៀវភៅសិក្សាគោលគ្រប់កម្រិត។ ជាលទ្ធផលសៀវភៅសិក្សាគោលមានចំណងជើងថា"English For Cambodia" ចំនួន៦ កម្រិតសម្រាប់ថ្នាក់ទី ៧ រហូតដល់ថ្នាក់ទី ១២ ត្រូវបានបោះពុម្ព និងដាក់អោយប្រើប្រាស់ជាបន្តបន្ទាប់(ណារ៉ុន,២០១៦)។ នៅក្នុងឆ្នាំ ២០០៤កម្មវិធីសិក្សានៅក្នុងប្រព័ន្ធអប់រំនៅប្រទេសកម្ពុជាត្រូវបានកែលំអដោយក្រសួងអប់រំយុវជននិងកីឡា។ ក្នុងនោះកម្មវិធីសិក្សាភាសាបរទេស(អង់គ្លេសនិងបារាំង)ត្រូវបានដាក់ឱ្យសិស្សរៀនចាប់ពីថ្នាក់ទី៥នៅកម្រិតបឋមសិក្សា ប៉ុន្តែមុខវិជ្ជានេះត្រូវបានដាក់ឱ្យសិក្សានៅក្នុងបំណិនជីវិតតាមមូលដ្ឋាន។ ចាប់ពីថ្នាក់ទី ៧ ឡើងទៅមុខវិជ្ជាភាសាបរទេស ត្រូវបានដាក់នៅក្នុងកម្មវិធីសិក្សាជាតិជាមុខវិជ្ជាចាំបាច់ដែលសិស្សត្រូវសិក្សាចំនួន៤ម៉ោងក្នុងមួយសប្តាហ៍។ ប៉ុន្តែក្រោយមកទៀត របាយម៉ោងសិក្សាភាសាបរទេសមានការផ្លាស់ប្តូរនៅកម្រិតមធ្យមសិក្សាទុតិយភូមិ។ យោងតាមសេចក្តីណែនាំលេខ ២៣ អយក.សណន ចថ្ងៃទី ០៨ ខែកញ្ញា ឆ្នាំ ២០១០ ស្តីពីការអនុវត្តកម្មវិធីសិក្សាចំណោះទូទៅថ្នាក់ទី១១ និងថ្នាក់ទី ១២ ចំនួនម៉ោងសិក្សាភាសាបរទេសត្រូវបានកាត់បន្ថយនៅសល់ត្រឹមតែ ២ ម៉ោងក្នុងមួយសប្តាហ៍ទាំងថ្នាក់វិទ្យាសាស្ត្រ និងថ្នាក់វិទ្យាសាស្ត្រសង្គម។ ដើម្បីបន្តអភិវឌ្ឍន៍ និងពង្រឹងកម្មវិធីសិក្សាភាសាអង់គ្លេសក្រសួងអប់រំ យុវជន និងកីឡា បានរៀបចំ និងដាក់ឱ្យប្រើនៅកម្មវិធីសិក្សាលំអិតភាសាអង់គ្លេសចំនួន ២ឆ្នាំនៅឆ្នាំ ២០១២ ដែលទី១គឺកម្មវិធីសិក្សាលម្អិតសម្រាប់បឋមសិក្សាថ្នាក់ទី ៤ទី ៥ និងទី៦ និងលើកទី ២ គឺកម្មវិធីសិក្សាលម្អិត

សម្រាប់ថ្នាក់ទី ៧ ទី៨ និង ទី៩(អយក.២០១២)។ តាមរយៈជំនួយពីអង្គការនីហ្សូណា សៀវភៅសិក្សាគោលភាសាអង់គ្លេសថ្មីដែលមានចំណងជើងថា"English Grade" ត្រូវបានផលិតឡើងដែលក្នុងនោះសៀវភៅ English Grade ៤&៥ ផលិតនៅឆ្នាំ ២០១៣ និង English Grade ៦&៧ នៅឆ្នាំ២០១៥។ ចំណែកសៀវភៅEnglish Grade ៨&៩ ក៏ត្រូវបានផលិតនៅឆ្នាំបន្តបន្ទាប់។ យោងតាមសេចក្តីណែនាំលេខ ៤៧អយក .សណន ចុះថ្ងៃទី ២៨ ខែធ្នូឆ្នាំ ២០១៦ សៀវភៅEnglish Grade ៧.៨.៩ត្រូវបានដាក់ឱ្យប្រើប្រាស់ជាសៀវភៅសិក្សាគោលសម្រាប់មធ្យមសិក្សាបឋមភូមិ ដែលក្នុងនោះមានទាំងសៀវភៅសិស្ស សៀវភៅណែនាំគ្រូ និងខ្សែអាត់សំឡេង។ ដោយឡែកសៀវភៅសិក្សាគោលភាសាអង់គ្លេសថ្មីសម្រាប់ថ្នាក់ទី ១០ទី១១ និង ទី១២ មិនទាន់បានផលិតចេញនៅឡើយនោះទេ ដូច្នេះសម្រាប់កម្រិតថ្នាក់ទាំងនេះត្រូវនៅតែអនុវត្តតាមសៀវភៅសិក្សាគោលចាស់ដដែលគឺសៀវភៅ"English For Cambodia"។

## ២.៥. ការលើកទឹកចិត្ត

ការលើកទឹមចិត្តត្រូវបានគេចាត់ទុកថា ជាកត្តាដ៏ចម្បងមួយដែលជះឥទ្ធិពលដល់ល្បឿននិងកម្រិតនៃការសិក្សាភាសាបរទេសរបស់សិស្ស(Gardner,2006)។ជាឧទាហរណ៍លោកGardner(2006) បានលើកឡើងថាសិស្សដែលមានកម្រិតនៃការលើកទឹកចិត្តខ្ពស់តែងតែធ្វើបានល្អជាងសិស្សដែលមានកម្រិតការលើកទឹកចិត្តទៀតជាង។ប្រសិនបើសិស្សមានការលើកទឹកចិត្តពួកគេមានហេតុផលគ្រប់គ្រាន់ក្នុងការចូលរួមរាល់សកម្មភាពទាំងអស់។(Elliot,S,.Kratochil, T,& Cook,J.,2000) មើលឃើញថាការលើកទឹកចិត្តជាសភាពលក្ខណៈខាងក្នុងដែលជំរុញឱ្យយើងធ្វើសកម្មភាពដើម្បីឆ្ពោះទៅរកគោលដៅដែលខ្លួនចង់បាននិងជំរុញឱ្យយើងព្យាយាមស្វែងរកចំណេះដឹងនិងជំនាញថ្មី។ ចំណែក(Petty,1998)យល់ឃើញថាប្រសិនបើសិស្សមិនចង់រៀនប្រសិទ្ធភាព នៃការសិក្សារបស់ពួកគេប្រាកដជាយឺត ឬក៏គ្មានទទួលបានលទ្ធផលអ្វីទាំងអស់។ ដូច្នេះបើគ្រូបង្រៀនដឹងពីវិធី នៃការលើកទឹកចិត្តសិស្ស គ្រូអាចជួយបង្កើនការសិក្សារបស់សិស្សឱ្យប្រសើរជាងមុន។ ការលើកទឹកចិត្តគឺជាការគិត និងអារម្មណ៍ដែលអាចជំរុញឱ្យយើងបន្តធ្វើអ្វីមួយ ហើយប្រែក្លាយការគិតទាំងនោះទៅជាសកម្មភាព។ ចំណែកការលើកទឹកចិត្តក្នុងការប្រើប្រាស់សៀវភៅសិក្សាភាសាអង់គ្លេសឱ្យកាន់តែសំខាន់ ប៉ុន្តែវាអាចប្រែប្រួលទៅតាមអាយុ ពេលវេលា ទីកន្លែង

និងសូម្បីតែការអានជាមួយគ្រូផ្សេងគ្នា។ មានកត្តាជាច្រើនដែលជាឥទ្ធិពលនិងជំរុញលើកទឹកចិត្តសិស្សឱ្យចង់អានសៀវភៅភាសាអង់គ្លេសដូចជាៈ ការយល់ពីសារៈសំខាន់នៃការអានសៀវភៅភាសាអង់គ្លេស ការចាប់អារម្មណ៍ពីវប្បធម៌របស់ប្រទេសដែលប្រើប្រាស់ភាសាអង់គ្លេសដែលសិស្សចង់ដឹង និងការគាំទ្រពីមនុស្សដទៃទៀតជុំវិញខ្លួន។ គ្រូចាំបាច់ត្រូវជួយសិស្សដើម្បីបង្កើតឱ្យមានកម្លាំងជំរុញទឹកចិត្ត និងថែរក្សាវា( Spatt,M, Pulvemess,A.& Williams,M.,2005 )។( Stern,2001 )ដែលបានសិក្សាពីអាកប្បកិរិយារបស់មនុស្សបានបញ្ជាក់ថា ចំពោះប្រទេស ក្រុម និងភាសាបានជួយយើងយល់ថាហេតុអ្វី បានជាមនុស្សមួយចំនួនមានកម្លាំងក្នុងការអានសៀវភៅជាមួយអ្នកដទៃ។ លោកក៏បានលើកឡើងទៀតថាការរៀបចំមេរៀនសម្រាប់បង្រៀនដោយផ្អែកលើចំណាប់អារម្មណ៍របស់សិស្ស តែមួយមុខគឺមិនទាន់គ្រប់គ្រាន់នៅឡើយទេគ្រូបង្រៀន ចាំបាច់ត្រូវតែជួយជំរុញសិស្សឱ្យយល់ពីតម្លៃនៃការទទួលបាននូវជំនាញប្រើប្រាស់ភាសា និងសៀវភៅសិក្សាថែមទៀត។ អ្នកសិក្សាជាច្រើនបានបែងចែកការជំរុញទឹកចិត្តជាពីរប្រភេទ ខាងក្នុងនិងខាងក្រៅ និងបានឱ្យនិយមន័យចំពោះការជំរុញទឹកចិត្តខាងក្នុងថាជាការធ្វើអ្វីមួយដោយសារមានការចូលចិត្តរបស់បុគ្គលនោះទាល់តែម្តង។ រីឯការជំរុញទឹកចិត្តខាងក្រៅ គឺកើតឡើងនៅពេលដែលមានកម្លាំងជំរុញពីខាងក្រៅអាចជាសម្ភារៈឬដើម្បីសម្រេចគោលដៅណាមួយ។ ជាទូទៅសិស្សដែលមានកម្លាំងជំរុញខាងក្នុងច្រើនទទួលបានលទ្ធផល នៃការសិក្សាខ្ពស់ជាងសិស្សដែលមានតែកម្លាំងជំរុញពីខាងក្រៅ ( Ryan,M,R,&,Deci,E,L.,2000 )។

## ២.៦. ការរៀបចំមេរៀនឬកិច្ចតែងការបង្រៀន

មានការលើកឡើងផ្សេងគ្នា ចំពោះការរៀបចំមេរៀន និងការធ្វើកិច្ចតែងការបង្រៀន។ Williams,.M( 2005 ) បានលើកឡើងថាការធ្វើកិច្ចតែងការគឺជាការកត់ចំណាំដែលជួយគ្រូបានគិតទុកជាមុននូវវត្ថុបំណងមេរៀន ដំណើរការបង្រៀន និងរបៀបដែលគ្រូត្រូវបង្រៀនមេរៀនមួយ និងជាផ្លូវសម្រាប់ជួយគ្រូបានរៀបចំនូវសម្ភារៈសម្រាប់ជួយសិស្សក្នុងការធ្វើសកម្មភាព។ នៅក្នុងថ្នាក់រៀនភាសាអង់គ្លេសមួយដើម្បីឱ្យសកម្មភាពសិក្សារបស់សិស្សទទួលបានលទ្ធផលល្អ ពួកគេត្រូវអនុវត្តសកម្មភាពជាច្រើន ដូច្នេះនៅពេលធ្វើកិច្ចតែងការគ្រូបង្រៀនត្រូវដាក់បញ្ចូលកម្មវិធីឱ្យបានច្រើនសម្រាប់សិស្សអនុវត្ត។

Celce-Murcia(2001)និយាយថាកិច្ចតែងការបង្រៀនដែលល្អ គឺទាមទារឱ្យសកម្មភាពទាំងអស់មានទំនាក់ទំនងគ្នា និងមានភាពបត់បែន។ គ្រូបង្រៀនត្រូវចាំទុកក្នុងចិត្តជានិច្ច នូវវត្ថុបំណងមេរៀបានពន្យល់នៅពេលរៀបចំសកម្មភាពបង្រៀននីមួយៗ។

## ២.៧. បរិមាណសិស្សក្នុងថ្នាក់

Blatchford(2003)បានពន្យល់ថាមានយុទ្ធសាស្ត្រជាច្រើនសម្រាប់លើកកម្ពស់ស្តង់ដារអប់រំ។ លោកក៏បានបន្ថែមទៀតថាថ្នាក់តូចអាចនាំឱ្យមានគុណភាពការរៀន និងបង្រៀនប្រសើរឡើង។ នៅពេលដែលគាត់បានចុះទៅអង្កេតនៅថ្នាក់រៀនមួយដែលមានសិស្ស ១៥នាក់ឃើញថាស្ថានភាពទូទៅនៅក្នុងថ្នាក់រៀននេះ គឺវិជ្ជមានដោយគ្រូតែងតែនិយាយលេងសើចជាមួយសិស្ស និងមានទំនាក់ទំនងផ្ទាល់ខ្លួនជាច្រើន។ ក្រៅពីនេះអ្នកស្រាវជ្រាវក៏ចុះទៅអង្កេតថ្នាក់រៀនធំផ្សេងទៀតដែលមានសិស្សចំនួន ៣០ នាក់ ហើយបានរកឃើញថា រវាងថ្នាក់ទាំងពីរមានសភាពខុសគ្នាគួរឱ្យកត់សម្គាល់។ នៅក្នុងថ្នាក់តូចគ្រូបានចំណាយពេលតិចតួចនៅក្នុងការគ្រប់គ្រងថ្នាក់រៀន ប៉ុន្តែនៅក្នុងខ្នាត់ធំ គ្រូព្យាយាមចំណាយពេលជាច្រើនដើម្បីទាញចំណាប់អារម្មណ៍សិស្សលើការងារដែលគ្រូដាក់។ ម្យ៉ាងទៀតនៅក្នុងថ្នាក់តូច គ្រូស្គាល់សិស្សម្នាក់ច្បាស់ដែលអាចឱ្យគ្រូជួយសិស្សក្នុងការសិក្សាបានងាយស្រួល(Blatchford, 2003)។Hong Thi Nguyen, Heather Fehrering(2014)បានធ្វើការសិក្សាមួយទៀតគឺបានធ្វើការអង្កេតថ្នាក់មួយចំនួននៅក្នុងសាលា Hutech ក្នុងប្រទេសវៀតណាមដែលក្នុងនោះថ្នាក់រៀន ភាគច្រើនមានសិស្សច្រើនចាប់ពី ៤០នាក់ ដល់ ៥០នាក់។ លទ្ធផលឃើញថាក្នុងថ្នាក់រៀនដែលមានតិច គឺការសិក្សារបស់សិស្សទទួលបានលទ្ធផលជាងពីព្រោះនៅក្នុងថ្នាក់រៀនតូចគ្រូងាយស្រួលគ្រប់គ្រងរាល់សកម្មភាពទាំងឡាយដែលគ្រូដាក់ឱ្យសិស្សអនុវត្តនិងធ្វើ។

# ជំពូកទី៣

# វិធីសាស្ត្រស្រាវជ្រាវ

# ជំពូកទី៣

# វិធីសាស្ត្រស្រាវជ្រាវ

## ៣.១. ការប្រមូលទិន្នន័យ

ដើម្បីឆ្លើយតបទៅ និងវត្ថុបំណងនៃការសិក្សាស្រាវជ្រាវ និងសំណួរស្រាវជ្រាវខាងលើវិធីសាស្ត្របែបបរិមាណវិស័យ និងគុណវិស័យត្រូវបានជ្រើសរើសយកមកប្រើប្រាស់ក្នុងការប្រមូលទិន្នន័យពីអ្នកដែលពាក់ព័ន្ធនានា។ មុននឹងប្រមូលទិន្នន័យទាំងនេះកម្រងសំណួរចំនួន ៣ ប្រភេទត្រូវបានបង្កើតឡើងសម្រាប់អ្នកចូលរួមចំនួនបីប្រភេទផ្សេងគ្នាឆ្លើយរួមមាននាយកនាយិការសាលាគ្រូបង្រៀនភាសាអង់គ្លេសថ្នាក់ទី ៧ ទី ៨ និងទី ៩ និងសិស្សានុសិស្ស។ កម្រងសំណួរទាំងនេះត្រូវបានបង្កើតឡើងតាមរយៈការអាន និងពិនិត្យយ៉ាងយកចិត្តទុកដាក់ទៅលើឯកសារគោលនានាដូចជា៖ ឯកសារកម្មវិធីសិក្សាភាសាបរទេស លិខិត និងសេចក្តីណែនាំរបស់ក្រសួង សៀវភៅសិក្សាគោលព្រមទាំងឯកសារពាក់ព័ន្ធនានាបានមកពីការសិក្សាស្រាវជ្រាវដែលមានស្រាប់ទាំងក្នុងស្រុក និងក្រៅប្រទេសមួយចំនួននៅក្នុងតំបន់ និងសាកលលោក។

## ៣.២. ទីតាំងនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវទៅលើប្រធានបទខាងលើ អ្នកសិក្សាស្រាវជ្រាវសម្រេចជ្រើសរើសយកវិទ្យាល័យ ចំនួន ៤ និងអនុវិទ្យាល័យចំនួន ៤ នៅក្នុងខេត្តស្វាយរៀងរួមមាន (១)វិទ្យាល័យស្វាយរៀង (២)វិទ្យាល័យហ៊ុនសែនស្វាយជ្រំ (៣)វិទ្យជាល័យហ៊ុនសែនប្រសូតិ (៤)វិទ្យាល័យហ៊ុនសែនកំពង់ចក (៥)អនុវិទ្យាល័យហ៊ុនសែនតាដៃ (៦)អនុវិទ្យាល័យហ៊ុនសែនសំបួរ (៧)អនុវិទ្យាល័យបាសាក់ (៨) អនុវិទ្យាល័យព្រៃគគីរ សម្រាប់ធ្វើការសិក្សាស្រាវជ្រាវឱ្យបានស៊ីជម្រៅនិងច្បាស់លាស់។មូលហេតុដែលអ្នកសិក្សាស្រាវជ្រាវជ្រើសរើសយកវិទ្យាល័យ និងអនុវិទ្យាល័យទាំងនោះសម្រាប់ធ្វើការសិក្សាស្រាវជ្រាវដោយសារសាលារៀនទាំងនោះស្ថិតនៅក្នុងស្រុកផ្សេងៗគ្នា(វិទ្យាល័យចំនួន ១ស្ថិតនៅក្នុងទីប្រជុំជន និង ៧ផ្សេងទៀតស្ថិតនៅតាមស្រុកនីមួយៗ)។

## ៣.៣. ការជ្រើសរើសសំណាក

ចំពោះការសិក្សាស្រាវជ្រាវលើប្រធានបទខាងលើ អ្នកសិក្សាស្រាវជ្រាវបានប្រើប្រាស់វិធីសាស្ត្រក្នុងការជ្រើសរើសភាគសំណាក់តាមបែបគោលបំណងក្នុងការប្រមូលទិន្នន័យដោយសំដៅតែសំណាក់ណាដែលអ្នកសិក្សាស្រាវជ្រាវយល់ថាភាគសំណាក់នោះអាចផ្តល់ទិន្នន័យបានជាក់លាក់ច្បាស់លាស់ និងអាចឆ្លើយតបទៅ និងប្រធានបទនេះបាន។ ដូច្នេះភាគសំណាកដែលអ្នកសិក្សាស្រាវជ្រាវយល់ថាអាចទទួលបានទិន្នន័យដែលជឿទុកចិត្តបាននោះមាន ៣ ប្រភេទរួមមាន លោកនាយកសាលាចំនួន ៨នាក់ គ្រូបង្រៀនភាសាអង់គ្លេសថ្នាក់ទី ៧ ទី ៨ និងទី ៩ ចំនួន២០នាក់ និងសិស្សថ្នាក់ទី ៧ ទី ៨ និងទី ៩ ចំនួន ៣០០នាក់ ចេញពីវិទ្យាល័យចំនួន ៤ និងអនុវិទ្យាល័យចំនួន ៤ ក្នុងក្រុងស្រុកចំនួន ៤ ផ្សេងៗគ្នានៅក្នុងខេត្តស្វាយរៀង។ប្រភេទទី៖ ១ គ្រូបង្រៀនភាសាអង់គ្លេសថ្នាក់ទី ៧ ទី ៨ និងទី៩ ទាំងអស់ត្រូវបានជ្រើសរើសសម្រាប់បំពេញកម្រងសំណួរ។មូលហេតុដែលអ្នកសិក្សាស្រាវជ្រាវជ្រើសរើសយកគ្រូភាសាអង់គ្លេសថ្នាក់ទី ៧ ទី៨ និងទី ៩ដោយសារមុខវិជ្ជាភាសាអង់គ្លេសនៅក្នុងកម្រិតថ្នាក់នេះជាមុខវិជ្ជាមួយដែលត្រូវបានក្រសួងអប់រំ យុវជន និងកីឡា ទើបតែនិងបានដាក់ឱ្យប្រើប្រាស់នូវសៀវភៅសិក្សាគោលថ្មី។ ដូច្នេះអ្នកសិក្សាស្រាវជ្រាវជឿជាក់ថាលោកគ្រូ អ្នកគ្រូពិតជាអាចប្រាប់ពីស្ថានភាពដែលគាត់ជួបប្រទះក្នុងការប្រើប្រាស់សៀវភៅសិក្សាគោលប្រចាំថ្ងៃនិងព័ត៌មានលម្អិតទាំងអស់មកធ្វើការវិភាគឱ្យបានស៊ីជម្រៅជាមិនខាន។ ប្រភេទទី២៖គឺការជ្រើសរើសយកសិស្សថ្នាក់ទី៧ ទី ៨ និងទី ៩ មកធ្វើជាសំណាកព្រោះពួកគេជាអ្នកសិក្សាមុខវិជ្ជាភាសាអង់គ្លេសជាមួយគ្រូភាសាអង់គ្លេសរបស់ពួកគេផ្ទាល់។ ហេតុដូច្នេះពួកគេប្រាកដជាអាចផ្តល់ព័ត៌មានបន្ថែមទាក់ទង និងប្រធានបទបានគ្រប់ជ្រុងជ្រោយសម្រាប់ឱ្យអ្នកសិក្សាស្រាវជ្រាវយកមកធ្វើការវិភាគ។ប្រភេទទី៣៖គឺជាការសម្ភាសន៍ផ្ទាល់និងឱ្យនាយកបំពេញកម្រងសំណួរបន្ថែម។មូលហេតុដែលជ្រើសរើសនាយកក្នុងការផ្តល់ព័ត៌មានក្នុងការស្រាវជ្រាវនេះពីព្រោះតែនាយកក៏ជាអ្នកដែលអាចផ្តល់ព័ត៌មានទូទៅស្តីពីការប្រើប្រាស់សៀវភៅសិក្សាគោលរបស់លោកគ្រូ អ្នកគ្រូ និងសិស្សជាពិសេសនាយក គឺជាអ្នកធ្វើអធិការកិច្ចផ្ទាល់នៅនៅសាលាក្នុងការតាមដានការអនុវត្តការងារប្រចាំថ្ងៃរបស់លោកគ្រូអ្នកគ្រូ។

## ៣.៤. ឧបករណ៍ស្រាវជ្រាវ

ដើម្បីប្រមូលទិន្នន័យបានជាក់លាក់អ្នកសិក្សាស្រាវជ្រាវបានបង្កើតទម្រង់សំណួរស្រាវជ្រាវចំនួន ៣ ដើម្បីឆ្លើយតបនឹងវត្ថុបំណងនៃការស្រាវជ្រាវរួមមាន ទី (១)ទម្រង់សំណួរសម្រាប់គ្រូបង្រៀនភាសាអង់គ្លេស ទី (២)គឺទម្រង់សំណួរសម្រាប់សិស្ស និងទី(៣)គឺទម្រង់សំណួរសម្រាប់សម្ភាសន៍និងឱ្យនាយកបំពេញ។ទម្រង់សំណួរទី ១៖ ទម្រង់សំណួរសម្រាប់សិស្សអ្នកសិក្សាស្រាវជ្រាវចែកជា ៨ផ្នែក។ផ្នែកទី ១៖ ព័ត៌មានទូទៅរបស់សិស្សចែកជា ៣ ចំណុចគឺ (១) ឈ្មោះក្រុង/ស្រុក(២)ឈ្មោះសាលារៀន (៣) ភេទ។ផ្នែកទី ២៖ គុណវុឌ្ឍគ្រូបង្រៀនភាសាអង់គ្លេសដែលបែងចែកជា ៣ ចំណុចគឺ១ កម្រិតចំណេះដឹងលើមុខវិជ្ជា ២សមត្ថភាពខ្ពស់ពុធរបស់គ្រូជួយសិស្សឆាប់យល់មេរៀន ៣គុណភាពនៃការបង្រៀនរបស់គ្រូ។ផ្នែកទី ៣៖កម្មវិធីសិក្សាត្រូវបានបែងចែកជា ៤ចំណុចគឺ (១)ខ្លឹមសារសៀវភៅសិក្សាគោល (២)កម្រិតខ្លឹមសារសៀវភៅសិក្សាគោលធៀបនិងសមត្ថភាពសិស្ស (៣)ចំនួនម៉ោងដែលសិស្សត្រូវរៀន ផ្នែកទី៤ ៖សម្ភារៈទ្រទ្រង់ការបង្រៀនបែងចែកជា២គឺ (១) កម្រិតនៃការប្រើប្រាស់សម្ភារៈឧបទេស (២)សារៈប្រយោជន៍នៃការប្រើប្រាស់សម្ភារៈឧបទេស។

ផ្នែកទី ៥៖ សមត្ថភាពប្រើប្រាស់សៀវភៅពុម្ពក្នុងថ្នាក់ត្រូវបានចែកជា៤ចំណុចគឺ(១)សិស្សអានសៀវភៅម្នាក់ឯង (២)សិស្សអានសៀវភៅជាគូ (៣)សិស្សអានសៀវភៅជាក្រុម (៤)សិស្សទាំងអស់អានសៀវភៅរួមគ្នា។ផ្នែកទី ៦ បរិមាណសិស្សក្នុងថ្នាក់ត្រូវបានបែងចែកជាពីរចំណុច (១)ចំនួនសិស្សក្នុងថ្នាក់នីមួយៗ (២)កត្តាជះឥទ្ធិពលអវិជ្ជមានចំពោះថ្នាក់រៀនដែលមានសិស្សច្រើន។ផ្នែកទី ៧៖ស្ថានភាពសិក្សារបស់សិស្សមាន ៤ ចំណុចគឺ(១) អាមករៀនទៀងទាត់និងទាន់ពេលវេលា (២)ការយកចិត្តទុកដាក់ស្តាប់គ្រូក្នុងម៉ោងសិក្សា (៣)ការចូលរួមធ្វើសកម្មភាពសិក្សាក្នុងថ្នាក់ (៤)ការធ្វើកិច្ចការផ្ទះដែលគ្រូដាក់ឱ្យ។

ទម្រង់សំណួរទី ២៖ទម្រង់សំណួរសម្រាប់គ្រូអ្នកសិក្សាស្រាវជ្រាវបានរៀបចំជា ៨ ផ្នែក ផ្នែកទី (១)អំពីព័ត៌មានទូទៅរបស់គ្រូចែកជា ៣ ចំណុចគឺ(១) ឈ្មោះក្រុង/ស្រុក (២) ឈ្មោះសាលា (៣) ភេទ។ផ្នែកទី២៖ គុណវុឌ្ឍគ្រូបង្រៀនភាសាអង់គ្លេសដែលបែងចែកជា ៧ចំណុចគឺ (១)ក្របខ័ណ្ឌរបស់គ្រូ

បង្រៀន(២)កម្រិតសញ្ញាប័ត្រចុងក្រោយរបស់គ្រូបង្រៀន(៣)សមត្ថភាពគ្រូខ្លស់ជួយដល់ការបង្រៀន(៤)បទពិសោធន៍បង្រៀន(៥)ការចូលរួមវគ្គបណ្តុះបណ្តាល(៦)គុណប្រយោជន៍នៃការចូលរួមវគ្គបណ្តុះបណ្តាល(៧)ការជ្រើសរើសវគ្គបំប៉ន។ ផ្នែកទី ៣៖ កម្មវិធីសិក្សាត្រូវបានបែងចែកជា ៤ចំណុចគឺ (១) បំណែងចែកកម្មវិធីសិក្សាប្រចាំឆ្នាំ(២)សារៈប្រយោជន៍នៃបំណែងចែកកម្មវិធីសិក្សា(៣)ខ្លឹមសារសៀវភៅសិក្សាគោល(៤)ចំនួនម៉ោងបង្រៀន។ផ្នែកទី ៤៖ សម្ភារៈទ្រទ្រង់ការបង្រៀនបែងចែកជា២គឺ (១)ស្ថានភាពនិងកម្រិតប្រើប្រាស់សម្ភារៈ(២)សារៈប្រយោជន៍នៃសម្ភារៈប្រទេស។ ផ្នែកទី ៥ ៖សកម្មភាពរៀនរបស់សិស្សក្នុងថ្នាក់ត្រូវបានចែកជា ៣ចំណុចគឺ(១)កម្រិតនៃការឱ្យសិស្សអានសៀវភៅម្នាក់ឯង ដៃគូក្រុមនឹងរួមគ្នា(២)ការដាក់ការងារអោយសិស្សធ្វើនៅផ្ទះ(៣)ការលើកទឹកចិត្តសិស្ស។ផ្នែកទី ៦៖ការរៀបចំមេរៀនបង្រៀនត្រូវបានចែកជាមួយចំណុចគឺការរៀបចំធ្វើកិច្ចតែងការបង្រៀន។ផ្នែកទី ៧ ៖ បរិមាណសិស្សក្នុងថ្នាក់ត្រូវបានបែងចែកជាពីរចំណុច(១) ចំនួនសិស្សក្នុងថ្នាក់នីមួយៗ(២)កត្តាជះឥទ្ធិពលអវិជ្ជមានចំពោះថ្នាក់រៀនដែលមានសិស្សច្រើន។ផ្នែកទី ៨ ស្ថានភាពសិក្សារបស់សិស្សមាន ៤ចំណុច(១)ការមករៀនទៀងទាត់និងទាន់ពេលវេលា(២)ការយកចិត្តទុកដាក់ស្តាប់គ្រូក្នុងម៉ោងសិក្សា(៣)ការចូលរួមធ្វើសកម្មភាពសិក្សាក្នុងថ្នាក់(៤)ការធ្វើកិច្ចការផ្ទះដែលគ្រូដាក់ឱ្យ។

ទម្រង់សំណួរទី ៣៖ ទម្រង់សំណួរសំរាប់សំភាសន៍នាយក នាយិកាសាលា។ នៅក្នុងទម្រង់កម្រងសំណួរនេះអ្នកសិក្សាស្រាវជ្រាវបានរៀបចំជា ៤ផ្នែក។ ផ្នែកទី ១៖ជំនាញឯកទេសក្របខណ្ឌគរុកោសល្យនិងសមត្ថភាពក្នុងការបង្រៀនរបស់គ្រូ។ ផ្នែកទី២៖ការចូលរួមវគ្គបណ្តុះបណ្តាលចុងក្រោយ។ ផ្នែកទី ៣៖ ការអនុវត្តរបស់គ្រូបង្រៀនទាក់ទងទៅ និងការមកបំពេញការងារបានទៀងទាត់ ការរៀបចំកិច្ចតែងការបង្រៀន និងការយកចិត្តទុកដាក់លើការសិក្សារបស់សិស្សពីសំណាក់គ្រូបង្រៀន។ ផ្នែកទី៤៖ទាក់ទងនិងប្រភេទសម្ភារៈជំនួយដល់ការបង្រៀន និងរៀនភាសាអង់គ្លេសដែលសាលាមាន និងកម្រិតនៃការប្រើប្រាស់សម្ភារៈដែលមានពីសំណាក់លោកគ្រូអ្នកគ្រូ។

## ៣.៥. ដំណាក់កាលនៃការប្រមូលទិន្នន័យ

បន្ទាប់ពីបានបង្កើតសំណួរ និងឧបករណ៍ ដើម្បីប្រមូលទិន្នន័យព្រមទាំងបានអនុម័តជាបន្តបន្ទាប់ពីសាស្ត្រាចារ្យដឹកនាំបង្គោល និងសាស្ត្រាចារ្យដឹកនាំរងរួចមក អ្នកសិក្សាស្រាវជ្រាវទទួលបានលិខិតអនុញ្ញាតពីវិទ្យាស្ថានជាតិអប់រំលេខ ១១៣ វជអ.ផក ចុះថ្ងៃទី ១៦ ខែកក្កដាឆ្នាំ ២០២០ ស្នើសុំទៅប្រធានមន្ទីរអប់រំ យុវជន និងកីឡា ខេត្តស្វាយរៀង ដើម្បីសុំកិច្ចសហការក្នុងគោលបំណងចុះប្រមូលទិន្នន័យនៅតាមសាលាគោលដៅ ដូចបានកំណត់ទាក់ទងទៅនិងប្រធានបទសម្រាប់ការធ្វើវិភាគ។ បន្ទាប់មកទៀត អ្នកសិក្សាស្រាវជ្រាវ ក៏បានស្នើសុំប្រធានមន្ទីរអប់រំ យុវជន និងកីឡាខេត្តដើម្បីធ្វើការឯកភាពទៅលើលិខិតអនុញ្ញាតថ្នាក់មន្ទីរអប់រំ យុវជន និងកីឡាខេត្តស្វាយរៀង ដើម្បីធ្វើដំណើរទៅកាន់ការិយាល័យអប់រំ យុវជន និងកីឡាថ្នាក់ស្រុក ក្នុងគោលបំណងស្នើសុំការចុះទៅសាលាគោលដៅដែលបានជ្រើសរើស។ បន្ទាប់មក អ្នកសិក្សាស្រាវជ្រាវ បានស្នើសុំជួបគណៈគ្រប់គ្រងសាលាដើម្បីសុំការអនុញ្ញាតពីគណៈគ្រប់គ្រងជួបជាមួយអ្នកពាក់ព័ន្ធដូចជាលោកគ្រូ អ្នកគ្រូបង្រៀនភាសាអង់គ្លេស និងសិស្សានុសិស្សថ្នាក់ទី៧ ទី ៨ ទី៩ ដើម្បីឱ្យពួកគាត់ជួយបំពេញចម្លើយទៅតាមកម្រងសំណួរដែលបានចែកជូនក្នុងនោះ ក៏មានកម្រងសំណួរសម្រាប់នាយក/នាយិកាផងដែរ។ ក្រោយពីគណៈគ្រប់គ្រងសាលាលោកគ្រូ អ្នកគ្រូបង្រៀនភាសាអង់គ្លេស បានបំពេញចម្លើយរួចរាល់ហើយអ្នកសិក្សាស្រាវជ្រាវ បានធ្វើការប្រមូលសន្លឹកសំណួរទាំងអស់នោះមកពិនិត្យមើលឱ្យមានរបៀបរៀបរយកុំឱ្យខ្វះចន្លោះ ឬសន្លឹកកិច្ចការណាដែលមានភាពមិនប្រក្រតីដើម្បីទទួលបានព័ត៌មានត្រឹមត្រូវ និងយកមកវិភាគទិន្នន័យច្បាស់លាស់។ បន្ទាប់មកទៀត អ្នកសិក្សាស្រាវជ្រាវបានធ្វើសម្ភាសន៍នាយក គ្រូបង្រៀនភាសាអង់គ្លេស និងសិស្សានុសិស្សមួយចំនួនដើម្បីទទួលបានព័ត៌មានកាន់តែស៊ីជម្រៅពីការប្រើប្រាស់សៀវភៅសិក្សាគោល និងបញ្ហាប្រឈមនានានៅកម្រិតអនុវិទ្យាល័យ។

## ៣.៦. ការវិភាគទិន្នន័យ

ការសិក្សាស្រាវជ្រាវនេះអ្នកសិក្សាស្រាវជ្រាវបានប្រើប្រាស់វិធីសាស្ត្រចម្រុះតាមបែបបរិមាណវិស័យ និងគុណវិស័យ។ទិន្នន័យបែបបរិមាណវិស័យដែលប្រមូលបានពីគ្រប់ភាគីពាក់ព័ន្ធទាំងអស់ជាដំបូង ត្រូវវិភាគដាច់ដោយឡែកទៅតាមប្រភេទសំណាក់នីមួយៗ គ្រូបង្រៀន និងសិស្ស។ បន្ទាប់មកអ្នក

សិក្សាស្រាវជ្រាវសំយោគបញ្ចូលគ្នាផ្តោតសំខាន់ទៅលើគុណវុឌ្ឍិគ្រូបង្រៀនភាសាអង់គ្លេស កម្មវិធីសិក្សា សម្ភារៈទ្រទ្រង់ការបង្រៀន និងរៀន ការរៀបចំមេរៀន បរិមាណសិស្សក្នុងថ្នាក់ និងស្ថានភាពការសិក្សារបស់សិស្ស។ ដើម្បីឆ្លើយតប និងចំណុចនេះអ្នកសិក្សាស្រាវជ្រាវបានប្រើវិធីសាស្ត្រកម្មវិធីMicrosoft Excel សម្រាប់ស្វែងរកចំនួនគិតជាភាគរយ សង់ក្រាប តារាង និងបកស្រាយព័ត៌មាន។ ការវិភាគបែបគុណវិស័យជាការប្រមូលផ្តុំគំនិតទស្សនៈការយល់ឃើញនានា របស់អ្នកផ្តល់សម្ភាសដោយចាក់បញ្ចូលនូវចំណុចដែលដូច ឬប្រហាក់ប្រហែលគ្នាដើម្បីបន្ថែមព័ត៌មាន និងបង្ហាញគំនិតគាំទ្រចំពោះទិន្នន័យនៃការវិភាគតាមបែបបរិមាណវិស័យ។ បន្ទាប់មកអ្នកសិក្សាស្រាវជ្រាវបានលើកជាសំណូមពរចំពោះចំនុចខ្វះខាត និងកែលម្អចំណុចខ្វះខាតទាំងនោះឱ្យបានប្រសើរឡើង។

## ៣.៧. ក្រមសីលធម៌នៃការស្រាវជ្រាវ

អ្នកសិក្សាស្រាវជ្រាវ បានផ្តោតយកចិត្តទុកដាក់ពីបញ្ហាក្រមសីលធម៌ ពីព្រោះវាមានសារៈសំខាន់ណាស់ក្នុងការធានាប្រសិទ្ធភាព នៃការស្រាវជ្រាវ ក៏ដូចជាការបង្កើននូវភាពទុកចិត្ត និងភាពជឿជាក់ដល់អ្នកចូលរួមផ្តល់ចម្លើយក៏ដូចជា ទិន្នន័យផ្សេងៗសម្រាប់ប្រើប្រាស់ក្នុងកិច្ចការស្រាវជ្រាវនេះផងដែរ។ មានការព្រមព្រៀងគ្នា រវាងអ្នកផ្តល់ចម្លើយ និងអ្នកដែលស្វែងរកប្រភពព័ត៌មានច្បាស់លាស់ និងមានប្រសិទ្ធិភាព ហើយអាចយកមកប្រើប្រាស់បានសម្រាប់ការធ្វើវិភាគស៊ីជម្រៅ។ អត្តសញ្ញាណរបស់អ្នកផ្តល់ចម្លើយត្រូវបានរក្សាការសម្ងាត់លើកលែងតែឈ្មោះសាលាដែលត្រូវបានបង្ហាញ ប៉ុន្តែក៏មានការឯកភាពពីនាយកសាលាគោលដៅនីមួយៗអ្នកសិក្សាស្រាវជ្រាវបាននាំយកនូវលិខិតអនុញ្ញាតទៅជាមួយហើយសុំការអនុញ្ញាតពីភាគីពាក់ព័ន្ធដោយចាប់ផ្តើមមុនពេលពួកគាត់បំពេញកម្រងសំណួរនិងផ្តល់បទសម្ភាសន៍។ការធ្វើបែបនេះមានន័យថាអ្នកផ្តល់ចម្លើយយល់នូវគោលបំណងនៃការស្រាវជ្រាវមុនហើយអ្នកស្រាវជ្រាវក៏រំពឹងផងដែរថានឹងទទួលបានចម្លើយឬព័ត៌មានដែលពិត។ការធ្វើដូច្នេះធ្វើឱ្យអ្នកសិក្សាស្រាវជ្រាវមានទំនុកចិត្ត និងមានភស្តុតាងបញ្ជាក់ពីការចុះទៅប្រមូលទិន្នន័យរបស់ខ្លួនដោយស្របច្បាប់។

# ជំពូកទី៤

# លទ្ធផល និង ការ ពិភាក្សា

# ជំពូកទី៤

# លទ្ធផល និងការពិភាក្សា

## ៤.១. អ្នកចូលរួម និងព័ត៌មានទូទៅ

បន្ទាប់ពីការចុះប្រមូលទិន្នន័យបឋម នៅតាមវិទ្យាល័យ និងអនុវិទ្យាល័យគោលដៅទាំង ៨រួចមក សិក្សាស្រាវជ្រាវបានទទួលអ្នកចូលរួមសរុបចំនួន ៣២៨នាក់ ក្នុងនោះមាននាយកសាលាចំនួន ៨ នាក់ គ្រូបង្រៀនភាសាអង់គ្លេសនៅថ្នាក់ទី ៧ទី ៨ទី ៩ចំនួន ២០នាក់ និងសិស្សានុសិស្សដែលកំពុងរៀនថ្នាក់ទី ៧ ទី៨ ទី៩ ចំនួន ៣០០នាក់។

**តារាងទី១៖ចំនួនអ្នកចូលរួមក្នុងការផ្ដល់ព័ត៌មានសម្រាប់ការសិក្សាស្រាវជ្រាវ**

| ភាគសំណាក | ប្រុស | ស្រី | សរុប |
|---|---|---|---|
| នាយកសាលា | ៨ | ០ | ៨ |
| គ្រូបង្រៀន | ១២ | ៨ | ២០ |
| សិស្ស | ១២៨ | ១៧២ | ៣០០ |

ទិន្នន័យនេះបានបង្ហាញពីចំនួនអ្នកចូលរួមស្ត្រីច្រើនជាងបុរសនោះ ក៏ព្រោះតែការជ្រើសរើសសំណាកចាប់ដោយចៃដន្យដោយយកបញ្ជីឈ្មោះសិស្សទាំងអស់នៃថ្នាក់នីមួយៗដោយរាប់ពីលេខ ១ ដល់លេខ១០។ ប៉ុន្តែបើមើលទៅគ្រូវិញ គឺប្រុសមានចំនួនច្រើនជាងស្ត្រីព្រោះ គ្រូបង្រៀន ភាសាអង់គ្លេសនៅសាលាទាំងនោះភាគច្រើនគឺគ្រូប្រុស។

## ៤.២. គុណវុឌ្ឍិគ្រូបង្រៀនភាសាអង់គ្លេស

### ៤.២.១. កម្រិតជំនាញគរុកោសល្យរបស់គ្រូភាសាអង់គ្លេស

| ជំនាញគរុកោសល្យ | កម្រិតសញ្ញាបត្រ | ភាគរយ |
|---|---|---|
| គ្រូបង្រៀនកម្រិតមូលដ្ឋាន | ១៦នាក់ | ៨០% |
| គ្រូបង្រៀនកម្រិតឧត្តម | ៤នាក់ | ២០% |

លទ្ធផលស្រាវជ្រាវបានបង្ហាញថាក្នុងចំណោមគ្រូភាសាអង់គ្លេសថ្នាក់ទី ៧ ទី៨ ទី ៩ទាំងអស់នៅក្នុងវិទ្យាល័យនិងអនុវិទ្យាល័យទាំង ៨ មានគ្រូចំនួន៨០% ដែលជាគ្រូកម្រិតមូលដ្ឋានដែលត្រូវតាមកម្រិត

ថ្នាក់ដែលខ្លួនកំពុងបង្រៀនខណៈគ្រូបង្រៀនប្រមាណ ២០%ទៀតជាគ្រូបង្រៀនកម្រិតឧត្តម។ បើតាមការអះអាងរបស់លោកនាយកសាលាតាមរយៈការសម្ភាសន៍បាននិយាយថា បានជាមានគ្រូកម្រិតឧត្តមបង្រៀននៅមធ្យមសិក្សាបឋមភូមិ ពីព្រោះគ្រូបង្រៀនទាំងនោះបានប្រឡងជាប់ជាគ្រូបង្រៀនកម្រិតឧត្តមតាមរយៈប្រឡងប្តូរក្របខណ្ឌ(ប្រឡងផ្ទៃក្នុង)ដែលបានបើកឱកាសទូលាយឱ្យលោកគ្រូ អ្នកគ្រូមានសិទ្ធិចូលរួមដាក់ពាក្យប្រឡងចាប់តាំងពីឆ្នាំ ២០១៣ក នលងមក។ ស្រដៀងគ្នានេះ តែមានសិស្សានុសិស្សចំនួន ៩៩%បានលើកឡើងថា គ្រូបង្រៀនរបស់ពួកគាត់ជាគ្រូបង្រៀនដែលមានកម្រិតចំណេះដឹងខ្ពស់ខណៈពេលដែលសិស្សប្រមាណ ០,៣%ប៉ុណ្ណោះ ដែលបានលើកឡើងថាគ្រូបង្រៀនភាសាអង់គ្លេសរបស់ពួកគេមានកម្រិតចំណេះដឹងខ្សោយ ក្រោមមូលដ្ឋានលើមុខវិជ្ជាដែលកំពុងរៀន។ តាមទិន្នន័យនេះអ្នកសិក្សាស្រាវជ្រាវអាចសន្និដ្ឋានថាការបង្រៀននៅតាមសាលាគោលដៅទាំង៨ មានភាពល្អប្រសើរស្រប និងការលើកឡើងរបស់Ethel(2000)ដែលថាគ្រូបង្រៀនដែលមានចំណេះដឹងឯកទេស និងមានចំណេះដឹងគ្រប់កោសល្យខ្ពស់អាចធ្វើអោយការបង្រៀនរបស់ពួក។

### ៤.២.២. កម្រិតសញ្ញាបត្ររបស់គ្រូភាសាអង់គ្លេស

| កម្រិតសញ្ញាបត្រ | ចំនួន | ភាគរយ |
|---|---|---|
| សញ្ញាបត្រទុតិយភូមិ | ៤នាក់ | ២០% |
| សញ្ញាបត្របរិញ្ញាបត្រ | ១៤នាក់ | ៧០% |
| សញ្ញាបត្របរិ.ជាន់ខ្ពស់ | ២នាក់ | ១០% |

តាមទិន្នន័យអំពីកម្រិតអប់រំចុងក្រោយរបស់គ្រូបង្រៀនភាសាអង់គ្លេសបានបង្ហាញថាគ្រូភាសាអង់គ្លេសដែលបានបង្រៀននៅថ្នាក់ទី ៧ ទី ៨និងទី ៩ ភាគច្រើនមានកំរិតសញ្ញាប័ត្រចុងក្រោយខ្ពស់។ ក្នុងចំណោមនេះមាន ៧០% នៃគ្រូទាំងអស់មានសញ្ញាបត្របរិញ្ញាបត្រនិង១០%ទៀតបានប្រឹងប្រែងបន្តការសិក្សារបស់ខ្លួនរហូតទទួលបានសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់។ បន្ថែមទៅលើចំណុចដែលទាក់ទងទៅនឹងកម្រិតសញ្ញាបត្ររបស់គ្រូបង្រៀននេះដែរ អ្នកសិក្សាស្រាវជ្រាវបានប្រើសំណួរមួយទៀតសួរទៅលើកទៀតសំណាកពីរផ្សេងគ្នាគឺ គ្រូ និងសិស្ស តើនៅពេលដែលគ្រូមានសមត្ថភាពខ្ពស់អាចជួយសិស្សឱ្យឆាប់យល់មេរៀនដល់កម្រិតណា។ ជាលទ្ធផលធៀបសំណាកទាំងពីរ បានផ្តល់ចម្លើយ គឺថាគ្រូបង្រៀន

ប្រមាណ ជា៣០% និងសិស្ស៤០% បានគិតថា គ្រូបង្រៀនដែលមានសមត្ថភាពខ្ពស់ពិតជាអាចជួយសិស្សឱ្យឆាប់យល់មេរៀនបានខ្លាំងណាស់ និងខ្លាំង។ ចំណែកឯសិស្សប្រមាណ ៩% គិតថាគ្រូបង្រៀនដែលមានសមត្ថភាពខ្ពស់ឥទ្ធិពលអោយសិស្សឆាប់យល់មេរៀនបានខ្លាំងណាស់ និងប្រមាណ ៤០% និង ៥០% បានគិតត្រឹមខ្លាំង និងមធ្យម។ អត្រារួមស្មើរតែទាំងស្រុងនៃអ្នកចូលរួមមានជំនឿថា ការរៀនសូត្របានខ្ពស់របស់គ្រូ គឺបានចូលរួមចំណែកក្នុងការជួយសិស្សរបស់ពួកគាត់ឱ្យយល់មេរៀនបានច្បាស់ល្អ។ ការសិក្សាស្រាវជ្រាវនេះដូចទៅ និងការលើកឡើងរបស់Hayes(2004)ដែលថាគ្រូបង្រៀន គួរតែមានសញ្ញាបត្រយ៉ាងហោចណាស់កម្រិតបរិញ្ញាបត្រជាមូលដ្ឋាន ដើម្បីមានសមត្ថភាពគ្រប់គ្រាន់ក្នុងការផ្ទេរចំណេះដឹងទៅឱ្យសិស្ស ពីព្រោះវាអាចជួយជានា ដល់ការបង្រៀនឱ្យសិស្សអាចទទួលបានលទ្ធផលនៃការសិក្សាខ្ពស់។

### ៤.២.៣. បទពិសោធន៍បង្រៀនរបស់គ្រូភាសាអង់គ្លេស

| បទពិសោធន៏បង្រៀន | ចំនួន | ភាគរយ |
|---|---|---|
| តិចជាង៥ឆ្នាំ | ៣នាក់ | ១៥% |
| ៦-១០ឆ្នាំ | ១១នាក់ | ៥៥% |
| ១១-១៥ឆ្នាំ | ៤នាក់ | ២០% |
| ច្រើនជាង១៥ឆ្នាំ | ២នាក់ | ១០% |

តាមតារាងខាងលើបានបង្ហាញថា គ្រូបង្រៀនភាសាអង់គ្លេសនៅតាមសាលាគោលដៅដែលអ្នកសិក្សាស្រាវជ្រាវបានចុះប្រមូលទិន្នន័យសុទ្ធតែជាគ្រូដែលមានបទពិសោធន៍។ ក្នុងនោះមានគ្រូប្រហែល ៥% ដែល មានបទពិសោធន៍បង្រៀន តិចជាង ៥ឆ្នាំ និង មានគ្រូ ប្រមាណជាង ៥៥% ដែលមានបទពិសោធន៍បង្រៀនចន្លោះពី ៦ឆ្នាំទៅ ១០ឆ្នាំ។ ខណៈមានគ្រូប្រមាណ ២០% មានបទពិសោធន៍បង្រៀនភាសាអង់គ្លេស នៅចន្លោះពី ១១ឆ្នាំ ទៅ ១៥ ឆ្នាំ។ ទោះយ៉ាងនេះក្តី នៅពេលនិយាយពីបទពិសោធន៍រៀនភាសាអង់គ្លេស នៅកម្រិតអនុវិទ្យាល័យ អ្នកសិក្សាស្រាវជ្រាវរកឃើញថា គ្រូប្រហែលជា១០% ដែលមានបទពិសោធន៍បង្រៀនច្រើនជាង ១៥ឆ្នាំ។ ក្នុងនេះដែរលោកនាយកសាលា បានលើកឡើងថា គ្រូដែលគាត់ដាក់ឱ្យបង្រៀននៅថ្នាក់ទាំងអស់នេះ គឺសុទ្ធតែជាគ្រូដែលមានបទពិសោធន៍បង្រៀនច្រើនឆ្នាំ និងមាន

ចំណេះដឹងជ្រៅជ្រះ ពីព្រោះ ពួកគាត់សុទ្ធតែបានបណ្តុះបណ្តាល នៅគរុកោសល្យភូមិភាគទាំងអស់ ហើយគ្រូខ្លះទៀត ក៏បានបន្តរៀនយកសញ្ញាប័ត្របរិញ្ញាបត្រ នៅតាមសាកលវិទ្យាល័យនានានៅក្នុងប្រទេស។ សរុបជារួមគ្រូដែលត្រូវចាត់តាំងឱ្យបង្រៀនភាសាអង់គ្លេសនៅកម្រិតអនុវិទ្យាល័យគឺសុទ្ធជាគ្រូ ដែលមានសមត្ថភាព និងមានបទពិសោធន៍ច្រើនឆ្នាំដែលនាំឱ្យការបង្រៀនរបស់ពួកគាត់បានល្អ និងជាកត្តាជំរុញឱ្យលទ្ធផលសិក្សារបស់សិស្សបានកាន់តែប្រសើរឡើង។

### ៤.២.៤. ការទទួលបានការបណ្តុះបណ្តាលបន្ថែម៥ឆ្នាំចុងក្រោយរបស់គ្រូ

បើយោងតាមលទ្ធផលការស្រាវជ្រាវបានបង្ហាញថា គ្រូទាំងអស់ដែលត្រូវជ្រើសរើសជាសំណាកក្នុងសំណួរចម្លើយមានគ្រូចំនួន៨០% នៃគ្រូបង្រៀនភាសាអង់គ្លេសនៅកម្រិតអនុវិទ្យាល័យ មិនដែលទទួលបានការចូលរួមវគ្គបំប៉នបន្ថែម ឬសិក្ខាសាលាទាក់ទងនឹងគរុកោសល្យ ឬវិធីសាស្ត្របង្រៀនភាសាអង់គ្លេសក្នុងរយៈពេល ៥ ឆ្នាំចុងក្រោយនេះទេ។តែទោះជាយ៉ាងណាគ្រូប្រមាណជា ២០% ផ្សេងទៀតមានឱកាស បានចូលរួមវគ្គបណ្តុះបណ្តាលឬសិក្ខាសាលានានា។ បើតាមការផ្តល់សម្ភាសន៍ របស់លោកនាយក នៃសាលាគោលដៅទាំងអស់នោះ បានលើកឡើងថាគ្រូភាសាអង់គ្លេសដែលត្រូវបានជ្រើសរើសឱ្យចូលរួមវគ្គបណ្តុះបណ្តាលខ្លីភាគច្រើន គឺជាប្រធាន ឬអនុប្រធានក្រុមបច្ចេកទេស ។ មូលហេតុដែលលោកនាយកបញ្ជូន លោកគ្រូ អ្នកគ្រូដែលជាប្រធានក្រុម ឬអនុប្រធានក្រុមបច្ចេកទេស ព្រោះពេលខ្លះវាជាតម្រូវការរបស់ក្រសួង ឬភាគីដែលជាអ្នករៀបចំ។ ប៉ុន្តែពេលខ្លះ វាជាការសម្រេចចិត្តរបស់លោកនាយកសាលាផ្ទាល់តែម្តង ដោយសារពួកគាត់យល់ឃើញថា ប្រធានក្រុម ឬអនុប្រធានក្រុមបច្ចេកទេសមានឱកាសចែករំលែកចំណេះដឹងផ្សេងៗដែលពួកគាត់ទទួលបាន បន្ទាប់ពីការចូលរួមវគ្គបំពាក់បំប៉នរួចមក ទៅកាន់សមាជិកក្រុមបច្ចេកទេសដទៃទៀត។ ជាការសន្និដ្ឋានការដែលទទួលបានការចូលរួមបណ្តុះបណ្តាលបន្ថែមរបស់គ្រូហាក់ដូចជានៅក្រោមមូលដ្ឋាននៅឡើយ ដែលផ្ទុយពីការលើកឡើងរបស់Mao(2013)ថាគ្រូបង្រៀនចាំបាច់ត្រូវទទួលបានការបណ្តុះបណ្តាលបន្ថែមដើម្បីពង្រឹងសមត្ថភាពពីព្រោះ ប្រសិនបើពួកគាត់មានសមត្ថភាពពួកគាត់ពិតជាមានភាពជឿជាក់ក្នុងការបង្រៀន ប្រកបដោយប្រសិទ្ធភាពខ្ពស់។

### ៤.២.៥. អត្ថប្រយោជន៍នៃការបណ្តុះបណ្តាលបន្ថែម

| អត្ថប្រយោជន៍នៃការបណ្តុះបណ្តាលបន្ថែម | ចំនួន | ភាគរយ |
|---|---|---|
| ល្អណាស់ | ៥នាក់ | ២៥% |
| ល្អ | ៤នាក់ | ២០% |
| មធ្យម | ១០នាក់ | ៥០% |
| តិចតួច | ១នាក់ | ៥% |
| អត់សោះ | 0 | 0% |

នៅក្នុងការសិក្សាស្រាវជ្រាវនេះដែរ អ្នកសិក្សាស្រាវជ្រាវបានចោទសួរថា តើលោកគ្រូ អ្នកគ្រូគិតថា ការចូលរួមវគ្គបណ្តុះបណ្តាលខ្លី ឬសិក្ខាសាលាមានប្រយោជន៍ដល់ការបង្រៀន ឬការប្រើប្រាស់សៀវភៅសិក្សារបស់លោកគ្រូ អ្នកគ្រូបានកំរិតណា។ ជាលទ្ធផលលោកគ្រូ អ្នកគ្រូចំនួនមួយ ២៥% បានជ្រើសរើសយក វាពិតជាមានសារៈប្រយោជន៍ណាស់ ពីព្រោះវាបានជួយគាត់ឱ្យមានប្រសិទ្ធភាពបន្ថែមទៀត ទៅលើការបង្រៀន និងប្រើប្រាស់សៀវភៅរបស់ពួកគាត់។ ដូច្នេះការអភិវឌ្ឍសមត្ថភាពរបស់គ្រូជាប្រចាំគឺជាចលករដ៏សំខាន់ ដែលក្រសួងអប់រំ ក៏ដូចជាភាគីពាក់ព័ន្ធនានា គួរយកចិត្តទុកដាក់ដើម្បីធានាថាគ្រូបង្រៀនអាចមានសមត្ថភាពជំនាញសតវត្សទី២១គ្រប់គ្រាន់ក្នុងការផ្ទេរចំណេះដឹងទៅឱ្យសិស្ស ប្រកបដោយគុណភាព និងប្រសិទ្ធភាពខ្ពស់។ តាមការបង្ហាញខាងលើនេះ ស្របទៅ និងការរកឃើញរបស់ Yoon(2007)ដែលថា គ្រូបង្រៀនទាំងអស់ត្រូវធ្វើបច្ចុប្បន្នភាពទៅលើសមត្ថភាព ចំណេះដឹងឯកទេសរួមទាំងទេពកុសល្យ ដើម្បីធានាដល់ការបង្រៀន និងការប្រើប្រាស់សៀវភៅប្រកបដោយប្រសិទ្ធភាពខ្ពស់។

### ៤.២.៦. ចំណាប់អារម្មណ៍គ្រូលើវគ្គបណ្តុះបណ្តាលបន្ថែម

| **ចំណាប់អារម្មណ៍** | ចំនួន | ភាគរយ |
|---|---|---|
| ប្រើប្រាស់សម្ភារឧបទេស | ៣នាក់ | ១៥% |
| ចិត្ត-គរុកោសល្យ | ៦នាក់ | ៣០% |
| បច្ចេកវិទ្យាព័ត៌មាន | ២នាក់ | ១០% |
| វិធីសាស្រ្តបង្រៀន | ៤នាក់ | ២០% |
| ពង្រឹងចំណេះដឹង | ៥នាក់ | ២៥% |

ចំណុចមួយទៀតដែលបន្ថែមទៅលើបណ្តុះបណ្តាលនេះដែរ អ្នកសិក្សាស្រាវជ្រាវបានបញ្ចូលវគ្គបំប៉នចំនួន ៥ ប្រភេទទៅក្នុងកម្រងសំណួរឱ្យលោកគ្រូ អ្នកគ្រូធ្វើការជ្រើសរើសចំនួន ៣ដែលពួកគាត់ថាវា

មានសារៈសំខាន់ជាងគេ ជួយដល់ការបង្រៀនរបស់គាត់។ ជាលទ្ធផលគ្រូដែលជ្រើសរើសយកចិត្ត-គរុកោសល្យមានចំនួន ៣០% ជ្រើសរើសយកវិធីសាស្ត្របង្រៀន មាន ២០% ជ្រើសរើសសម្ភារៈឧបទេស ១៥% លោកគ្រូដែលជ្រើសរើសព័ត៌មានវិទ្យា ចំនួន១០% និងពង្រឹងចំណេះដឹងភាសាអង់គ្លេស មាន ២៥%។ មួយវិញទៀត គ្រូបង្រៀនមួយចំនួន ក៏បានលើកជាសំណូមពរ ឱ្យក្រសួងអប់រំ

យុវជន និងកីឡា និងភាគីពាក់ព័ន្ធធ្វើយ៉ាងណារៀបចំឱ្យមានវគ្គបណ្ដុះបណ្ដាលបន្ថែម ដល់គ្រូបង្រៀនឱ្យបានជាប្រចាំ ជាពិសេសនៅពេលក្រសួងចេញសៀវភៅសិក្សា ឬកម្មវិធីសិក្សាលម្អិតថ្មីដើម្បីលើកកម្ពស់ដល់ការបង្រៀនរបស់ពួកគាត់ ជាពិសេសសម្រេចបានស្តង់ដារ និងលទ្ធផលសិក្សា។ តាមការបង្ហាញរបស់លោក គ្រូអ្នកគ្រូ ពិតជាត្រូវការចាំបាច់ក្នុងការទទួលបានការបំប៉នវិធីសាស្ត្របង្រៀន ដោយគាត់គិតថាការបង្រៀនមួយដែលមានគុណភាព និងប្រសិទ្ធភាព ត្រូវពឹងផ្អែកជាសំខាន់ទៅលើវិធីសាស្ត្របង្រៀនដែលអាចជួយឱ្យគុណភាពនៃការរៀនមានភាពល្អប្រសើរ។ ចំណុចខាងលើនេះស្រដៀង និងការសិក្សារបស់ ChengនិងAndy(2010)បាននិយាយថា ការបង្រៀនបានជោគជ័យគ្រូបង្រៀន ចាំបាច់ទាមទារឱ្យមានកម្រិតយល់ដឹងភាសាអង់គ្លេស គុណសម្បត្តិផ្ទាល់ខ្លួន សម្ភារៈបង្រៀន ព្រមទាំងជំនាញផ្នែកវិធីសាស្ត្របង្រៀនដែលជាកត្តាសំខាន់។

## ៤.៣. កម្មវិធីសិក្សាភាសាអង់គ្លេស

### ៤.៣.១. បំណែងចែកកម្មវិធីសិក្សាភាសាអង់គ្លេស




យោងតាមលទ្ធផលបង្ហាញថា គ្រូភាសាអង់គ្លេសនៅកម្រិតអនុវិទ្យាល័យ នៅតាមសាលាទាំង ៨ ស្មើនិង១០០% ភាគរយសុទ្ធតែមានបំណែងចែកកម្មវិធីសិក្សាប្រចាំឆ្នាំ សម្រាប់ប្រើប្រាស់គ្រប់គ្នា។ មួយវិញទៀតក្នុងចំណោមលោកគ្រូ អ្នកគ្រូទាំងនោះមានគ្រូចំនួន៨០% ដែលគិតថាមានបំណែងចែកកម្មវិធីសិក្សាប្រចាំឆ្នាំ សម្រាប់ប្រើប្រាស់ពិតជាមានសារៈប្រយោជន៍ខ្លាំងណាស់ ចំពោះការបង្រៀនរបស់ពួកគាត់ និងខណៈដែលលោកគ្រូ អ្នកគ្រូប្រមាណប្រហែល ១០% នៅមានភាពស្ទាក់ស្ទើរហើយបានត្រឹមគិតថាវាមានប្រយោជន៍ត្រឹមកម្រិតមធ្យម។ យោងតាមលទ្ធផលនេះ អ្នកសិក្សាស្រាវជ្រាវអាចសន្និដ្ឋានបានថា លោកគ្រូអ្នកគ្រូភាសាអង់គ្លេសនៅក្នុងសាលាទាំង៨ ភាគច្រើនពិតជាអាចបង្រៀនទាន់កម្មវិធីសិក្សាដែលបានកំណត់ដោយក្រសួងអប់រំ យុវជន និងកីឡា ឬមន្ទីរអប់រំ យុវជន និងកីឡាជាមិនខាន។ តាមរយៈបំណែងចែកកម្មវិធីសិក្សាប្រចាំឆ្នាំនេះ ហើយដែលគ្រូប្រើប្រាស់វាជាឯកសារសម្រាប់ចង្អុលបង្ហាញ ពួកគាត់ឱ្យបង្កើតបានជាផែនការបង្រៀនផ្ទាល់ខ្លួន ដើម្បីជួយឱ្យការបង្រៀន និងរៀនសម្រេចតាមពេលវេលា និងការកំណត់របស់កម្មវិធីសិក្សារបស់ក្រសួងដែលបានកំណត់។

### ៤.៣.២. ខ្លឹមសារក្នុងសៀវភៅសិក្សាគោល




តាមតារាងខាងលើបង្ហាញថា ការយល់ឃើញរបស់គ្រូបង្រៀនភាសាអង់គ្លេស និងសិស្សមានភាពប្រហាក់ប្រហែលគ្នាទៅនឹងខ្លឹមសារមេរៀន នៅក្នុងសៀវភៅសិក្សាគោល នៅកម្រិតអនុវិទ្យាល័យដែលក្រសួងអប់រំ យុវជន និងកីឡា ដាក់ឱ្យដំណើរការបង្រៀន និងរៀន បើធៀបទៅនិងសមត្ថភាពរបស់សិស្ស។ ដោយក្នុងចំណោមភាគសំណាកទាំងនោះមានគ្រូប្រមាណ ២០% បានគិតថាខ្លឹមសារមេរៀនក្នុងសៀវភៅសិក្សាគោលមានកម្រិតខ្ពស់ជាងសមត្ថភាពសិស្ស និងមានគ្រូប្រមាណជា ៨០%គិតថាវាមានភាពសមស្របទៅ និងសមត្ថភាពសិស្ស។ ជាមួយគ្នានេះដែរ មានសិស្សប្រហែល ៩១% បានគិតថា

ខ្លឹមសារមេរៀន ក្នុងសៀវភៅសិក្សាគោលសព្វថ្ងៃ មានកម្រិតសមស្របទៅ និងសមត្ថភាពរបស់ខ្លួន ក៏ប៉ុន្តែមានសិស្សចំនួន ៩% បានឆ្លើយថាវា មានកម្រិតខ្ពស់ជាង សមត្ថភាពរបស់ខ្លួន។ ដូចនេះយោងតាម

លទ្ធផលអ្នកសិក្សាស្រាវជ្រាវអាចសន្និដ្ឋានបានថាខ្លឹមសារមេរៀនមិនមែនជាបញ្ហាចោទចំពោះសមត្ថភាពសិស្សឡើយ។

ដូច្នេះគ្រូ និងសិស្សពិតជាអាចដំណើរការរៀន និងបង្រៀនរបស់ខ្លួនបានយ៉ាងរលូន និងងាយស្រួលជាក់ជាមិនខានឡើយ ស្របតាមការលើកឡើងរបស់Igawa(2009)ដែលថាសៀវភៅសិក្សាគោលដែលល្អ គួរតែមានលក្ខណៈសមស្របទៅ និងសមត្ថភាព និងចំណេះដឹងរបស់សិស្សពីព្រោះសៀវភៅសិក្សាគោលជាធាតុមួយដ៏សំខាន់ នៃកម្មវិធីសិក្សាហើយត្រូវបានគេចាត់ទុកថា ជាសម្ភារៈឧបទេសដ៏

សំខាន់បំផុតនៅក្នុងដំណើរការបង្រៀន និងរៀន។

### ៤.៣.៣.ចំណាប់អារម្មណ៍របស់សិស្សទាក់ទងនិងខ្លឹមសារមេរៀនក្នុងសៀវភៅ




តាមលទ្ធផលបង្ហាញថា ក្នុងចំណោមសំណាកក្នុងសាលាគោលដៅទាំងអស់ មានសិស្សប្រមាណ ៩៧% ដែលគិតថា សៀវភៅសិក្សាគោលដែលពួកគេកំពុងរៀនសព្វថ្ងៃនេះ មានភាពទាក់ទាញ និងជាទីចាប់អារម្មណ៍ ទាំងខ្លឹមសារមេរៀន រូបភាព និងទ្រង់ទ្រាយ ទំហំសៀវភៅ។ ទោះយ៉ាងណាក្តី ក៏នៅមានសិស្សប្រមាណ ៣%បានបង្ហាញពីចំណាប់អារម្មណ៍ពួកគេថា សៀវភៅសិក្សាគោលនេះ មិនសូវគួរឱ្យជាទីចាប់អារម្មណ៍ទៅលើសៀវភៅសិក្សាគោល ដែលក្រសួងអប់រំ យុវជន កីឡា បានដាក់ឱ្យដំណើរការសព្វថ្ងៃនេះ។ ផ្អែកទៅលើលទ្ធផលសិក្សាស្រាវជ្រាវនេះ អាចបង្ហាញឱ្យយើងឃើញថា សកម្មភាពរៀនរបស់សិស្សអាចមានភាពរស់រវើក និងមានគុណភាពច្រើន ដោយសារខ្លឹមសារមេរៀន ភាគច្រើនផ្តោតទៅលើ

សមត្ថភាពសំខាន់ពីរគឺ(១) សមត្ថភាពស្តាប់ (២)សមត្ថភាពនិយាយដែលសុទ្ធសឹង ជាសមត្ថភាពត្រូវការធ្វើសកម្មភាពទាំងក្នុងថ្នាក់ និងក្រៅថ្នាក់។ លទ្ធផលនេះសមស្របទៅ និងការលើកឡើងរបស់ Igawa(2010)ដែលថាខ្លឹមសារមេរៀននៅក្នុងសៀវភៅសិក្សាគោល គួរតែធ្វើអោយមានការចាប់អារម្មណ៍ និងសមស្របសម្រាប់សិស្សគ្រប់កម្រិតសិក្សាហើយត្រូវផ្សារភ្ជាប់ទៅ និងជីវភាពរស់នៅប្រចាំថ្ងៃជាពិសេសតម្រូវការការងារក្នុងបរិបទប្រទេសកម្ពុជាផងដែរ។

### ៤.៣.៤. ចំនួនម៉ោងសិក្សាធៀបនិងចំនួនមេរៀន

ទោះបីមានការលើកឡើងថាខ្លឹមសារមេរៀនមិនមែនជាបញ្ហាចោទក៏ដោយ ក៏នៅតែមានចំណុចគួរឱ្យកត់សម្គាល់មួយចំនួនតូចដែរ។ ដោយចង់ដឹងពីគំនិត និងយោបល់លោកគ្រូ អ្នកគ្រូដែលបង្រៀនភាសាអង់គ្លេសនៅកម្រិតអនុវិទ្យាល័យ ទាក់ទងទៅនិងរបបម៉ោងបង្រៀន និងចំនួនមេរៀនដែលត្រូវបង្រៀនក្នុងមួយឆ្នាំ អ្នកសិក្សាស្រាវជ្រាវបានចោទជាសំណួរមួយថា តើចំនួនមេរៀនក្នុងសៀវភៅសិក្សាគោលសមស្របទៅ និងពេលវេលាដែលត្រូវដាក់ឱ្យបង្រៀនក្នុងមួយឆ្នាំដែរឬទេ។ ជាលទ្ធផលមានភាគសំណាក់ជាគ្រូបង្រៀនរហូតដល់ទៅ ៥០% ដែលគិតថាចំនួនមេរៀនក្នុងសៀវភៅសិក្សាគោល មិនសមស្របទៅនិងម៉ោងបង្រៀនដែលក្រសួងអប់រំ យុវជន និងកីឡា ផ្ដល់ឱ្យបង្រៀនក្នុងរយៈពេលមួយឆ្នាំនោះឡើយ។ខណៈដែលមានគ្រូប្រមាណ ៥០% ភាគរយដែលគិតថាសមស្រប។ ទាក់ទងទៅ និងចំណុចនេះដែរមានគ្រូបង្រៀនមួយចំនួន បានលើកជាសំណូមពរឱ្យក្រសួងអប់រំ យុវជន និងកីឡា កាត់មេរៀន ឬពង្រួញអត្ថបទអាន នៅក្នុងសៀវភៅសិក្សាគោលខ្លះចេញ ដើម្បីឱ្យមានមានលទ្ធភាពអាចបង្រៀនបានលម្អិតគ្រប់ចំណុច និងចប់កម្មវិធីដោយប្រសិទ្ធភាពខ្ពស់។ តាមលទ្ធផលនេះបង្ហាញថាគ្រូបង្រៀនភាសាអង់គ្លេសភាគច្រើនបង្រៀនមិនចប់កម្មវិធី ឬចប់ដែរតែចប់ដោយរំលងមេរៀន ឬកាត់សកម្មភាពលំហាត់ចោលដែលនាំឱ្យប៉ះពាល់ដល់លទ្ធផលសិក្សារបស់សិស្សពីមួយឆ្នាំ ទៅមួយឆ្នាំ។

### ៤.៣.៥. ចំនួនម៉ោងសិក្សាភាសាអង់គ្លេសក្នុង១សប្ដាហ៍

| ម៉ោងសិក្សា | គ្រប់គ្រាន់ | មិនគ្រប់គ្រាន់ |
|---|---|---|
| គ្រូ | ៥០% | ៥០% |
| សិស្ស | ៩១% | ៩% |

តាមការកំណត់របស់ក្រសួងអប់រំ យុវជន និងកីឡា សម្រាប់មុខវិជ្ជាភាសាអង់គ្លេសដាក់ឱ្យអនុវត្តនូវកម្រិតអនុវិទ្យាល័យក្នុងមួយថ្នាក់ គឺមានចំនួន៤ម៉ោង ក្នុងមួយសប្ដាហ៍។ ម៉ោងបង្រៀន និងរៀនភាសាអង់គ្លេសនេះ ជាកត្តាសំខាន់ណាស់ក្នុងការទទួលបានលទ្ធផលល្អប្រសើរ។ ដោយមើលឃើញបែបនេះទើបអ្នកសិក្សាស្រាវជ្រាវបានលើកសំណួរមួយសួរទៅភាគសំណាក ព្រោះចង់ដឹងពីការយល់ឃើញរបស់ពួកគាត់ថា តើចំនួនម៉ោងដែលកំណត់ដោយក្រសួងអប់រំ យុវជន និងកីឡា សម្រាប់ការបង្រៀន និងរៀន

ភាសាអង់គ្លេស។ លទ្ធផលគ្រូបង្រៀន ៥០% និងសិស្សចំនួន ៩១% បានយល់ឃើញថាចំនួនម៉ោងគឺគ្រប់គ្រាន់សម្រាប់ការបង្រៀន និងរៀនភាសាអង់គ្លេសនៅថ្នាក់កម្រិតអនុវិទ្យាល័យ។ ខណៈគ្រូបង្រៀនចំនួន ៥០% ទៀត និងសិស្សចំនួន ៩% ទៀតគិតថា ម៉ោងសម្រាប់ការបង្រៀន និងរៀនភាសាអង់គ្លេសគឺមិនទាន់គ្រប់គ្រាន់នៅឡើយទេ។ ពួកគាត់ចង់បង្ហាញថា គាត់ចង់បានម៉ោងសិក្សាបន្ថែមទៀតគឺ ៦ ម៉ោងក្នុងមួយសប្តាហ៍។ តាមចម្លើយខាងលើនេះ បញ្ជាក់ថាការកំណត់ម៉ោងបង្រៀនរបស់ក្រសួងអប់រំ យុវជន និងកីឡា បានតម្រូវឱ្យអនុវិទ្យាល័យអនុវត្តបានប្រសិទ្ធភាពបាន ១០០%។ បើតាមការលើកឡើងរបស់លោកនាយកសាលាថា សាលាបានរៀបចំកាលវិភាគតាមម៉ោងកំណត់របស់ក្រសួងគឺមាន៤ម៉ោងក្នុងមួយសប្តាហ៍ដើម្បីឱ្យការបង្រៀន និងរៀនភាសាអង់គ្លេសនៅកម្រិតវិទ្យាល័យ មានប្រសិទ្ធភាព និងលទ្ធផលសិក្សាអាចទទួលយកបាន។

## ៤.៤. សម្ភារឧបទេសសម្រាប់ទ្រទ្រង់ការប្រើប្រាស់សៀវភៅសិក្សា

| សម្ភារឧបទេស | គ្រូ | | | សិស្ស | | |
|---|---|---|---|---|---|---|
| | គ្រប់ពេល | ញឹកញាប់ | កម្រណាស់ | គ្រប់ពេល | ញឹកញាប់ | កម្រណាស់ |
| សៀវភៅសិក្សាគោល | ២៥% | ៤០% | ៣៥% | ៦៦% | ៣០% | ៤% |
| សៀវភៅគ្រូ | ៥% | ៥០% | ៤៥% | N/A | N/A | N/A |
| ម៉ាញ៉េចាក់ស៊ីឌី | ៥% | ៥% | ៩០% | ១២% | ១៥% | ៧៣% |
| បណ្ណរូបភាព/បណ្ណពាក្យ | ០% | ៥% | ៩៥% | ១២% | ១១% | ៧៧% |
| បន្ទប់អនុវត្តការស្តាប់ | ០% | ០% | ១០០% | ៨% | ៨% | ៨៤% |
| បណ្ណាល័យមានឯកសារភាសាអង់គ្លេស | ៥% | ៥% | ៩០% | ២៧% | ២៧% | ៤៦% |

បើនិយាយទាក់ទងទៅ និងកម្រិត នៃការប្រើប្រាស់សម្ភារៈទ្រទ្រង់ដល់ការប្រើប្រាស់សៀវភៅសិក្សាគោល អ្នកសិក្សាស្រាវជ្រាវបានប្រើសំណួរដូចគ្នាទៅកាន់ភាគសំណាកទាំងពីរគឺគ្រូ និងសិស្សលើកលែងតែសំណាកដែលសួរអំពីសៀវភៅគ្រូប៉ុណ្ណោះ ដែលអ្នកសិក្សាស្រាវជ្រាវសួរតែទៅលើលោកគ្រូ។ ជាលទ្ធផលបង្ហាញថា គ្រូចំនួន ២៥% បានឆ្លើយថា គ្រប់ពេលគាត់បានប្រើប្រាស់សៀវភៅសិក្សាគោលនៅពេលបង្រៀនសិស្ស ចំណែកសិស្សវិញចំនួន ៦៦% បានឆ្លើយថា ខ្លួនបានប្រើប្រាស់សៀវភៅពុម្ពគ្រប់ពេលរៀនភាសាអង់គ្លេស។ សំណួរដដែលសួរថាតើលោកគ្រូ អ្នកគ្រូបានប្រើប្រាស់សៀវភៅគ្រូបានកម្រិត

ណាគឺមានគ្រូចំនួន ៥% ដែលគាត់ឆ្លើយថា បានប្រើប្រាស់សៀវភៅគ្រូ គ្រប់ពេល ៥៥% ប្រើប្រាស់ញឹកញាប់ និង៤៥% ប្រើម្តងម្កាល។ ដោយផ្អែកទៅលើស្ថានភាពជាក់ស្តែង របស់សាលាគោលដៅទាំងអស់ដែលខ្វះ និងគ្មានសម្ភារៈទ្រទ្រង់ចាំបាច់សម្រាប់ឱ្យការប្រើប្រាស់សៀវភៅភាសាអង់គ្លេសមួយចំនួនទើបធ្វើឱ្យកម្រិត នៃការប្រើប្រាស់សម្ភារៈទាំងនោះមានកម្រិតក្រោមមូលដ្ឋានខ្លាំងណាស់។ ការលើកឡើងបែបនេះដោយសារ តែសិស្សប្រមាណ ៨៤% ដែលបានចូលរួមក្នុងការផ្តល់ព័ត៌មានបាននិយាយថា គ្រូរបស់ពួកគេ មិនសូវបានប្រើ ឬមិនប្រើតែម្តងនូវសម្ភារៈបង្រៀនមួយចំនួនដូចជាម៉ាញ៉េចាក់ស៊ីឌី ៧៣%អត់ប្រើបានរូបភាព ៨៤% មិនប្រើបន្ទប់ស្តាប់ ៧៧% និង ៤៦% ទៀត គឺបណ្ណាល័យគ្មានឯកសារជាភាសាអង់គ្លេស។ ទន្ទឹមគ្នានេះដែរមានគ្រូប្រមាណ៩០% បានឱ្យដឹងថាពួកគាត់មិនសូវបានប្រើ ឬប្រើតែម្តងនូវសម្ភារៈបង្រៀនមួយចំនួនដូចជា ម៉ាញ៉េចាក់ស៊ីឌី ៤៥% និងបណ្ណរូបភាព១០០% បន្ទប់អនុវត្តន៍ការស្តាប់ ៩០% បណ្ណាល័យគ្មានឯកសារភាសាអង់គ្លេស ៩៥% ។ បន្ថែមលើទិន្នន័យនេះលោកនាយក លោកគ្រូអ្នកគ្រូ សិស្សានុសិស្សបានលើកឡើង ស្រដៀងគ្នាទៅលើកម្រិត នៃការប្រើប្រាស់សម្ភារៈទ្រទ្រង់ការបង្រៀនរបស់គ្រូថា គ្រូបង្រៀននៅសាលារបស់គាត់ពុំសូវបានប្រើសម្ភារៈបង្រៀនឱ្យបានជាប់លាប់ទេ ពីព្រោះដោយសារតែកង្វះសម្ភារៈឧបទេស ប៉ុន្តែពួកគាត់តែងតែជំរុញ និងលើកទឹកចិត្តឱ្យគ្រូព្យាយាមប្រើប្រាស់សំភារៈដែលមាន និងអាចផលិតបានឱ្យអស់លទ្ធភាព។ សរុបមក គេមើលឃើញថាភាគសំណាកសុទ្ធតែបានអះអាងពីចំណុចអវិជ្ជមានរបស់គ្រូ ទៅលើការប្រើប្រាស់សម្ភារឧបទេសមិនគ្រប់គ្រាន់ ដែលរារាំងដល់ប្រសិទ្ធភាព នៃការរៀនរបស់សិស្ស នោះក៏ប្រហែលទាក់ទងដល់ការដែលសាលាមិនមានសម្ភារៈទាំងនោះ សម្រាប់ផ្តល់ឱ្យគ្រូផងដែរ។ ស្របនិង ការសិក្សានេះMosha,(2014)ក៏បានលើកឡើងដែរថា កង្វះសម្ភារៈទ្រទ្រង់ការបង្រៀនគឺជាកត្តាជះឥទ្ធិពលអវិជ្ជមាន ដល់ប្រសិទ្ធភាព នៃការប្រើប្រាស់សៀវភៅសិក្សាក៏ដូចការបង្រៀន និងរៀនផងដែរ។

### ៤.៥. សារៈប្រយោជន៍នៃការប្រើប្រាស់សម្ភារបង្រៀនរបស់គ្រូ

| សារៈប្រយោជន៍នៃការប្រើប្រាស់សម្ភារ | គ្រូ | សិស្ស |
|---|---|---|
| ខ្លាំងណាស់ | ២០% | ៤៣% |
| ខ្លាំង | ៧៥% | ៣១% |
| មធ្យម | ៥% | ២៣% |
| តិចតួច | 0% | 0% |
| អត់សោះ | 0% | 0% |

លោកគ្រូ អ្នកគ្រូទាំងអស់នៅតែគិតថា ការប្រើប្រាស់សម្ភារៈបង្រៀនគ្រប់គ្រាន់ គឺពិតជាមានប្រយោជន៍ខ្លាំងណាស់ ក្នុងការជួយដល់ការសិក្សារបស់សិស្ស សិស្សចងចាំមេរៀនបានយូរ ធ្វើឱ្យសប្បាយក្នុងការរៀនជញ្ជក់យកចំណេះដឹង និងចូលរួមគ្រប់សកម្មភាពទាំងអស់ក្នុងថ្នាក់រៀន ទោះបីជាការប្រើប្រាស់សម្ភារៈបង្រៀនរបស់ពួកគាត់នៅមានកំម្រិតទាបយ៉ាងណាក៏ដោយ។ នៅក្នុងថ្នាក់រៀន សម្ភារៈឧបទេសមិនត្រឹមតែ ជួយឱ្យសម្រេចវត្ថុបំណងនោះទេ ប៉ុន្តែវាថែមទាំងធ្វើឱ្យសិស្សកាន់តែចាប់អារម្មណ៍មកលើ ដំណើរការបង្រៀនរបស់គ្រូធ្វើឱ្យលទ្ធផល នៃការសិក្សារបស់សិស្សមានការប្រែប្រួលជាវិជ្ជមាន។ បើយោងតាមលទ្ធផលបង្ហាញឱ្យឃើញថាមានគ្រូ ៧៥% សុទ្ធតែទទួលស្គាល់ ពីអត្ថប្រយោជន៍ នៃការប្រើប្រាស់សម្ភារៈបង្រៀន។ ប្រហាក់ប្រហែលគ្នានេះដែរ មានសិស្សប្រមាណ ៤៣% ក៏បានគាំទ្រដែរថា ការប្រើប្រាស់សម្ភារៈបង្រៀនគ្រប់គ្រាន់របស់គ្រូនៅពេលគាត់បង្រៀនដែលធ្វើឱ្យពួកគេ សប្បាយក្នុងការរៀនសូត្រ និងឆាប់យល់មេរៀន។ ទោះជាយ៉ាងណាក៏នៅមានសិស្ស ២៣% ដែលយល់ឃើញថា ការប្រើប្រាស់សម្ភារៈជំនួយដល់ការបង្រៀនរបស់គ្រូ មានប្រយោជន៍តិចតួច ឬអត់ទាល់តែសោះដល់ការសិក្សារបស់ពួកគេ។ ស្របទៅ និងការលើកឡើងរបស់Klainin(2009 )ដែលថាសម្ភារទ្រទ្រង់ការបង្រៀន និងរៀនផ្តល់សារៈសំខាន់យ៉ាងខ្លាំងដល់ការសិក្សាភាសាបរទេស ពីព្រោះសម្ភារៈសិក្សាមានទំនាក់ទំនងយ៉ាងខ្លាំងទៅលើគុណភាព នៃការបង្រៀនរបស់គ្រូដែលជាយាននាំទៅដល់ការបង្កើនលទ្ធផលសិក្សារបស់សិស្ស។

### ៤.៦. វិធីសាស្ត្របង្រៀនភាសាអង់គ្លេស

#### ៤.៦.១. សកម្មភាពប្រើប្រាស់សៀវភៅសិក្សាក្នុងថ្នាក់

| **សកម្មភាពប្រើប្រាស់សៀវភៅ** | គ្រប់ពេល | ញឹកញាប់ | ពេលខ្លះ | កម្រណាស់ | អត់សោះ |
|---|---|---|---|---|---|

| | | | | | |
|---|---|---|---|---|---|
| សិស្សអានសៀវភៅម្នាក់ឯង | ១៥% | ៤៥% | ៣០% | ៥% | ៥% |
| សិស្សអានសៀវភៅជាដៃគូ | ១៥% | ៥៥% | ២៥% | ៥% | ០% |
| សិស្សអានសៀវភៅជាក្រុម | ៣០% | ២៥% | ៣០% | ១៥% | ០% |
| សិស្សទាំងអស់អានរួមគ្នា | ១៥% | ១៥% | ២៥% | ២៥% | ២០% |

និយាយពីសកម្មភាពបង្រៀនរបស់គ្រូភាសាអង់គ្លេស នៅកម្រិតអនុវិទ្យាល័យ អ្នកសិក្សាស្រាវជ្រាវមានបំណងចង់ដឹងពី កម្រិតនៃការប្រើប្រាស់សកម្មភាពមួយចំនួនរួមមាន សកម្មភាពសិស្សអានសៀវភៅម្នាក់ឯង សិស្សអានសៀវភៅជាគូរ សិស្សអានសៀវភៅជាក្រុម និងសិស្សទាំងអស់គ្នាអានសៀវភៅរួមគ្នា។ តាមរយៈទិន្នន័យទទួលបានបង្ហាញថា មានភាគសំណាកប្រហែល ១៥% បានគិតថា គ្រូបង្រៀនបានប្រើប្រាស់សកម្មភាពគ្រប់ពេល ប្រហែល ៤៥% គិតថាប្រើប្រាស់ញឹកញាប់ ប្រមាណ ៥% ជ្រើសរើសយកកម្រណាស់ និង ៥% ផ្សេងទៀត បានគិតថា គ្រូបង្រៀនមិនដែលប្រើប្រាស់សកម្មភាពទាំងនោះសោះ។ តាមលទ្ធផលបង្ហាញថា គ្រូបង្រៀនភាសាអង់គ្លេសនៅកម្រិតអនុវិទ្យាល័យទាំង៨ ពិតជាបានព្យាយាមប្រើប្រាស់សកម្មភាពសិស្សទាំងអស់រៀងរាល់ពេល ដែលពួកគាត់បង្រៀន ដើម្បីអោយការបង្រៀនរបស់ពួកគាត់ទទួលបានប្រសិទ្ធភាព និងការចាប់អារម្មណ៍ពីសិស្ស។ ការលើកឡើងបែបនេះដោយផ្អែកទៅលើលទ្ធផល ដែលភាគសំណាក់បាន ជ្រើសរើសយកចម្លើយដែលថា គ្រូពេលខ្លះប្រើវិធីសាស្ត្រនេះ ពេលខ្លះប្រើវិធីសាស្ត្រនោះមានកំរិតភាគរយខ្ពស់ជាងគេ។

ជាការសន្និដ្ឋាន ការបង្រៀននៅសាលារៀនគោលដៅទាំង៨ អាចមានភាពល្អប្រសើរ ព្រោះគ្រូបង្រៀនភាគច្រើនចេះបត់បែន វិធីសាស្ត្របង្រៀនរបស់ខ្លួនទៅតាមកាលៈទេសៈ និងពេលវេលា។ ការរកឃើញនេះស្រប និងការលើកឡើងរបស់លោក ចៅ លិន(2011) មានវិធីសាស្ត្រណាល្អជាងគេនោះទេ ពោលគឺត្រូវចេះប្រើប្រាស់អោយស្របទៅតាមកាលៈទេសៈ នៃការបង្រៀន និងតាមភាពបត់បែនរបស់គ្រូ។

### ៤.៦.២. ការផ្តល់កិច្ចការផ្ទះ

| ចំនួនកិច្ចការផ្ទះ | គ្រូ | សិស្ស |
|---|---|---|
| ៤ដង | ៣០% | ២០% |
| ៣ដង | ១០% | ៥% |
| ២ដង | ៦០% | ៦៣% |

| | | |
|---|---|---|
| ១ដង | 0% | ១២% |
| អត់សោះ | 0% | 0% |

គ្រប់មុខវិជ្ជាមិនថា តែមុខវិជ្ជាភាសាអង់គ្លេសនោះទេ ដើម្បីឱ្យការសិក្សារបស់សិស្សមានភាពល្អប្រសើរ និងពង្រឹងការអនុវត្តន៍ ឬតាមដានការសិក្សារៀនសូត្ររបស់សិស្សឱ្យបានទៀងទាត់លោកគ្រូ អ្នកគ្រូទាំងអស់ ចាំបាច់ត្រូវតែដាក់កិច្ចកាឱ្យសិស្សយកទៅធ្វើនៅផ្ទះបន្ថែមពេលទំនេរ ព្រោះកិច្ចការទាំងនេះជួយឱ្យលោកគ្រូ អ្នកគ្រូ អាចវាយតម្លៃលើការសិក្សា របស់សិស្សបាន និងជួយជំរុញសិស្សអោយខិតខំប្រឹងប្រែងរៀនសូត្រ និងបង្កើនសកម្មភាពស្វ័យសិក្សារបស់ខ្លួន ព្រមទាំងជួយសិស្សខ្សោយ ឬសិស្សរៀនយឺតឱ្យបានល្អប្រសើរ។ ដើម្បីចង់ដឹងពីកម្រិត នៃការដាក់កិច្ចការផ្ទះឱ្យសិស្សធ្វើ អ្នកសិក្សាស្រាវជ្រាវបានលើកជាសំណួរសួរទៅកាន់ភាគសំណាក់គ្រូ និងសិស្ស។ តាមទិន្នន័យដែលបានប្រមូលមាន គ្រូប្រមាណ ៦០% បានលើកឡើងថា បានដាក់កិច្ចការឱ្យសិស្សធ្វើ២ ដងក្នុងមួយសប្តាហ៍ប្រហែល ១០%បានដាក់កិច្ចការឱ្យសិស្សធ្វើ១ដង ក្នុងមួយសប្តាហ៍។ ខណៈសិស្សចំនួន ៦៣% បានគិតថា គ្រូរបស់គេដាក់កិច្ចការផ្ទះឱ្យអនុវត្តបន្ថែម ២ដង ក្នុងមួយសប្តាហ៍ និងប្រមាណ ១២% ផ្សេងទៀតគិតថា គ្រូគាត់ដាក់កិច្ចការផ្ទះឱ្យធ្វើបន្ថែមមួយដងប៉ុណ្ណោះក្នុង ១សប្តាហ៍។ យោងតាមលទ្ធផលនេះ គេអាចសន្និដ្ឋានបានថា កម្រិតនៃការផ្តល់កិច្ចការផ្ទះឱ្យសិស្សធ្វើមានភាពល្អប្រសើរ ដោយសារមានគ្រូជាងពាក់កណ្តាលបានផ្តល់កិច្ចការការងារឱ្យសិស្សធ្វើនៅផ្ទះបានគ្រប់គ្រាន់ មិនច្រើនពេក និងមិនតិចពេក ស្របតាមការលើកឡើង របស់ Skaggs(2007 )ថាការឱ្យកិច្ចការសិស្សធ្វើនៅផ្ទះច្រើនពេក ធ្វើឱ្យបាត់បង់ចំណាប់អារម្មណ៍ នៃការសិក្សារបស់សិស្ស ប៉ុន្តែបើតិចពេកធ្វើឱ្យប៉ះពាល់ដល់លទ្ធផលសិក្សា យ៉ាងណាក្តី ការដាក់តិចការផ្ទះគួរតែសមល្មមមិនគួរច្រើនពេក ឬក៏តិចពេកនោះទេ។

### ៤.៦.៣. ការលើកទឹកចិត្ត

| ការលើកទឹកចិត្ត | គ្រូ | សិស្ស |
|---|---|---|
| គ្រប់ពេល | ៥0% | ៥៣% |
| ញឹកញាប់ | ៥0% | ៤១% |
| ម្តងម្កាល | 0% | ៦% |
| កម្រណាស់ | 0% | 0% |

ដើម្បីឱ្យការសិក្សារបស់សិស្សប្រសើរឡើង ការលើកទឹកចិត្តពីគ្រូវា ក៏ជាផ្នែកមួយដែលជួយជំរុញការសិក្សារបស់សិស្សឱ្យទទួលបានជោគជ័យ ដូច្នេះគ្រូបង្រៀនមុខវិជ្ជាភាសាអង់គ្លេសគ្រប់កម្រិតគួរតែធ្វើការលើកទឹកចិត្តសិស្សឱ្យបានច្រើនគ្រប់ពេលដែលគាត់បង្រៀន។ ត្រង់ចំណុចនេះលទ្ធផលនៃការប្រមូលទិន្នន័យបានបង្ហាញថា គ្រូបង្រៀនភាសាអង់គ្លេសនៅកំរិតអនុវិទ្យាល័យប្រមាណ ៥០% បានព្យាយាមលើកទឹកចិត្តដល់សិស្ស ក្នុងការរៀនសូត្ររបស់សិស្សានុសិស្សគ្រប់ពេល ចំនួន ៥០% ផ្សេងទៀតបានលើកឡើងថាពួកគាត់ បានធ្វើការលើកទឹកចិត្តដល់ការសិក្សារបស់សិស្សញឹកញាប់ ជាពិសេសនៅពេលដែលពួកគាត់បង្រៀន។ ជារួមអ្នកសិក្សាស្រាវជ្រាវអាចសន្និដ្ឋាន ថាការលើកទឹកចិត្តសិស្សពីសំណាក់គ្រូបង្រៀនភាសាអង់គ្លេសនៅគ្រប់សាលាគោលដៅទាំងអស់ មានភាពល្អប្រសើរច្រើន ដែលនាំឱ្យលទ្ធផលសិក្សារបស់សិស្សក៏មានភាពល្អប្រសើរផងដែរ។ ការលើកទឹកចិត្តសិស្សត្រូវបានគេចាត់ទុកជាកត្តាដែលជះឥទ្ធិពលដល់ល្បឿន និងកម្រិតនៃការសិក្សាភាសាបរទេសរបស់សិស្ស ហើយសិស្សដែលមានកម្រិតនៃការលើកទឹកចិត្តខ្ពស់តែងតែធ្វើបានល្អជាង សិស្សដែលមានកម្រិតនៃការលើកទឹកចិត្តទាប។

## ៤.៧. ការរៀបចំកិច្ចតែងការបង្រៀន

នៅត្រង់នេះអ្នកសិក្សាស្រាវជ្រាវចង់ដឹងពីកម្រឹត នៃការរៀបចំកិច្ចតែងការបង្រៀនរបស់លោកគ្រូ អ្នកគ្រូភាសាអង់គ្លេស នៅកម្រិតអនុវិទ្យាល័យ នេះដោយសារតែការរៀបចំកិច្ចតែងការបង្រៀនបានជួយឱ្យលោកគ្រូ អ្នកគ្រូបានគិតទុកជាមុននូវវត្ថុបំណងមេរៀន សកម្មភាព ឬដំណើរការក្នុងការបង្រៀន និងមួយវិញទៀត គឺអាចជាការបង្ហាញផ្លូវឱ្យគ្រូបង្រៀនភាសាអង់គ្លេស បានរៀបចំនូវសម្ភារៈឧបទេសនានាសម្រាប់ជួយសិស្សក្នុងការធ្វើសកម្មភាព។ លទ្ធផលដែលទទួលបានបង្ហាញថា លោកគ្រូ អ្នកគ្រូចំនួន ៩៥% បានលើកឡើងថា ពួកគាត់តែងតែធ្វើ និងរៀបចំកិច្ចតែងការបង្រៀនស្ទើរគ្រប់ពេលដែលពួកគាត់បង្រៀន។ ក្រៅពីនេះមានគ្រូតែចំនួន ៥% ប៉ុណ្ណោះដែលបានឆ្លើយថា ពួកគាត់មិនសូវបានធ្វើកិច្ចតែងការបង្រៀនគ្រប់ពេល និងគ្រប់មេរៀនពោលគឺធ្វើតែ ៥០% នៃមេរៀនទាំងអស់។ បើតាមការលើកឡើងរបស់លោកនាយកសាលាគោលដៅទាំងអស់ មានប្រសាសន៍ថា នៅក្នុងសាលារបស់ពួកគាត់តែងតែជំរុញលើកទឹកចិត្តលោកគ្រូ អ្នកគ្រូទាំងអស់ឱ្យខិតខំ ពង្រឹងការរៀបចំសៀវភៅរដ្ឋបាលទាំងអស់ ជាពិសេសគឺ

ការរៀបចំកិច្ចតែងការបង្រៀនតែម្តង។ ដើម្បីឱ្យសៀវភៅរដ្ឋបាលរបស់គ្រូទាំងអស់ដំណើរការ នាយកសាលាបានរៀបចំសៀវភៅទាំងអស់រួចហើយ ទើបចែកជូនគ្រូ។ ការធ្វើបែបនេះគាត់សង្កេតឃើញថាសៀវភៅរដ្ឋបាលគ្រូទាំងអស់ប៉ុន្មាន ៩០% មានលទ្ធផលប្រសើរ និងមានប្រសិទ្ធភាពជាងមុន។ នៅពេលសួរថា តើលោកនាយកធ្វើដូចម្តេចដើម្បីធានាថាលោកគ្រូ អ្នកគ្រូ បានធ្វើកិច្ចតែងការបង្រៀនគ្រប់ពេលដែលគាត់បង្រៀន។ លោកនាយកទាំងអស់បានបញ្ជាក់ថា ពួកគាត់តែងតែឱ្យលោកគ្រូ អ្នកគ្រូទាំងអស់ដែលបង្រៀននៅសាលារបស់គាត់យកសៀវភៅកិច្ចតែងការបង្រៀនមកឱ្យគណៈនាយកពិនិត្យ និងចុះហត្ថលេខា ជារៀងរាល់ខែព្រមទាំងចុះធ្វើអធិការកិច្ចផ្ទៃក្នុងជាប្រចាំ។ យោងតាមលទ្ធផល អាចសន្និដ្ឋានថាការរៀបចំមេរៀន សកម្មភាព នៃការបង្រៀន ឬការតាក់តែងកិច្ចតែងការបង្រៀនរបស់លោកគ្រូ អ្នកគ្រូភាសាអង់គ្លេស នៅក្នុងសាលាគោលដៅទាំង៨ មានភាពល្អប្រសើរ ដែលអាចធានាដល់ការបង្រៀនសម្រេចតាមវត្ថុបំណង និងមានប្រសិទ្ធភាពក្នុងសាលាទាំងនោះ។ ដូចការលើកឡើងរបស់ Woodward(2001 )ថាការធ្វើកិច្ចតែងការបង្រៀនរបស់លោកគ្រូវាបានជួយដល់សកម្មភាពសិក្សារបស់សិស្ស ពីព្រោះគ្រូរៀបចំកិច្ចតែងការបង្រៀន គ្រូតែងតែដាក់បញ្ចូលនូវសកម្មភាពសម្រាប់ឱ្យសិស្សអនុវត្តដែលនាំឱ្យសកម្មភាពសិក្សានៅក្នុងថ្នាក់រៀនទាំងនោះមានភាពល្អប្រសើរដែលជាកត្តានាំអោយសិស្សទទួលបានលទ្ធផលល្អក្នុងការសិក្សា។

## ៤.៨. បរិមាណសិស្សក្នុងថ្នាក់រៀន

### ៤.៨.១. ចំនួនសិស្សក្នុង១ថ្នាក់

| ចំនួនសិស្សក្នុង១ថ្នាក់ | ចំនួន | ភាគរយ |
|---|---|---|
| ៣៦-៤០ | ៥៦នាក់ | ១៩% |
| ៤១-៤៥ | ៩៦នាក់ | ៣២% |
| ៤៦-៥០ | ៩៥នាក់ | ៣១% |
| ច្រើនជាង៥១ | ៥៣នាក់ | ១៨% |

ចំនួនសិស្សនៅក្នុងថ្នាក់រៀនក៏ជា កត្តាមួយដែលមានផលជះទៅលើសកម្មភាព នៃការប្រើប្រាស់សៀវភៅសិក្សានៅក្នុងថ្នាក់រៀនផងដែរ។ គិតទៅដល់បញ្ហានេះ អ្នកសិក្សាស្រាវជ្រាវបានដាក់ជាចម្ងល់ទៅ

កាន់ភាគសំណាកឱ្យជួយស្រាយបំភ្លឺ ព្រោះចង់ដឹងថា នៅសាលាគោលដៅទាំងនោះមានសិស្សចំនួនប៉ុន្មាននាក់ក្នុងមួយថ្នាក់ៗ។ លទ្ធផលភាគសំណាកគិតជា មធ្យមប្រមាណជា ១៩% ជ្រើសរើសយកចម្លើយដែលថា មានសិស្សពី ៣៦ ទៅ ៤០នាក់ សិស្សចំនួន ៣២% បានជ្រើសរើសយកសិស្សក្នុងថ្នាក់ចំនួនពី ៤១ ទៅ ៤៥ នាក់ សិស្ស ៣១% បានជ្រើសរើសសិស្សក្នុងមួយថ្នាក់ពី ៤៦ ទៅ ៥០ នាក់ និងសិស្សប្រមាណជាង ១៨% ទៀតជ្រើសរើសយកសិស្សដែលមានសិស្សច្រើនជាង ៥០នាក់ ក្នុងមួយថ្នាក់។ សរុបជារួម តាមរយៈការជ្រើសរើសរបស់ភាគសំណាក់ឃើញថា សាលារៀនគោលដៅទាំងអស់មានសិស្សសមស្របទៅតាមនិយាមរបស់ក្រសួងអប់រំ យុវជន និងកីឡា បានកំណត់ចំនួនសិស្សពី ៣៥ ទៅ ៤០ នាក់ក្នុងមួយថ្នាក់នៅ មធ្យមសិក្សាបឋមភូមិឡើងទៅ។ ដោយផ្អែកលើលទ្ធផលនេះ សាលាទាំងនោះគ្មានផលអវិជ្ជមាន ជះទៅលើដំណើរការ នៃការប្រើប្រាស់សៀវភៅសិក្សារបស់សិស្សនោះទេ។

### ៤.៨.២. ឥទ្ធិពលអវិជ្ជមាននៃឥទ្ធិពលអវិជ្ជមាននៃចំនួនសិស្សច្រើនក្នុងមួយថ្នាក់

| ឥទ្ធិពលអវិជ្ជមាននៃចំនួនសិស្សច្រើនក្នុងមួយថ្នាក់ | គ្រូ | សិស្ស |
|---|---|---|
| ខ្លាំងណាស់ | ១០% | ១% |
| ខ្លាំង | ៨០% | ២៨% |
| មធ្យម | ១០% | ៦៦% |
| តិចតួច | ០% | ៥% |
| អត់សោះ | ០% | ០% |

តាមការចង់សិក្សាពីអ្នកចូលរួមទាំងពីរ ពីភាគសំណាកគ្រូ និងសិស្សទាក់ទិនទៅ និងទំនាក់ទំនងរវាងចំនួនសិស្សក្នុងមួយថ្នាក់ៗ និងកត្តាជះឥទ្ធិពលរបស់វា អ្នកសិក្សាស្រាវជ្រាវបានលើកឡើងជាសំណួរបន្ថែមទៀត ថាតើចំនួនសិស្សច្រើននៅក្នុងថ្នាក់អាចនាំឱ្យជះឥទ្ធិពលអវិជ្ជមានខ្លាំងដល់ការប្រើប្រាស់សៀវភៅ និងការបង្រៀនរបស់លោកគ្រូ អ្នកគ្រូដល់កម្រិតណា។ តាមលទ្ធផលដែលមានគ្រូចំនួន ១០% បានគាំទ្រថា ចំនួនសិស្សច្រើននៅក្នុងថ្នាក់ពិតជាជះឥទ្ធិពលអវិជ្ជមានខ្លាំងណាស់ ដល់ការបង្រៀនរបស់ពួកគាត់ ខណៈមានគ្រូចំនួន ៨០% ដែលគិតថាអវិជ្ជមានខ្លាំង សម្រាប់ពួកគាត់។ បើមើលទៅលើចម្លើយរបស់សិស្សវិញ មានភាពខុសគ្នារវាងការគិតរបស់គ្រូ ពីព្រោះតែមានតែ ១% ប៉ុណ្ណោះដែលគាំទ្រថា ចំនួនសិស្សច្រើនក្នុងថ្នាក់ ជះឥទ្ធិពលអវិជ្ជមានដល់ការសិក្សារបស់ពួកគេ ខណៈមានសិស្សរហូតចំនួន ៦៦%

ដែលគិតថាមានផលអវិជ្ជមានមធ្យម និងមានចំនួន ៥% ប៉ុណ្ណោះ ដែលគិតថា មានការជះឥទ្ធិពលតិចតួច ឬមិនមានប៉ះពាល់ទៅលើដំណើរការ នៃការរៀនសូត្រនៅក្នុងថ្នាក់របស់ពួកគេឡើយ។ ការសិក្សានេះស្របទៅនឹងការលើកឡើងរបស់Blatchford(2003 )ដែលថាក្នុងថ្នាក់រៀនមួយដែលមានសិស្សច្រើននាំឱ្យគ្រូបានចំណាយពេលច្រើនទៅលើការគ្រប់គ្រងថ្នាក់រៀន ហេតុដូចនេះមិនមានពេលវេលាដាក់សកម្មភាពឱ្យសោះធ្វើច្រើនឡើយ។ ជាលទ្ធផលនៅក្នុងថ្នាក់រៀនដែលមានសិស្សច្រើន គឺមិនសូវទទួលបានផលល្អដូចថ្នាក់ដែលមានចំនួនសិស្សតិចនោះទេ ពោលគឺចំនួនសិស្ស ក៏ជាកត្តាជះឥទ្ធិពលដល់លទ្ធផលសិក្សារបស់សិស្សផងដែរ។

## ៤.៩. ស្ថានភាពសិក្សារបស់សិស្ស

| សកម្មភាព | ល្អណាស់ | ល្អ | បង្គួរ | មធ្យម | ខ្សោយ |
|---|---|---|---|---|---|
| មករៀនទៀងទាត់ និងទាន់ពេលវេលា | ១៨% | ៦០% | ១៦% | ៦% | 0% |
| យកចិត្តទុកដាក់ក្នុងម៉ោងសិក្សា | ៣២% | ៤៦% | ១៨% | ៤% | 0% |
| ចូលរួមធ្វើសកម្មភាពៗដែលគ្រូដាក់ឱ្យធ្វើក្នុងថ្នាក់ | ៤៨% | ៣៩% | ១១% | ២% | 0% |
| ធ្វើកិច្ចការផ្ទះដែលគ្រូដាក់ឱ្យទៀងទាត់ | ២៧% | ៣៨% | ៣៤% | ១% | 0% |

ក្នុងការលើកស្ទួយដល់សកម្មភាពសិស្សឱ្យមានសកម្ម យើងចាំបាច់ពឹងផ្អែកទៅលើកត្តារួមបញ្ចូលគ្នាជាច្រើន ក្នុងនោះ ការចូលរួមយ៉ាងសកម្ម និងផុសផុលដោយការពេញចិត្តរបស់សិស្សទៅលើផ្នែកជាច្រើនដូចជា៖ ការមករៀនទៀងទាត់ ការយកចិត្តទុកដាក់ស្តាប់គ្រូពន្យល់ ការចូលរួមក្នុងសកម្មភាពក្នុងថ្នាក់ និងកិច្ចការផ្ទះដែលគ្រូដាក់ឱ្យអនុវត្តជាដើម។ យោងតាមទិន្នន័យដែលទទួលបានពីគ្រូ និងសិស្សទាក់ទងទៅ និងការមករៀនទៀងទាត់ និងទាន់ពេលវេលាគឺអ្នកចូលរួមប្រមាណ ៦០%អះអាងថាសិស្សមករៀនទាន់ពេលវេលា និងបានត្រឹមត្រូវល្អ ស្របពេលដែលមានភាគសំណាកប្រហែល ១៦%បានជ្រើសរើសយកមធ្យម។ លើសពីនេះទៀត ចំពោះការយកចិត្តទុកដាក់ស្តាប់គ្រូក្នុងម៉ោងសិក្សាវិញ មានគ្រូ និងសិស្សប្រមាណ ៤៦% គិតថាសិស្សយកចិត្តទុកដាក់ខ្លាំង ក្នុងការស្តាប់ការពន្យល់មេរៀនរបស់គ្រូ។ ហើយតួលេខដែលគិតថា សិស្សមិនសូវស្តាប់គ្រូមាន៤%។ ចំណុចមួយទៀតគ្រូ និងសិស្សដែលបានចូលរួមឆ្លើយសំណួរចំនួន ៤៨% ដែលឆ្លើយថាសិស្សចូលរួមធ្វើសកម្មភាពផ្សេងៗ ដែលគ្រូដាក់ឱ្យក្នុងថ្នាក់បាន

ល្អណាស់ និង ៣៩% ទៀត ជ្រើសរើសយកល្អ និងស្របគ្នានេះដែរ មានអ្នកចូលរួមប្រហែល ១៣% ដែលគិតថា សិស្សមិនសូវចូលរួម និងអនុវត្តន៍តាមសកម្មភាពដែលគ្រូប្រាប់ឱ្យធ្វើនោះទេ។ បើនិយាយទៅលើកិច្ចការដែលគ្រូដាក់ឱ្យយកទៅធ្វើនៅផ្ទះវិញ មានភាគសំណាកប្រហែល ២៨% ដែលគិតថាបានខិតខំប្រឹងប្រែងធ្វើកិច្ចការផ្ទះបានល្អណាស់ ខណៈដែលចំនួនអ្នកចូលរួមប្រមាណ ៣៥% ដទៃទៀត បានលើកឡើងថា សិស្សមិនសូវធ្វើ ឬអត់ធ្វើកិច្ចការផ្ទះពួកគេទៀងទាត់នោះទេ។ បើទៅមើលទិន្នន័យ ដែលទទួលបានខាងលើ អ្នកសិក្សាស្រាវជ្រាវអាចទាញសេចក្តីសន្និដ្ឋានបានថា ស្ថានភាពការសិក្សារបស់សិស្សនៅមានកម្រិតនៅឡើយដោយសារតែទិន្នន័យដែលទទួលបានពី សាលាគោលដៅទាំង៨ ឃើញថាអ្នកចូលរួមជ្រើសរើសយកចម្លើយមធ្យម និងក្រោមមូលដ្ឋានមានរហូតដល់ទៅ ៣៤% ។ ដូច្នេះនាំឱ្យលទ្ធផលសិក្សារបស់សិស្សក៏នៅមានកម្រិតផងដែរ។

# ជំពូកទី៥

# សេចក្តីសន្និដ្ឋាន

# និង

# សំណូមពរ

# ជំពូកទី៥

# សេចក្តីសន្និដ្ឋាន និង សំណូមពរ

## ៥.១. សេចក្តីសន្និដ្ឋាន

ជាការសន្និដ្ឋាន ស្ថានភាពនៃការប្រើប្រាស់សៀវភៅសិក្សាភាសាអង់គ្លេសនៅកម្រិតអនុវិទ្យាល័យក្នុងខេត្តស្វាយរៀងមានកម្រិតវិជ្ជមានច្រើនគួរឱ្យកត់សម្គាល់ ហើយមានការឆ្លើយតបខ្ពស់ទៅនឹងអ្វី ដែលអ្នកសិក្សាស្រាវជ្រាវកំពុងស្វែងរក ដើម្បីបានចូលរួមជាចំណែកដ៏តូចមួយក្នុងការកែលម្អស្ថានភាពនៃការប្រើប្រាស់សៀវភៅភាសាអង់គ្លេសនៅនៅថ្នាក់ទី ៧ ទី ៨ និងទី ៩នៅសាលារដ្ឋឱ្យកាន់តែប្រសើរឡើង។

ចំណុចវិជ្ជមានដែលអ្នកសិក្សាស្រាវជ្រាវបានរកឃើញទាំងនោះ គឺទាក់ទងទៅនឹងកម្រិតជំនាញគរុកោសល្យរបស់គ្រូបង្រៀនដែលបង្រៀនភាសាអង់គ្លេសនៅកម្រិតអនុវិទ្យាល័យដែលក្នុងនោះមានរហូតដល់ទៅ៨០% (តារាងទី២)មានកម្រិតគរុកោសល្យជាគ្រូបង្រៀនកម្រិតមូលដ្ឋាន ហើយក្នុងចំណោមគ្រូបង្រៀនទាំងនោះ មានរហូតជាង ៧០% (តារាងទី៣) មានកំរិតសញ្ញាប័ត្រចុងក្រោយយ៉ាងហោចណាស់បរិញ្ញាបត្រ និង គ្រូចំនួន១០% មានសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់ និងជាង ៥៥% មានបទពិសោធន៍ច្រើនជាង៥ ឆ្នាំ និង ១០%មានបទពិសោធន៍ច្រើនជាំង១៥ឆ្នាំ។ តាមលទ្ធផលនៃគ្រូបង្រៀននៅតាមសាលាគោលដៅទាំងនោះពិតជាអាចបង្រៀនសិស្សប្រកបដោយគុណភាព និងប្រសិទ្ធភាព។ ពាក់ព័ន្ធទៅនិងខ្លឹមសារមេរៀនវិញ បើធៀបទៅនិងសមត្ថភាពរបស់សិស្សគឺមិនមានបញ្ហាចោទនោះទេ ដោយសារមានសិស្សរហូតដល់ទៅ៩១% (តារាងទី ៩) យល់ថាខ្លឹមសារមេរៀនសមស្របទៅនិងសមត្ថភាពរបស់ខ្លួន។ ចំពោះការប្រើប្រាស់វិធីសាស្រ្តបង្រៀនរបស់គ្រូវិញ ក៏មានភាពល្អប្រសើរផងដែរ។ ដោយសារគ្រូបង្រៀនភាគច្រើន តែងតែប្រើវិធីសាស្រ្តចម្រុះទៅតាមពេលវេលានិងកាលៈទេសៈដែលពួកគាត់បង្រៀន។ លើសពីនេះទៅទៀត ក្នុងចំណោមគ្រូបង្រៀនទាំងនោះ គ្រូបង្រៀនរហូតដល់ទៅជាង ៩៥%(តារាងទី ១៧) បានរៀបចំកិច្ចតែងការបង្រៀនស្ទើរតែគ្រប់មេរៀន ដែលគាត់បង្រៀនដែលធ្វើអោយការបង្រៀនរបស់ពួកគាត់មានប្រសិទ្ធភាពខ្ពស់។ ម្យ៉ាងវិញទៀតចំពោះកម្រិតនៃការលើកទឹកចិត្តសិស្ស ពីសំណាក់គ្រូ

បង្រៀនភាសាអង់គ្លេសក៏មានភាពល្អប្រសើរ ស្របពេលដែលការផ្តល់តិចការឱ្យសិស្សធ្វើនៅផ្ទះក៏ឃើញថាសមគួរដែលអាចទទួលយកបាន។ចំណុចមួយទៀតនោះ គឺចំនួនសិស្សក្នុងមួយថ្នាក់មានចំនួនចន្លោះពី ៣៦ ទៅ ៤០នាក់ មានភាពល្អប្រសើរដែលចំនួនសិស្សក្នុងមួយថ្នាក់សមស្របទៅ និងនិយាមរបស់ក្រសួងអប់រំ យុវជន និងកីឡា ដែលបានកំណត់សិស្សពី ៣៥ ទៅ ៤៥នាក់ ក្នុងមួយថ្នាក់ៗ។

ទន្ទឹមនិងចំណុចវិជ្ជមាន អ្នកសិក្សាស្រាវជ្រាវក៏បានរកឃើញនូវបញ្ហាប្រឈមមួយចំនួនផងដែរ។ ជាក់ស្តែង អនុវិទ្យាល័យ និងវិទ្យាល័យទាំង ៨នៅខ្វះសម្ភារៈទ្រទ្រង់ចាំបាច់មួយចំនួនសម្រាប់ដំណើរការនៃការបង្រៀន និងរៀន ក្នុងការប្រើប្រាស់សៀវភៅភាសាអង់គ្លេស។ សាលាទាំងនោះស្ទើរតែមិនមានឧបករណ៍សម្រាប់ចាក់សំឡេងនិងបន្ទប់អនុវត្តន៍ស្តាប់និងមើលវីដេអូដែលបម្រើដល់បំណិនស្តាប់ និងសន្ទនា។ មួយវិញទៀត បណ្ណាល័យដែលមានឯកសារជាភាសាអង់គ្លេសសម្រាប់ឱ្យសិស្សពង្រីកការសិក្សាក្រៅថ្នាក់ក៏នៅមិនទាន់គ្រប់គ្រាន់។ ម្យ៉ាងវិញទៀតគ្រូភាសាអង់គ្លេសទាំងនោះមិនសូវឃើញបានប្រើប្រាស់សម្ភារៈឧបទេសងាយៗផ្សេងទៀត ដែលគាត់អាចផលិតបានដូចជា ប័ណ្ណរូបភាព ឬប័ណ្ណពាក្យសម្រាប់បម្រើដល់ការបង្រៀន និងរៀនក្នុងថ្នាក់នៅឡើយ ដែលទាក់ទងទៅនឹងការប្រើប្រាស់សៀវភៅភាសាអង់គ្លេស។ការសិក្សាស្រាវជ្រាវនេះ ក៏បានរកឃើញបន្តទៀតថា ការផ្តល់វគ្គបំប៉នគ្រូជាប្រចាំក៏នៅតែជាបញ្ហាប្រឈមដោយសារគ្រូបង្រៀនភាសាអង់គ្លេសទាំង៨ សាលាភាគច្រើនពុំដែលបានចូលរួមវគ្គបំប៉នឡើយនៅក្នុងរយៈពេល ៥ ឆ្នាំចុងក្រោយនេះ។ ដូច្នេះគ្រូបង្រៀនទាំងនោះ បានលើកជាសំណូមពរឱ្យមានការបើកវគ្គបំប៉នសមត្ថភាពដល់ពួកគាត់ ទៅលើជំនាញផ្សេងៗជាពិសេសនៅពេលដែលក្រសួងអប់រំ យុវជន និងកីឡា បានប្តូរសៀវភៅសិក្សាថ្មី និងវិធីសាស្រ្តបង្រៀនថ្មីៗទៀតតែម្តង។ លើសពីនេះទៅទៀត អ្នកសិក្សាស្រាវជ្រាវក៏បានរកឃើញដែរថានៅតាមសាលាគោលដៅមួយចំនួនតូចមិនទាន់អនុវត្តតាមសេចក្តីណែនាំរបស់ក្រសួងស្តីពីការកំណត់ម៉ោងបង្រៀនមុខវិជ្ជាភាសាអង់គ្លេស ៤ម៉ោងក្នុងមួយសប្តាហ៍ឱ្យបាន ១០០%នៅឡើយទេ។ បន្ថែមលើសពីនេះដែរ ចំនួនមេរៀននៅក្នុងសៀវភៅសិក្សាគោលនិងសកម្មភាពដែលត្រូវរៀនមិនសូវជាសមាមាត្រគ្នាទៅនិងម៉ោងបង្រៀន និងរៀន ក្នុងមួយសប្តាហ៍នៅឡើយដែរ ពោលគឺមានចំនួនមេរៀនច្រើន។ បើក្រឡេកទៅមើលស្ថានភាព នៃការខិតខំប្រឹងប្រែងសិក្សាភាសាអង់គ្លេសនៅ

កម្រិតអនុវិទ្យាល័យគឺនៅមានកម្រិតនៅឡើយ ដែលរួមចំណែកធ្វើឱ្យប៉ះពាល់ដល់គុណភាព និងប្រសិទ្ធភាពនៃការបង្រៀន និងរៀនភាសាអង់គ្លេសក្នុងខេត្តស្វាយរៀងនាពេលបច្ចុប្បន្ន។ រីឯបញ្ហាខ្វះសៀវភៅសិក្សាតាមកម្រិតថ្នាក់ ក៏នៅតែជាចំណុចខ្វះខាតរបស់លោកនាយកក្នុងការដឹកនាំ និងកៀងគរកសប្បុរសជនដើម្បីឱ្យពួកគាត់ជួយជាថវិកានិងសម្ភារៈដើម្បីទិញសៀវភៅសិក្សាភាសាអង់គ្លេសឱ្យបានគ្រប់គ្រាន់។

## ៥.២. សំណូមពរ

ដើម្បីដោះស្រាយបញ្ហាប្រឈមខាងលើនឹងជួយបង្កើនគុណភាពនិងប្រសិទ្ធភាពនៃការប្រើប្រាស់សៀវភៅភាសាអង់គ្លេសនៅកំរិតអនុវិទ្យាល័យ អ្នកសិក្សាស្រាវជ្រាវបានលើកជាសំណូមពរមួយចំនួនដូចខាងក្រោមៈ

## ក. ក្រសួងអប់រំ យុវជន និងកីឡា

-រៀបចំវគ្គបណ្តុះបណ្តាលស្តីពីវិធីសាស្ត្របង្រៀន ការផលិតសម្ភារៈឧបទេស និងចិត្តគរុកោសល្យផ្សេងៗជាប្រចាំដើម្បីធ្វើបច្ចុប្បន្នភាពនៃការបង្រៀនឱ្យដើរទាន់សតវត្សទី២១ ជាពិសេស វិធីសាស្ត្របង្រៀនបែបរិះរក គិតស៊ីជម្រៅ ការសហការដោះស្រាយបញ្ហា និងពលរដ្ឋសកលស្របទៅតាមក្របខណ្ឌកម្មវិធីសិក្សាថ្មី។

-គួរតែផ្តល់ឱ្យសាលារៀននូវ សម្ភារៈទ្រទ្រង់ការបង្រៀននិងរៀនភាសាអង់គ្លេសចាំបាច់មួយចំនួនដូចជា ឧបករណ៍សម្រាប់បម្រើឱ្យបំណិនស្តាប់ និងបានរូបភាពពណ៌។ ជាមួយគ្នានេះដែលត្រូវរៀបចំឱ្យសាលាទាំងអស់មានបណ្ណាល័យដែលមានឯកសារភាសាអង់គ្លេស ឬឯកសារបំរើឱ្យការបង្រៀន និងរៀនភាសាអង់គ្លេសដើម្បី ឱ្យសិស្សអាចមានលទ្ធភាពស្វ័យសិក្សាបង្កើនសមត្ថភាពភាសាអង់គ្លេសបន្ថែម ដែលនាំអោយមានគុណភាព និងប្រសិទ្ធភាពនៃការរៀន និងបង្រៀនភាសាអង់គ្លេសនៅតាមសាលារៀនរដ្ឋឱ្យកាន់តែប្រសើរឡើងពីមួយឆ្នាំទៅមួយឆ្នាំសិក្សា។

-ពិនិត្យលទ្ធភាពផ្តល់នូវសៀវភៅសិក្សាគោលទៅឱ្យសាលារៀនឱ្យបានគ្រប់គ្រាន់ នឹងទាន់ពេលវេលា និងឆ្នាំសិក្សា។

-គួរតែកាត់បន្ថយមេរៀន និងសកម្មភាពក្នុងមេរៀនមួយចំនួន ហើយបន្ថែមលំហាត់អនុវត្ត។

## ខ. មន្ទីរអប់រំ យុវជន និងកីឡា

-គួរតែអន្តរាគមន៍និងពិនិត្យតាមដានជាប្រចាំទៅលើការបង្រៀននិងរៀនហើយមួយវិញទៀតរាយការណ៍ដោះស្រាយឱ្យទាន់ពេលវេលារាល់តម្រូវការចាំបាច់របស់សាលារៀនទៅថ្នាក់លើបន្ត។

-គួរតែពង្រឹងរដ្ឋបាលគ្រូបន្ថែមទៅលើអ្វីដែលលោកគ្រូអ្នកគ្រូមានស្រាប់ពិសេសកិច្ចតែងការបង្រៀននិងសម្ភារៈឧបទេសងាយសមស្របតាមខ្លឹមសាររបស់មេរៀននីមួយៗ។

## គ. គណៈគ្រប់គ្រងសាលារៀន

-គួរតែលើកទឹកចិត្តគ្រូបង្រៀនឱ្យផលិតសម្ភារៈឧបទេសងាយៗស្របតាមខ្លឹមសាររបស់មេរៀននីមួយៗតាមរយៈការប្រជុំបច្ចេកទេសប្រចាំខែនិងប្រើប្រាស់សម្ភារៈឧបទេសក្នុងការបង្រៀនឱ្យអស់លទ្ធភាព។ មួយវិញទៀតគួរស្វែងរកដៃគូអភិវឌ្ឍន៍ដើម្បីឱ្យជួយឧបត្ថម្ភលើសៀវភៅសិក្សានិងសម្ភារៈទ្រទ្រង់ការបង្រៀនណាដែលគ្រូមិនអាចផលិតបាន។

-ពង្រឹងបទប្បញ្ញត្តិរបស់សាលារៀន និងវិន័យគ្រូឱ្យមានប្រសិទ្ធភាពខ្ពស់។

## ឃ. ចំពោះលោកគ្រូ អ្នកគ្រូ

-គួរតែស្វ័យសិក្សាស្រាវជ្រាវពីវិធីសាស្ត្រណាដែលថ្មីៗជាប្រចាំដើម្បីពង្រឹងចំណេះដឹងជំនាញវិជ្ជាជីវៈទៅលើអ្វីដែលខ្លួនមានស្រាប់។

-គួរតែពង្រឹងរដ្ឋបាលរបស់គ្រូបន្ថែមពីលើអ្វីដែលខ្លួនកំពុងធ្វើស្រាប់។

-ជំរុញលើកទឹកចិត្តសិស្ស និងពន្យល់ឱ្យពួកគេទទួលស្គាល់ពីគុណតម្លៃ និងអត្ថប្រយោជន៍នៃការសិក្សាភាសាអង់គ្លេស។

### ខ. ចំពោះសិស្សានុសិស្ស

-គួរពង្រឹងសមត្ថភាពខ្លួនឱ្យស្ទាត់ជំនាញទៅលើភាសាអង់គ្លេសដើម្បីឆ្លើយតបទៅនិងតម្រូវការទីផ្សារការងារនាពេលបច្ចុប្បន្ននិងទៅអនាគត។

## ៥.៣. ការស្រាវជ្រាវបន្ត

ការសិក្សាស្រាវជ្រាវមួយនេះបានធ្វើឡើងតែទៅលើថ្នាក់ទី ៧ ទី៨ និងទី ៩នៅតាមសាលាអនុវិទ្យាល័យ និងវិទ្យាល័យចំនួន ៨ ក្នុងស្រុកចំនួន ៥ ក្នុងខេត្តស្វាយរៀងតែប៉ុណ្ណោះ ដូច្នេះលទ្ធផលដែលរកឃើញអាចនៅចន្លោះប្រហោងនៅឡើយ។ ហេតុនេះអ្នកសិក្សាស្រាវជ្រាវក្រោយក្រោយដែលមានបំណងចង់សិក្សាស្រាវជ្រាវបន្តលើប្រធានបទនេះគួរតែពង្រីកដែនកំណត់ និងវិសាលភាពរបស់ខ្លួនឱ្យបានធំជាងនេះ ប្រសិនបើនៅតែមានបំណងចង់សិក្សានៅក្នុងខេត្តស្វាយរៀងដដែល។ ក្រៅពីនេះអ្នកសិក្សាស្រាវជ្រាវក្រោយក្រោយក៏អាចយកប្រធានបទនេះទៅសិក្សានៅទីប្រជុំជន ឬតំបន់ដាច់ស្រយាលនៅតាមបណ្តាខេត្តនានាផងដែរ ដោយសារតែគុណភាពសាលារៀន គុណភាពគ្រូបង្រៀន និងចំណេះដឹងភាសាអង់គ្លេសរបស់សិស្សនៅទីនោះអាចមានភាពខុសគ្នាឆ្ងាយពីស្ថានភាពនៅក្នុងស្រុកទាំង ៥ នៃខេត្តស្វាយរៀង។

# ឯកសារយោង

# ឯកសារយោង

របាយការណ៍បូកសរុបវាយតម្លៃការងារ អប់រំ យុវជន និងកីឡាខេត្តស្វាយរៀង ឆ្នាំសិក្សា ២០១៨-២០១៩ និងទិសដៅ ឆ្នាំសិក្សា ២០១៩-២០២០, ស្វាយរៀងៈ មន្ទីរអប់រំ យុវជន និងកីឡា ខេត្តស្វាយរៀង

NEP. (២០១៥).វិស័យអប់រំឆ្នាំ ២០៣០ សេចក្តីប្រកាសទីក្រុង អ៊ីន ឈុន និងក្របខណ្ឌសកម្មភាពឆ្ពោះទៅរកការអប់រំមានគុណភាព បរិយាបន្ន សមធម៌ និងការសិក្សាពេញមួយជីវិត សម្រាប់ទាំងអស់គ្នា, អ៊ីន ឈុន.NGO Education Partnership.

UNESCO. (២០១៥).ការអប់រំដើម្បីទាំងអស់គ្នាឆ្នាំ ២០០០-២០១៥:សមិទ្ធិផល និងបញ្ហាប្រឈម. ដាកា:UNESCO

ណារុន;ហ.(២០១៦) កំណែទម្រង់វិស័យអប់រំនៅកម្ពុជា: មាគ៌ាឆ្ពោះទៅរកសង្គមពុទ្ធិ និងវិបុលភាព. ភ្នំពេញ: ក្រសួងអប់រំ យុវជន និងកីឡា

ណារុន,ហ.ជ.(២០១៤).ផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ ២០១៥-២០១៨.ភ្នំពេញ.ក្រសួងអប់រំ យុវជន និងកីឡា

នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា(២០១៥).ក្របខណ្ឌកម្មវិធីសិក្សាចំណេះទូទៅនិងអប់រំបច្ចេកទេស. ភ្នំពេញ: ក្រសួងអប់រំ យុវជន និងកីឡា

នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា(២០១២)កម្មវិធីសិក្សាលម្អិតភាសាអង់គ្លេសសម្រាប់ថ្នាក់ទី៤ ទី៥ និងទី៦.ភ្នំពេញ: ក្រសួងអប់រំ យុវជន និងកីឡា

អូន,ធ(២០១៧). ការបង្រៀននិងរៀនភាសាអង់គ្លេសថ្នាក់ទី ១២ ក្នុងរាជធានីភ្នំពេញ. ភ្នំពេញ: វិទ្យាស្ថានជាតិអប់រំ

ពណ្ណរាយ,ស.រ.(២០១៧) ការអនុវត្តកម្មវិធីសិក្សាភាសាអង់គ្លេសនៅបឋមសិក្សាសាធារណៈ. ភ្នំពេញ: វិទ្យាស្ថានជាតិអប់រំ.

Beishuizen, J.(2001). Students′ and Teachers′ recognition about good teacher. British Journal of Educational Psychology, 185-201

Brown, H.D.(2001). Teaching by principles: an interactive approach to language pedagogy. New York: Addison Wesley.

Burton, J. (2000). Learning from teaching practice: a case study approach. Prospect 5-22

Celce-Murcia, M. (2001) Teaching English as a second Language. Boston: Heinle& Hein

Cheng Lying & Andy Curtis. (2010). Teachers´ self-evaluation of Knowledge, skills and personality characteristics. Asia-Pacific Journal of teacher Education. 139-152.

Clayton, T. (2007). Transition, Culture, Language in Cambodia. IN A. B.Tollefson, language Policy, Culture, and Identity in Asia Contents. (pp. 95-120).

Elliot, S., Kratochil, T.,&Cook, J.(2000). Educational psychology. New York: McGraw-Hill.

Ethell, R. G. & McMeniman, M. M. (2000). Unlocking the knowledge in action of an expert practitioner. Journal of Teacher Education, 87-101.

Gardner, R. C. (2000). The social-educational model of second language acquisition. A research paradigm, 237-260.

Glatthor, A . & Jailall, J. (2000). Curriculum for the new millennium. Review of Educational Research , 99-119.

Grower, R , Phillips, D.,&Walters, S. (2005). Teaching practice: A handbook for teachers in training. Thailand : Macmillan Education.

Hayes, D. (2014) Factor influencing success in teaching English in state primary school London: British Council.

Hong Thi Nguyen, Wendy Warren & Heather Fehring . (2014). Factor affecting English

Language Teaching and Learning in Higher education. English language Teaching, 94-105.

Huang, Z. (2010). What makes a successful EFL Teacher in China? A case study of an English Language Teacher at Nanjing University of Chinese Medicine.

Igawa, K. (2008). English and Education in Cambodia , a Country in Transition. Shitennoji University Bulletin, 343-369.

Lee, Gi- Pyo park 7 Hyo-Woong. (2006). The characteristics of Effective English Teachers As perceived by High School Teacher and Students in Korea. Asia Pacific Education Review, 236-248.

Mao, S. (2013). Education and Policy of English Language. Forum publications Complete, 23-32.

Mao, S. (2013). Education and Policy of English Language in T, W Bigalke & S, Sabarwi(eds), English for Asean Integration: Policy and practice in Region, University Brunei Darrussalum.

Minh, L.L (2013). Asean state Of Education 2013. Jakata: Asean Secretarial.

Mosha, M. A. (2014). Factor Affecting Students performance in English Language in Zanzibar Rural and urban Secondary School, 64-77.

Naron, H. C. (2014). Education Reform, English Language learning and Asean community.

Petty, G. (1998). Teaching Today. English: Stanley Thornes.

Stabback,P. (2016). What makes a quality curriculum

Ster, H. (2001). Fundamental concepts of Language teaching. Oxford University.

Woodward, T. ( 2001 ). Planning lessons and courses: Designing sequences of work. Cambridge: Cambridge University Press.

Yoon, K. S. ( 2007 ). Reviewing the evidence on how teacher professional development Affects students achievement . Washington DC. US.

Elena, T. T. ( 2006 ). Concepts on The Methodology of Teaching English. Journal of Takasaki city University .( pp, 169-188 ).

# ឧបសម្ព័ន្ធ

# ឧបសម្ព័ន្ធទី១

# កម្រងសំណួរសម្រាប់នាយក

ខ្ញុំបាទឈ្មោះ**ថៃ ណាគ្រី**ជានិស្សិតបរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំនៃវិទ្យាស្ថានជាតិអប់រំ បានរៀបចំការសិក្សាស្រាវជ្រាវមួយទាក់ទងទៅនឹងប្រធានបទ"ការប្រើប្រាស់សៀវភៅសិក្សាភាសាអង់គ្លេសនៅកម្រិតអនុវិទ្យាល័យ ក្នុងខេត្តស្វាយរៀង"។អាស្រ័យហេតុនេះសូមលោកនាយក/នាយិកាទាំងអស់មេត្តាជួយឆ្លើយនូវកម្រងសំនួរនេះតាមភាពជាក់ស្ដែងរបស់ខ្លួន។រាល់ចម្លើយរបស់នាយក/នាយិកាទាំងអស់នឹងត្រូវបានរក្សាជាការសម្ងាត់និងប្រើសម្រាប់ការសរសេរសារណានេះតែប៉ុណ្ណោះ។សូមថ្លែងអំណរគុណដល់នាយក/នាយិកាទាំងអស់ដែលបានចំណាយពេលវេលាក្នុងការចូលរួមជាមួយខ្ញុំបាទក្នុងការសិក្សាស្រាវជ្រាវដ៏មានសារៈសំខាន់មួយនេះ។

**សូមលោកនាយក/នាយិកាជួយគូសសញ្ញា(☑)ក្នុងប្រអប់ចម្លើយ របស់សំណួរនីមួយៗខាងក្រោមទៅតាមស្ថានភាពជាក់ស្ដែងរបស់លោកនាយក/នាយិកាដែលបានជ្រើសរើស៖**

**ផ្នែកទី១៖ព័ត៌មានទូទៅ**

ខេត្ត៖ស្វាយរៀង

១.ស្រុក/ក្រុង……………… ……………….　　២.សាលា៖……………………………………….

៣.ឋានៈតួនាទី៖ □១.នាយក/នាយិកា　　□២.នាយករង/នាយិការង

៤.ភេទ៖ □ប្រុស　　□ស្រី

**ផ្នែកទី២៖គុណវុឌ្ឍិនាយក/នាយិកាសាលា**

៥.តើលោកនាយក/នាយិកាមានតួនាទីជានាយកនៅសាលានេះប៉ុន្មានឆ្នាំហើយ?

១. □១ឆ្នាំ ដល់៥ឆ្នាំ　　២. □៥ឆ្នាំ ដល់១០ឆ្នាំ

៣. □១១ឆ្នាំ ដល់២០ឆ្នាំ　　៤.□ ច្រើនជាង២០ឆ្នាំ

៦.តើលោកនាយក/នាយិកាមានក្របខណ្ឌប្រភេទអ្វី?

១ □គ្រូបង្រៀនកម្រិតមូលដ្ឋាន　　២□ គ្រូបង្រៀនកម្រិតឧត្ដម

៧.សូមបញ្ជាក់ពីកម្រិតសញ្ញាបត្រចុងក្រោយរបស់លោកនាយក/នាយិកា៖

□១. សញ្ញបត្រមធ្យមសិក្សាទុតិយភូមិ(ឯកទេស៖……………………………………)

□២. សញ្ញាបត្របរិញ្ញបត្រ(ឯកទេស៖………………………………………………….)

□៣. សញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់(ឯកទេស៖……………………………………..)

□៤.សញ្ញាបត្របណ្ឌិត(ឯកទេស៖……………………………………………………..)

៨.លោកនាយកនាយិកាធ្លាប់បានចូលរួមវគ្គបំប៉នខ្លីៗទាក់ទងទៅនឹងការគ្រប់គ្រងដែរឬទេ បើបានវគ្គនោះមានរយៈពេលប៉ុន្មានថ្ងៃ?

១□មាន(រយៈពេល)…………………….. ២□គ្មាន

**ផ្នែកទី៣៖ការគ្រប់គ្រងសាលារៀន**

៩.តើសាលារៀនមានគ្រូភាសាអង់គ្លេសថ្នាក់ទី 7 ទី 8 ទី 9 ប៉ុន្មាននាក់?

…………………………………………………………………………………………………

…………………………………………………………………………………………………

១០.តើពួកគាត់សុទ្ធតែមានជំនាញឯកទេសភាសាអង់គ្លេសទាំងអស់ឬយ៉ាងណា?

…………………………………………………………………………………………………

…………………………………………………………………………………………………

១១.តើពួកគាត់សុទ្ធតែមានសមត្ថភាពគ្រប់គ្រាន់ក្នុងការបង្រៀនឬយ៉ាងណា?

…………………………………………………………………………………………………

…………………………………………………………………………………………………

១២.តើលោកគ្រូអ្នកគ្រូមុខវិជ្ជាភាសាអង់គ្លេសបានទទួលការបណ្ដុះបណ្ដាលប្រយ័ត្នពេលខ្លីឬចូលរួមសិក្ខាសាលាទាក់ទងទៅនឹងការប្រើប្រាស់សៀវភៅភាសាអង់គ្លេសឬវិធីសាស្ត្របង្រៀនរយៈពេល 5 ឆ្នាំចុងក្រោយដែរឬទេ?

១□ មាន ២ □គ្មាន

១៣.តើលោកនាយកនាយិកាគិតថាគ្រូភាសាអង់គ្លេសបានអនុវត្តការងាររបស់ខ្លួនដល់កម្រិតណាពាក់ព័ន្ធទៅនឹង

□១.ការមកបង្រៀនទៀងទាត់

□២.ការរៀបចំកិច្ចតែងការបង្រៀន

□៣.ការពង្រឹងចំណេះដឹងនិងជំនាញទាក់ទងនឹងមុខវិជ្ជាកំពុងបង្រៀន

□៤.ការយកចិត្តទុកដាក់លើការសិក្សារបស់សិស្ស

**ផ្នែកទី៤៖ សម្ភារៈសិក្សា**

១៤.តើសិស្សមានសៀវភៅពុម្ពភាសាអង់គ្លេសគ្រប់គ្នាដែរឬទេ ?

……………………………………………………………………………………………………

……………………………………………………………………………………………………

១៥.តើសាលាមានសម្ភារៈឧបទេសអ្វីខ្លះសម្រាប់ជួយដល់ការគាំទ្រការបង្រៀនភាសាអង់គ្លេសរបស់លោកគ្រូ អ្នកគ្រូ ?

……………………………………………………………………………………………………

……………………………………………………………………………………………………

១៦.តើលោកគ្រូអ្នកគ្រូបានប្រើប្រាស់សម្ភារៈទាំងនេះដល់កម្រិតណា ?

……………………………………………………………………………………………………

……………………………………………………………………………………………………

១៧.តើលោកនាយក/នាយិកាបានសំណូមពរអ្វីខ្លះដើម្បីឱ្យស្ថានភាពនៃការប្រើប្រាស់សៀវភៅសិក្សាភាសាអង់គ្លេសនៅក្នុងសាលារបស់លោកនាយក/នាយិកាកាន់តែប្រសើរជាងនេះ ?

……………………………………………………………………………………………………

……………………………………………………………………………………………………

……………………………………

# កម្រងសំណួរសម្រាប់គ្រូ

ខ្ញុំបាទឈ្មោះ**ថៃ ណារត្រី**ជានិស្សិតបរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំនៃវិទ្យាស្ថានជាតិអប់រំ បានរៀបចំការសិក្សាស្រាវជ្រាវមួយទាក់ទងទៅនឹងប្រធានបទការសិក្សា"**ការប្រើប្រាស់សៀវភៅសិក្សាភាសាអង់គ្លេសនៅកម្រិតអនុវិទ្យាល័យ ក្នុងខេត្តស្វាយរៀង**"។អាស្រ័យហេតុនេះសូមលោកគ្រូអ្នកគ្រូទាំងអស់មេត្តាជួយឆ្លើយនូវកម្រងសំនួរនេះតាមភាពជាក់ស្តែងរបស់ខ្លួន។រាល់ចម្លើយរបស់លោកគ្រូ អ្នកគ្រូទាំងអស់នឹងត្រូវបានរក្សាជាការសម្ងាត់និងប្រើសម្រាប់ការសរសេរសារណានេះតែប៉ុណ្ណោះ។សូមថ្លែងអំណរគុណដល់លោកគ្រូ អ្នកគ្រូទាំងអស់ដែលបានចំណាយពេលវេលាក្នុងការចូលរួមជាមួយខ្ញុំបាទក្នុងការសិក្សាស្រាវជ្រាវដ៏មានសារៈសំខាន់មួយនេះ៖

**ផ្នែកទី១៖ព័ត៌មានទូទៅ**

**ខេត្តស្វាយរៀង**

**១. ស្រុក/ក្រុង.......................... ២.សាលា៖....................................**

៣. ភេទ ☐ ក. ប្រុស ☐ ខ. ស្រី

**ផ្នែកទី២៖គុណវុឌ្ឍិគ្រូបង្រៀនភាសាអង់គ្លេស**

៤.តើលោកគ្រូអ្នកគ្រូមានក្របខណ្ឌប្រភេទអ្វី?

☐ ១.គ្រូបង្រៀនកម្រិតឧត្តម ☐ ២.គ្រូបង្រៀនកម្រិតមូលដ្ឋាន

៥.សូមបញ្ជាក់ពីកម្រិតសញ្ញាបត្រចុងក្រោយរបស់លោកគ្រូ អ្នកគ្រូ៖

☐ សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ☐ ២.សញ្ញាបត្របរិញ្ញាបត្រ

☐ ៣.សញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់ ☐ ៤.សញ្ញាបត្របណ្ឌិត

៦.តើលោកគ្រូ អ្នកគ្រូយល់ថានៅពេលមានសមត្ថភាពខ្ពស់អាចជួយឱ្យសិស្សឆាប់យល់មេរៀនកម្រិតណា

☐ ១.ខ្លាំងណាស់ ☐ ២.ខ្លាំង ☐ ៣.មធ្យម ☐ ៤.ខ្សោយ ☐ ៥.អត់សោះ

៧. តើលោកគ្រូ អ្នកគ្រូមានបទពិសោធន៏បង្រៀនភាសាអង់គ្លេស ប៉ុន្មានឆ្នាំ?

☐ ១.តិចជាង៥ឆ្នាំ ☐ ២. ៦ទៅ១០ឆ្នាំ ☐ ៣. ១១ទៅ១៥ឆ្នាំ ☐៥.ច្រើនជាងង១៥ឆ្នាំ

៨. តើលោកគ្រូ អ្នកគ្រូមានបទពិសោធន៏បង្រៀនភាសាអង់គ្លេស នៅអនុវិទ្យាល័យប៉ុន្មានឆ្នាំ?

☐ ១.តិចជាង៥ឆ្នាំ ☐ ២. ៦ទៅ១០ឆ្នាំ ☐ ៣. ១១ទៅ១៥ឆ្នាំ ☐៥.ច្រើនជាងង១៥ឆ្នាំ

៩.តើលោកគ្រូ អ្នកគ្រូឆ្លងកាត់វគ្គបណ្តុះបណ្តាលខ្លីឬសិក្ខាសាលាទាក់ទងនឹងគរុកោសល្យ ឬវិធីសាស្រ្តបង្រៀន ភាសាអង់គ្លេសរយៈពេល៥ឆ្នាំចុងក្រោយនេះដែរឬទេ?

☐ ១.មាន ☐ ទេ

១០.តើលោកគ្រូ អ្នកគ្រូគិតថាការចូលរួមវគ្គបណ្តុះបណ្តាលខ្លីឬសិក្ខាសាលាទាក់ទងនឹងគរុកោសល្យមានប្រយោជន៍ដល់ការប្រើប្រាស់សៀវភៅសិក្សាគោលភាសាអង់គ្លេសលោកគ្រូអ្នកគ្រូកម្រិតណា?

☐ ១.ខ្លាំងណាស់ ☐ ២.ខ្លាំង ☐ ៣.មធ្យម ☐ ៤.ខ្សោយ ☐ ៥.អត់សោះ

១១.សូមជ្រើសរើសវគ្គបំប៉នខាងក្រោមចំនួន៣ដែលលោកគ្រូ អ្នកគ្រូត្រូវការចាំបាច់ដើម្បីប្រើប្រាស់សៀវភៅសិក្សាគោលភាសាអង់គ្លេសនៅកម្រិតបឋមភូមិ?

☐ ១.ចិត្ត គរុកោសល្យ ☐ ២.វិធីសាស្ត្របង្រៀន

☐ ៣.ពង្រឹងចំណេះដឹងភាសាអង់គ្លេស ☐ ៤. បច្ចេកវិទ្យាព័ត៌មាន

☐ ៥.ការផលិត និងប្រើប្រាស់សម្ភារៈឧបទេស

**ផ្នែកទី៣៖កម្មវិធីសិក្សា**

១២.តើលោកគ្រូ អ្នកគ្រូមានបំណែងចែកកម្មវិធីសិក្សាប្រចាំឆ្នាំដែរឬទេ?

☐ ១.មាន ☐ ២.គ្មាន

១៣.តើបំណែងចែកកម្មវិធីសិក្សាភាសាអង់គ្លេសមានសារៈសំខាន់កម្រិតណាលើមុខវិជ្ជាភាសាអង់គ្លេសរបស់លោកគ្រូអ្នកគ្រូ?

☐ ១.ខ្លាំងណាស់ ☐ ២.ខ្លាំង ☐ ៣.មធ្យម ☐ ៤.ខ្សោយ ☐ ៥.អត់សោះ

១៤.តើខ្លឹមសារសៀវភៅសិក្សាគោលសមស្របទៅនឹងកម្រិតសមត្ថភាពភាសាអង់គ្លេសរបស់សិស្សដែរឬទេ?

☐ ១. មានកម្រិតខ្ពស់ជាងសមត្ថភាពសិស្ស ☐ ២. ស្របទៅនឹងសមត្ថភាពសិស្ស

☐ ៣.ទាបជាងសមត្ថភាពសិស្ស

១៥. តើចំនួនមេរៀនក្នុងសៀវភៅសិក្សាគោលសសមស្របទៅនឹងពេលវេលាដែលត្រូវដាក់ឱ្យក្នុងមួយឆ្នាំដែលឬទេ?

☐ ១.សមស្រប ☐ ២.មិនសមស្រប

១៦. តើម៉ោងបង្រៀនភាសាអង់គ្លេសនៅសាលារបស់លោកគ្រូគ្រប់គ្រាន់ឱ្យសិស្សចេះដែរឬទេ?

☐ ១.គ្រប់គ្រាន់ ☐ ២.មិនគ្រប់គ្រាន់

១៧. បើមិនគ្រប់គ្រាន់ តើម៉ោងភាសាអង់គ្លេសនៅសាលារដ្ឋគួរតែមានប៉ុន្មានម៉ោងក្នុង ១សប្តាហ៍?

☐ ១. ៤ម៉ោង ☐ ២. ៥ម៉ោង ☐ ៣. ៦ម៉ោង

**ផ្នែកទី៤៖ សម្ភារឧបទេសសម្រាប់ទ្រទ្រង់ការប្រើប្រាស់សៀវភៅសិក្សាគោល**

១៨. ស្ថានភាពសម្ភារ និង កម្រិត នៃការប្រើប្រាស់សម្ភាររបស់គ្រូ៖

| ប្រភេទសម្ភារៈ | ស្ថានភាពជាក់ស្តែង | | កម្រិតនៃការប្រើប្រាស់សម្ភាររបស់គ្រូ | | | |
|---|---|---|---|---|---|---|
| | គ្មាន (បើគ្មានសូមមេត្តាកុំគូសបន្ត) | មាន(បើមានសូមគូសបន្ត) | ប្រើប្រាស់គ្រប់ពេល(១) | ប្រើប្រាស់ញឹកញាប់(២) | ប្រើប្រាស់ម្តងម្កាល(៣) | អត់ប្រើប្រាស់សោះ(៤) |
| ១.សៀវភៅសិក្សាគោល | | | | | | |

| | | | | | | |
|---|---|---|---|---|---|---|
| ២.សៀវភៅគ្រូ | | | | | | |
| ៣.ម៉ាញ៉េចាក់កាសែតឬស៊ីឌី | | | | | | |
| ៤.បណ្ណរូបភាពឬបណ្ណពាក្យ | | | | | | |
| ៥. បន្ទប់អនុវត្តស្តាប់ | | | | | | |
| ៦.បណ្ណាល័យដែលមានឯកសារជាភាសាអង់គ្លេស | | | | | | |

១៩.ការប្រើប្រាស់សម្ភារៈឧបទេសគ្រប់ម៉ោងសិក្សាមានប្រយោជន៍ដល់ការបង្រៀនភាសាអង់គ្លេសរបស់សិស្សកម្រិតណា?

☐ ១.ខ្លាំងណាស់ ☐ ២.ខ្លាំង ☐ ៣.មធ្យម ☐ ៤.ខ្សោយ ☐ ៥.អត់សោះ

**ផ្នែកទី៥៖សកម្មភាពប្រើប្រាស់សៀវភៅសិក្សាគោលរបស់សិស្សក្នុងថ្នាក់**

២០.តើលោកគ្រូអ្នកគ្រូប្រើប្រាស់សកម្មភាពទាំងនេះក្នុងការប្រើប្រាស់សៀវភៅសិក្សាគោលកម្រិតណា?

| សកម្មភាព | គ្រប់ពេល | ញឹកញាប់ | ពេលខ្លះ | កម្រណាស់ | អត់សោះ |
|---|---|---|---|---|---|
| ១.សិស្សអានសៀវភៅម្នាក់ឯង | | | | | |
| ២.សិស្សអានសៀវភៅជាគូរ | | | | | |
| ៣.សិស្សអានសៀវភៅជាក្រុម | | | | | |
| ៤.សិស្សទាំងអស់គ្នាអានរួមគ្នា | | | | | |

២១.តើក្នុង១សប្តាហ៍លោកគ្រូអ្នកគ្រូផ្តល់កិច្ចការផ្ទះឱ្យសិស្សធ្វើបានប៉ុន្មានដង?

☐ ៤ដង ☐ ៣ដង ☐ ២ដង ☐ ១ដង ☐ អត់សោះ

២២. តើលោកគ្រូ អ្នកគ្រូបានព្យាយាមលើកទឹកចិត្តសិស្សឱ្យប្រើប្រាស់សៀវភៅសិក្សាគោលដល់កម្រិតណា?

☐ ១.គ្រប់ពេល ☐ ២. ញឹកញាប់ ☐ ៣.ម្តងម្កាល ☐ អត់សោះ

**ផ្នែកទី៦៖ការរៀបចំមេរៀន**

២៣.តើលោកគ្រូអ្នកគ្រូធ្វើកិច្ចតែងការបានគ្រប់មេរៀន តាមសៀវភៅសិក្សាគោលដែរឬទេ?

☐ ១.គ្រប់មេរៀន ☐ ២.ពេលខ្លះ ☐ ៣.ម្តងម្កាល ☐ ៤.អត់សោះ

**ផ្នែកទី៧៖បរិមាណសិស្សក្នុងថ្នាក់**

២៤. តើជាមធ្យមថ្នាក់រៀនដែលលោកគ្រូ អ្នកគ្រូបង្រៀនមានសិស្សប៉ុន្មាននាក់?

☐ ១.តិចជាង៣០ ☐ ២. ៣០-៣៥ ☐ ៣. ៣៦-៤០ ៤. ☐ ៤១-៤៥

☐ ៥. ៤៦-៥០ ☐ ៦. ច្រើនជាង៥០

២៥.លោកគ្រូ អ្នកគ្រូយល់ថាចំនួនសិស្សច្រើននៅក្នុងថ្នាក់ធ្វើឱ្យជះឥទ្ធពលអវិជ្ជមានកម្រិតណា?

☐ ១.ខ្លាំងណាស់ ☐ ២.ខ្លាំង ☐ ៣.មធ្យម ☐ ៤.តិចតួច ☐ ៥.អត់សោះ

**ផ្នែកទី៨៖ស្ថានភាពសិក្សារបស់សិស្ស**

២៦.តើលោកគ្រូអ្នកគ្រូសង្កេតឃើញថាសិស្សបានប្រឹងប្រែងក្នុងភាសាអង់គ្លេសកម្រិតណា ?

| បរិយាយ | កម្រិតនៃការប្រឹងប្រែង | | | | |
|---|---|---|---|---|---|
| | ល្អណាស់ | ល្អ | បង្គួរ | មធ្យម | ខ្សោយ |
| ១.មករៀនទៀងទាត់ និងទាន់ពេលវេលា | | | | | |
| ២.យកចិត្តទុកដាក់ស្តាប់គ្រូក្នុងម៉ោងសិក្សា | | | | | |
| ៣.ចូលរួមធ្វើសកម្មភាពផ្សេងៗដែលគ្រូឱ្យ | | | | | |
| ៤.ធ្វើកិច្ចការផ្ទះដែលគ្រូដាក់ឱ្យទៀងទាត់ | | | | | |

២៧.សំណូមពរទាក់ទងទៅនឹងបញ្ហានានាដែលមាននៅក្នុងសៀវភៅសិក្សាគោលភាសាអង់គ្លេស ?

……………………………………………………………………………………………………………………..

……………………………………………………………………………………………………………………..

……………………………………………………………………………………………………………………..

……………………………………………………………………………………………………………………..

……………………………………………………………………………………………………………………..

# កម្រងសំណួរសម្រាប់សិស្ស

ខ្ញុំបាទឈ្មោះ **ថៃ ណាគ្រី** ជានិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់គ្រប់គ្រងអប់រំនៃវិទ្យាស្ថានជាតិអប់រំ នឹងធ្វើការស្រាវជ្រាវបញ្ចប់ឆ្នាំសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់សិក្សាក្រោមប្រធានបទ«**ការប្រើប្រាស់សៀវភៅភាសាអង់គ្លេសនៅកម្រិតអនុវិទ្យាល័យ ក្នុងខេត្តស្វាយរៀង**» អាស្រ័យ ហេតុនេះ សូមប្អូនៗ សិស្សានុសិស្ស មេត្តាជួយឆ្លើយនូវកម្រងសំណួរនេះ ទៅតាមស្ថានភាពជាក់ស្តែងរបស់ប្អូនៗ ហើយព័ត៌មានរបស់ប្អូនៗ នឹងត្រូវបានរក្សាជាការសម្ងាត់។ ការចូលរួមរបស់ប្អូន ពិតជាមានសារៈសំខាន់ ក្នុងការពង្រឹងគុណភាពអប់រំនៅប្រទេសកម្ពុជាយើង។

ជាចុងក្រោយខ្ញុំបាទសូមថ្លែងអំណរគុណចំពោះប្អូនៗទាំងអស់ ដែលបានចំណាយពេលវេលា ក្នុងការចូលរួម ជាមួយខ្ញុំក្នុងការសិក្សាស្រាវជ្រាវ ប្រធានបទដែលមានសារៈសំខាន់មួយនេះ។

សូមប្អូនៗជួយគូសសញ្ញា(✓)ក្នុងប្រអប់ចម្លើយ របស់សំណួរនីមួយៗខាងក្រោមទៅតាមស្ថានភាពជាក់ស្តែងរបស់ខ្លួន៖

**ផ្នែកទី១៖ព័ត៌មានទូទៅ**

**ខេត្តស្វាយរៀង**

**១. ស្រុក/ក្រុង..........................** **២.សាលា៖....................................**

៣. ភេទ ☐ ក. ប្រុស ☐ ខ. ស្រី

**ផ្នែកទី២៖គុណវុឌ្ឍិគ្រូបង្រៀនភាសាអង់គ្លេស**

៤.តើគ្រូបង្រៀនភាសាអង់គ្លេសរបស់ប្អូនមានចំណេះដឹងកម្រិតណា?

☐ ១.ខ្លាំងណាស់ ☐ ២.ខ្លាំង ☐ ៣.មធ្យម ☐ ៤.ខ្សោយ

៥.តើគ្រូមានសមត្ថភាពជួយប្អូនឆាប់យល់មេរៀនក្នុងសៀវភៅសិក្សាបានដល់កម្រិតណា?

☐ ១.ខ្លាំងណាស់ ☐ ២.ខ្លាំង ☐ ៣.មធ្យម ☐ ៤.ខ្សោយ

៦.តើប្អូនយល់យ៉ាងណាចំពោះការបង្រៀនភាសាអង់គ្លេសរបស់គ្រូប្អូន?

☐ ១.ល្អណាស់ ☐ ២.ល្អ ☐ ៣.មធ្យម ☐ ៤.ខ្សោយ

**ផ្នែកទី៣៖កម្មវិធីសិក្សា**

៧.តើខ្លឹមសារមេរៀនក្នុងសៀវភៅសិក្សាគោលស្របទៅនឹងកម្រិត សមត្ថភាពភាសាអង់គ្លេសរបស់ប្អូនៗដែរឬទេ?

☐ ១.មានកម្រិតខ្ពស់ជាសមត្ថភាពរបស់ខ្ញុំ ☐ ២.ស្របទៅនឹងសមត្ថភាពរបស់ខ្ញុំ

☐ ៣.ទាបជាងសមត្ថភាពរបស់ខ្ញុំ

៨.តើប្អូនចាប់អារម្មណ៍ដូចម្តេចចំពោះសៀវភៅភាសាអង់គ្លេសដែលប្អូនកំពង់រៀនសព្វថ្ងៃ?

☐ ១.គួរឱ្យចាប់អារម្មណ៍ខ្លាំង ☐ ២.មិនសូវចាប់អារម្មណ៍ខ្លាំង

☐ ៣. គួរឱ្យធុញទ្រាន់

៩.តើម៉ោងភាសាអង់គ្លេសនៅសាលារៀនរបស់ប្អូនគ្រប់គ្រាន់សម្រាប់ប្រើប្រាស់សៀវភៅពុម្ពដែរឬទេ?

☐ ១.គ្រប់គ្រាន់ ☐ ២.មិនគ្រប់គ្រាន់

១០.តើប្អូនត្រូវការប៉ុន្មានម៉ោងក្នុងមួយសប្តាហ៍ ដើម្បីឱ្យបានគ្រប់គ្រាន់ក្នុងការប្រើប្រាស់សៀវភៅពុម្ព?

☐ ១. ៤ម៉ោង ☐ ២. ៥ម៉ោង ☐ ៣. ៦ម៉ោង

**ផ្នែកទី៤៖ សម្ភារៈឧបទេស**

១១. ស្ថានភាពសម្ភារៈ និងកម្រិតនៃការប្រើប្រាស់សម្ភារៈរបស់គ្រូ

| ប្រភេទសម្ភារៈ | កម្រិតនៃការប្រើប្រាស់សម្ភារៈគ្រូ | | | |
|---|---|---|---|---|
| | ប្រើគ្រប់ពេល(១) | ប្រើញឹកញាប់(២) | ប្រើម្តងម្កាល(៣) | អត់ប្រើសោះ(៤) |
| ១.សៀវភៅពុម្ព | | | | |
| ២.ម៉ាញ៉េចាក់កាសែតឬស៊ីឌី | | | | |
| ៣.បណ្ណរូបភាព ឬបណ្ណពាក្យ | | | | |
| ៤.បន្ទប់អនុវត្តន៍( ស្តាប់និងមើលវីឌេអូ) | | | | |
| ៥.បណ្ណាល័យដែលមានឯកសារភាសាអង់គ្លេស | | | | |

១២.ការប្រើប្រាស់សម្ភារៈឧបទេសគ្រប់គ្រាន់ តើមានប្រយោជន៍ដល់ការសិក្សាភាសាអង់គ្លេសរបស់ប្អូនៗដល់កម្រិតណា?

☐ ១.ខ្លាំងណាស់ ☐ ២.ខ្លាំង ☐ ៣.មធ្យម ☐ ៤.តិចតួច ☐ ៥.អត់សោះ

**ផ្នែកទី៥៖សមត្ថភាពប្រើប្រាស់សៀវភៅក្នុងថ្នាក់**

១៣.តើលោកគ្រូ អ្នកកគ្រូប្រើប្រាស់សកម្មភាពទាំងនេះនៅក្នុងការប្រើប្រាស់សៀវភៅពុម្ពបានដល់កម្រិតណាក្នុងការបង្រៀន?

| សកម្មភាព | គ្រប់ពេល | ញឹកញាប់ | ពេលខ្លះ | កម្រណាស់ | អត់សោះ |
|---|---|---|---|---|---|
| ១.សិស្សអានសៀវភៅម្នាក់ម្តង | | | | | |
| ២.សិស្សអានសៀវភៅជាគូរ | | | | | |
| ៣.សិស្សអានសៀវភៅជាក្រុម | | | | | |
| ៤.សិស្សទាំងអស់គ្នាអានរួមគ្នា | | | | | |

១៤.តើលោកគ្រូ អ្នកគ្រូបានលើកទឹកចិត្តឱ្យប្អូនៗខិតខំអានសៀវភៅភាសាអង់គ្លេសបានដល់កម្រិតណា?

☐ ១.គ្រប់ពេល ☐ ២.ញឹកញាប់ ☐៣.ម្ដងម្កាល ☐ ៤.អត់សោះ

១៥.តើគ្រូបង្រៀនមុខវិជ្ជាភាសាអង់គ្លេសបានដាក់កិច្ចការផ្ទះឱ្យប្អូនអនុវត្តតាមសៀវភៅពុម្ពប៉ុន្មានដងក្នុងមួយសប្ដាហ៍

☐ ៤ដង ☐ ៣ដង ☐ ២ដង ☐ ១ដង ☐ អត់សោះ

**ផ្នែកទី៦៖បរិមាណសិស្សក្នុងថ្នាក់**

១៦. តើនៅក្នុងថ្នាក់រៀនរបស់ប្អូនជាមធ្យមមានសិស្សប៉ុន្មាននាក់?

☐ ១.តិចជាង៣០ ☐ ២. ៣០-៣៥ ☐ ៣. ៣៦-៤០ ៤. ☐ ៤១-៤៥

☐ ៥. ៤៦-៥០ ☐ ៦. ច្រើនជាង៥០

១៧.តើសិស្សច្រើននៅក្នុថ្នាក់អាចជះឥទ្ធិពលដល់ការសិក្សាកម្រិតណា?

☐ ១.ខ្លាំងណាស់ ☐ ២.ខ្លាំង ☐ ៣.មធ្យម ☐ ៤.តិចតួច ☐ ៥.អត់សោះ

**ផ្នែកទី៧ ស្ថានភាពសិក្សារបស់សិស្ស**

១៨.តើប្អូនបានប្រឹងប្រែងក្នុងការសិក្សាភាសាអង់គ្លេសនៅក្នុងថ្នាក់ដល់កម្រិតណា?

| បរិយាយ | កម្រិតនៃការប្រឹងប្រែង | | | | |
|---|---|---|---|---|---|
| | ល្អណាស់ | ល្អ | បង្គួរ | មធ្យម | ខ្សោយ |
| ១.មករៀនទៀងទាត់ និងទាន់ពេលវេលា | | | | | |
| ២.យកចិត្តទុកដាក់ស្ដាប់គ្រូក្នុងម៉ោងសិក្សា | | | | | |
| ៣.ចូលរួមធ្វើសកម្មភាពផ្សេងៗដែលគ្រូឱ្យ | | | | | |
| ៤.ធ្វើកិច្ចការផ្ទះដែលគ្រូដាក់ឱ្យទៀងទាត់ | | | | | |

១៩.សំណូមពរទាក់ទងទៅនឹងបញ្ហានានាចំពោះសៀវភៅពុម្ពភាសាអង់គ្លេសរបស់ប្អូន?

……………………………………………………………………………………………

……………………………………………………………………………………………

……………………………………………………………………………………………

……………………………………………………………………………………………

……………………………………………………………………………………………

# ឧបសម្ព័ន្ធទី២៖ លិខិតឧទ្ទេសនាម និងឯកសារពាក់ព័ន្ធ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

វិទ្យាស្ថានជាតិអប់រំ
លេខ :..............វជអ.

## លិខិតអញ្ជើញ

សូមគោរពអញ្ជើញ ៖ និស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៧

ដើម្បីចូលរួម ៖ ការពារនិក្ខេបបទ

កាលបរិច្ឆេទ ៖ ពីថ្ងៃសៅរ៍-អាទិត្យ ៨-៩កើត ខែកត្តិក ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤ ត្រូវនឹងថ្ងៃទី២៤-២៥ ខែតុលា ឆ្នាំ២០២០ វេលាម៉ោង ០៧:៣០នាទីព្រឹកដល់១៧:៣០រសៀល (មានភ្ជាប់ជូនកម្មវិធី)។

ទីកន្លែង ៖ វិទ្យាស្ថានជាតិអប់រំនៅអគារ H បន្ទប់ជាន់ទី១។

ថ្ងៃពុធ ៥កើត ខែកត្តិក ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី២១ ខែតុលា ឆ្នាំ២០២០

នាយកវិទ្យាស្ថានជាតិអប់រំ

បណ្ឌិត.សៀង សុវណ្ណា

ព័ត៌មានបន្ថែម ៖

- ✓ សម្លៀកបំពាក់សម្រាប់និស្សិត៖ បុរសអាវធំខ្មៅឬខៀវចាស់ និងខោខ្មៅ និងនិស្សិតនារីអាវប៉ាកស សំពត់ខ្មៅ ឬខៀវ។
- ✓ និស្សិតមានសិទ្ធិឡើងការពារនិក្ខេបបទបញ្ចប់ការសិក្សាលុះណាមានការឯកភាពពីលោកគ្រូដឹកនាំ និងដឹកនាំរង។

អាសយដ្ឋានលេខ ១២៣ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ៖ (៨៥៥-២៣) ២១៥/៥៨៨ គេហទំព័រ៖ www.nie.edu.kh